សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីបណ្តឹងសាទុក្ខនៃរឿងក្តីរដ្ឋប្បវេណី

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦

រៀបរៀងដោយ ៖
និស្សិតឈ្មោះ **លោក កែវ វណ្ណះ**
**លោក ឈិន ធារិទ្ធិ**

សាស្ត្រាចារ្យណែនាំ
**លោកជំទាវ ខួន មករា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទ **កែវ វណ្ណះ** និងខ្ញុំបាទ **ឈិន ធារិទ្ធិ** សូមសម្តែងការគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត បានចិញ្ចឹមបីបាច់ថែរក្សា និងបានផ្តល់នូវសេចក្តីស្រឡាញ់ មេត្តា ករុណា អប់រំទូន្មានកូនឲ្យមានសេចក្តីព្យាយាមក្នុងជីវិត ។ លោកបានធ្វើការចំណាយពេលវេលា កំលាំងកាយ ចិត្ត និងធនធានយ៉ាងច្រើនដោយមិនគិតពីការនឿយហត់ មិនដែលពោលពីទុក្ខលំបាកគ្រប់បែបយ៉ាងដើម្បីផ្គត់ផ្គង់ដល់ការសិក្សារបស់កូនឱ្យទទួលបាននូវចំណេះដឹងដ៏ប្រពៃថ្លៃថ្លាសម្រាប់ជាស្ពានចម្លងខ្លួនឯង គ្រួសារ ក៏ដូចជាសង្គមជាតិ ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ **ឯកឧត្តម លុយ ចណ្ណា** ជាសាកលវិទ្យាធិការ ព្រមទាំងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានលះបង់នូវរាល់កម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំ បង្ហាត់បង្រៀន ដើម្បីផ្តល់នូវចំណេះដឹងថ្មីៗ និងដំបូន្មានល្អៗ ដល់យើងខ្ញុំទាំងអស់គ្នា ។ តាមរយៈគុណោបការៈរបស់អស់លោក ទើបធ្វើឲ្យយើងខ្ញុំទទួលបាននូវចំណេះដឹងល្អៗដែលនាំឱ្យយើងអាចបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យនាពេលនេះ ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ **ឯកឧត្តម ឌិត មុន្ទី** ប្រធានតុលាការកំពូល ដែលបានអនុញ្ញាតឱ្យយើងខ្ញុំ ចុះទៅស្រាវជ្រាវឯកសារនៅតុលាការកំពូល ។ ហើយសូមថ្លែងអំណរគុណ យ៉ាងខ្ពង់ខ្ពស់ចំពោះលោកក្រឡាបញ្ជី **សុខ ផលី** ដែលបានសហការណ៍ និងបានផ្តល់នូវឯកសារជាច្រើនសម្រាប់ការស្រាវជ្រាវនេះ ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោកជំទាវ ខួន មករា** ជាសាស្ត្រាចារ្យណែនាំ ដែលលោកស្រីបានចំណាយពេលវេលាដ៏មានតម្លៃលះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីជួយណែនាំផ្តល់នូវដំបូន្មាន កែសម្រួល និងតម្រង់ទិសយើងខ្ញុំរហូតដល់សារណានេះទទួលបានជោគជ័យគួរជាទីមោទនៈនាពេលនេះ ។

ជាកិច្ចបញ្ចប់ យើងខ្ញុំសូមជូនពរដល់អស់លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានឲ្យជួបប្រទះតែសំណាងល្អ ទទួលបាននូវភាពជោគជ័យក្នុងជីវិត និងមានសុខភាពល្អ ជាពិសេសសូមឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើមុខវិជ្ជាដែលទាក់ទងនឹងផ្នែកនីតិវិធីរដ្ឋប្បវេណី ។ ហើយដោយបានសង្កេតឃើញថា ប្រជាពលរដ្ឋមួយចំនួនពុំសូវមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីនីតិវិធីនៃការធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ប៉ុន្មានទេ ។ ជាងនេះទៅទៀត ឯកសារដែលសរសេររៀបរាប់លម្អិតអំពីនីតិវិធីធ្វើបាស្រ័យទៅតុលាការជាន់ខ្ពស់ ជាពិសេសនីតិវិធីនៃបណ្ដឹងសាទុក្ខនេះឯងក៏ពុំសូវសម្បូរបែបប៉ុន្មាននោះទេ ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកស្រាវជ្រាវជំនាន់ក្រោយ ក៏ដូចជាតម្រូវការរបស់មិត្តអ្នកអាន ការស្រលាញ់ពេញចិត្តផ្ទាល់ខ្លួន ជាពិសេសដើម្បីទុក្ខជាឯកសារក្រោយពេលយើងបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ យើងក៏សម្រេចចិត្តកំណត់យកប្រធានបទស្តីពី "**នីតិវិធីបណ្ដឹងសាទុក្ខនៃរឿងក្ដីរដ្ឋប្បវេណី**" ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ គាក់តែងជាសារណានេះឡើង ។

យើងពិតជាមានមោទនៈភាពយ៉ាងខ្លាំងចំពោះស្នាដៃនេះ ដោយហេតុថាវាជាការស្រាវជ្រាវមួយដែលថ្មី ជាងនេះទៅទៀតយើងអាចបង្កើតជាស្នាដៃនេះឡើងខណៈពេលដែលយើងខ្ញុំគិតថាមានការលំបាកក្នុងការស្វែងរកឯកសារ និងសរសេរឲ្យគ្រប់តាមចំនួនកំណត់របស់សាកលវិទ្យាល័យ ។ ក្នុងស្នាដៃនេះយើងបានសរសេររៀបរាប់អំពីទ្រឹស្តីដែលមានចែងនៅក្នុងច្បាប់ សៀវភៅរបស់អ្នកនិពន្ធនានា និងឯកសាផ្សេងៗជាច្រើនទៀត និងបានឃើញការបង្ហាញអំពីការអនុវត្តជាក់ស្តែងតាមរយៈការចុះទៅស្រាវជ្រាវនៅតុលាការកំពូលដើម្បីយកឯកសារដែលពាក់ព័ន្ធយកមកធ្វើជាឧបសម្ព័ន្ធ ។ យើងមានការសង្ឃឹម និងជឿជាក់យ៉ាងមុតមាំក្នុងចិត្តថា ស្នាដៃនេះពិតជាអាចរួមចំណែកក្នុងការផ្ដល់នូវចំណេះដឹងផ្នែកច្បាប់ទៅដល់បងប្អូនប្រជាពលរដ្ឋ មិត្តអ្នកអាន សិស្ស និស្សិត អ្នកស្រាវជ្រាវជំនាន់ក្រោយ ហើយក៏ដើម្បីចូលរួមលើកស្ទួយវិស័យយុត្តិធម៌ និងនីតិរដ្ឋនៅកម្ពុជាឱ្យកាន់តែរីកចម្រើនមួយកម្រិតថែមទៀតដែរ ។

ជាចុងក្រោយនេះ យើងសូមការខន្តីអភ័យទោសទុកជាមុនអំពីសំណាក់ សិស្ស និស្សិត មិត្តអ្នកអាន សាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវ នូវរាល់កំហុសឆ្គងដែលកើតមានឡើងដោយ អចេតនាត្រង់ប្រកាណាមួយ តាមរយៈការប្រើប្រាស់ពាក្យពេចន៍មិនសមរម្យ ឬមិនត្រឹមត្រូវត្រង់ចំណុចណាមួយនៃស្នាដៃនេះ ។ យើងខ្ញុំរីករាយ និងទទួលយកនូវការរិះគន់ទាំងឡាយដើម្បីស្ថាបនាឱ្យការស្រាវជ្រាវកាន់តែល្អឡើងមួយកម្រិតថែមទៀត ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១ : សញ្ញាណទូទៅនៃបណ្តឹងសាទុក្ខ**

**១. ប្រវត្តិនៃបណ្តឹងសាទុក្ខ** ........................................ ៤

១.១. រចនាសម្ព័ន្ធតុលាការពីឆ្នាំ ១៩៣៧ ........................................ ៤

១.២. រចនាសម្ព័ន្ធតុលាការពីឆ្នាំ១៩៧០ ........................................ ៥

១.៣. រចនាសម្ព័ន្ធតុលាការពីឆ្នាំ១៩៧៥ ........................................ ៥

១.៤. រចនាសម្ព័ន្ធតុលាការពីឆ្នាំ១៩៧៩ ........................................ ៦

១.៥. រចនាសម្ព័ន្ធតុលាការពីឆ្នាំ១៩៩៣ ........................................ ៦

**២. រចនាសម្ព័ន្ធតុលាការកំពូលសម័យបច្ចុប្បន្ន** ........................................ ៧

ក.សមាសភាពតុលាការកំពូល ........................................ ៨

ខ.សមាសភាពសភាជំនាញ ........................................ ៨

គ.សភារដ្ឋប្បវេណី ........................................ ៩

ឃ.សភារួមក្រុម ........................................ ៩

ង.សភាពេញអង្គ ........................................ ៩

**៣. គោលបំណងនៃបណ្តឹងសាទុក្ខ** ........................................ ១០

**៤. ល័ក្ខខ័ណ្ឌនៃបណ្តឹងសាទុក្ខ** ........................................ ១១

៤.១. ល័ក្ខខ័ណ្ឌរយៈពេល ........................................ ១១

៤.១.១. រយៈពេលនៃបណ្តឹងសាទុក្ខ ........................................ ១១

៤.១.២. រយៈពេលដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ ........................................ ១២

៤.២. សេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបាន ........................................ ១២

**៥. មូលហេតុនៃបណ្តឹងសាទុក្ខ** ........................................ ១៣

៥.១.មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ ........................................ ១៤

៥.២.មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ ........................................ ១៤

## ជំពូកទី២ : នីតិវិធីនៃបណ្តឹងសាទុក្ខ


**១. របៀបធ្វើបណ្តឹងសាទុក្ខ** ........ ១៨
១.១. របៀបដាក់ពាក្យបណ្តឹងសាទុក្ខ ........ ១៨
១.២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងសាទុក្ខ ........ ១៨
១.៣. ការពិនិត្យពាក្យបណ្តឹង ........ ១៩
១.៤. ប្រាក់ប្រដាប់ក្តី ........ ១៩
១.៤.១.ពន្ធដាក់ពាក្យសុំ ........ ១៩
១.៤.២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ........ ២១
១.៤.៣. ប្រាក់ប្រដាប់ក្តីភាគី ........ ២២
១.៥. ការបញ្ជូន ........ ២២
១.៥.១. វិធីនៃការបញ្ជូន ........ ២៣
១.៥.១.១. ការបញ្ជូនដោយប្រគល់ ........ ២៣
ក. ការបញ្ជូនដោយជួបប្រទះ ........ ២៤
ខ. ការបញ្ជូនដោយបង្គ្រប់កិច្ច ........ ២៤
គ. ការបញ្ជូនដោយទុកចោល ........ ២៥
១.៥.១.២. ការបញ្ជូនទៅបរទេស ........ ២៥
១.៥.១.៣. ការបញ្ជូនតាមការផ្សាយជាសាធារណៈ ........ ២៦
ក.ល័ក្ខខ័ណ្ឌនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ ........ ២៦
ខ.របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ ........ ២៧
គ.អានុភាពនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ ........ ២៧
១.៥.២. របាយការណ៍នៃការបញ្ជូន ........ ២៧
**២. ប្រធាននៃបណ្តឹងសាទុក្ខ** ........ ២៩
២.១. តុលាការនៃបណ្តឹងសាទុក្ខ ........ ២៩
២.២. ភាគីនៃបណ្តឹងសាទុក្ខ ........ ២៩
២.៣. អ្នកតំណាង ........ ៣០
២.៣.១. អ្នកតំណាងដោយអាណត្តិ ........ ៣០
ក. លក្ខណសម្បត្តិរបស់អ្នកតំណាង ........ ៣០

ខ. សិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ ........ ៣១
២.៣.២. អ្នកតំណាងដែលច្បាប់បានកំណត់ ........ ៣១
២.៤. សហាបណ្តឹង ........ ៣៣
២.៤.១. ល័ក្ខខ័ណ្ឌនៃសហាបណ្តឹង ........ ៣៣
២.៤.២. ការជ្រើសរើសភាគី និងឋានៈនៃសហាបណ្តឹង ........ ៣៣
២.៥. អ្នកចូលរួមជួយអន្តរាគមន៍ ........ ៣៤
២.៥.១. សិទ្ធិអំណាចនៃអ្នកចូលរួមជួយអន្តរាគមន៍ ........ ៣៤
២.៥.២. អានុភាពសេចក្តីសម្រេចចំពោះអ្នកចូលរួមជួយអន្តរាគមន៍ ........ ៣៥
២.៥.៣. ការចូលរួមជួយអន្តរាគមន៍ និងសហាបណ្តឹង ........ ៣៥
**៣. អានុភាពនៃពាក្យបណ្តឹងសាទុក្ខ** ........ ៣៦
៣.១. អានុភាពបង្អាក់ការចូលជាស្ថាពរ ........ ៣៦
៣.២. ការផ្ទេរការជំនុំជម្រះក្តី ........ ៣៦
៣.៣. អានុភាពអវិភាគនៃបណ្តឹងសាទុក្ខ ........ ៣៦
**៤. បណ្តឹងសាទុក្ខបន្ទាប់បន្សំ** ........ ៣៧
**៥. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់** ........ ៣៨

## ជំពូកទី៣ : នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការបញ្ចប់បណ្តឹង

**ផ្នែកទី១ : នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់** ........ ៣៩
**១. ទំហំនៃការទាញហេតុផលដោយផ្ទាល់មាត់** ........ ៣៩
**២.នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់** ........ ៣៩
២.១. ការទាញហេតុផលដោយផ្ទាល់មាត់ ........ ៣៩
ក .សមាសភាពចៅក្រមជំនុំជម្រះ ........ ៣៩
ខ .សកម្មភាពនៃការទាញហេតុផលដោយផ្ទាល់មាត់ ........ ៤០
២.២. ការទាញហេតុផលដោយផ្ទាល់មាត់ ករណីមានបណ្តឹងសាទុក្ខលើកទី២ ........ ៤១
ក .សមាសភាពចៅក្រមជំនុំជម្រះ ........ ៤១
ខ .សកម្មភាពនៃការទាញហេតុផលដោយផ្ទាល់មាត់ ........ ៤២
**ផ្នែកទី២ : ការបញ្ចប់បណ្តឹងសាទុក្ខ** ........ ៤២
**១.ការបញ្ចប់បណ្តឹងដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ** ........ ៤២

១.១. ការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ ..................................................... ៤២
១.២. ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី..................................................... ៤៣
១.២.១. ការដកពាក្យបណ្តឹង..................................................... ៤៣
ក. លក្ខខណ្ឌចាំបាច់នៃការដកពាក្យបណ្តឹងសាទុក្ខ ..................................................... ៤៤
ខ. អានុភាពនៃការដកពាក្យបណ្តឹងសាទុក្ខ ..................................................... ៤៥
គ. ការសងពន្ធដាក់ពាក្យបណ្តឹង ..................................................... ៤៥
១.២.២. ការលះបង់ ឬការទទួលស្គាល់នូវការទាមទារ ..................................................... ៤៦
ក. និយមន័យ ..................................................... ៤៦
ខ. លក្ខខណ្ឌចាំបាច់នៃការលះបង់ ឬការទទួលស្គាល់នូវការទាមទារ..................................................... ៤៦
គ. អានុភាពនៃការលះបង់ ឬការទទួលស្គាល់នូវការទាមទារ ..................................................... ៤៦
១.២.៣. ការសះជាតាមផ្លូវបណ្តឹង ..................................................... ៤៧
ក. និយមន័យ ..................................................... ៤៧
ខ. លក្ខខណ្ឌចាំបាច់នៃការសះជាតាមផ្លូវបណ្តឹង..................................................... ៤៧
គ. វិធីសះជាតាមផ្លូវបណ្តឹង..................................................... ៤៨
ឃ. អានុភាពនៃការសះជា ..................................................... ៤៨
ឃ.១. អានុភាពបញ្ចប់បណ្តឹង ..................................................... ៤៨
ឃ-២ អានុភាពអនុវត្ត..................................................... ៤៨
ឃ-៣ អានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ..................................................... ៤៨
ង. បន្ទុកនៃប្រាក់ប្រដាប់ក្តី..................................................... ៤៩
**២. ការបញ្ចប់បណ្តឹងដោយសេចក្តីសម្រេចរបស់តុលាការ**..................................................... ៤៩
២.១. ដីកាលើកចោលបណ្តឹងសាទុក្ខ ..................................................... ៤៩
២.២. សាលដីកាចុងក្រោយ ..................................................... ៥០
២.២.១.សាលដីកាច្រានចោលបណ្តឹងសាទុក្ខ..................................................... ៥០
២.២.២ សាលដីកាទទួលស្គាល់បណ្តឹងសាទុក្ខ ..................................................... ៥០
ក. ការបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញ ..................................................... ៥១
ខ. ការផ្ទេររឿងក្តីទៅតុលាការផ្សេង..................................................... ៥១
គ.ការបដិសេធចោល ហើយធ្វើការវិនិច្ឆ័យដោយខ្លួនឯង..................................................... ៥២
**សេចក្តីសន្និដ្ឋាន**..................................................... ៥៣

**អនុសាសន៍** ........................................................................................................ ៥៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ចាប់តាំងពីពេលដែលប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងភ្លើងសង្គ្រាម អស់រយៈពេលជាច្រើនឆ្នាំកន្លងមកប្រព័ន្ធយុត្តិធម៌ក៏ត្រូវបានបំផ្លាញយ៉ាងដំណំ ។ ជាពិសេសនៅរបបកម្ពុជាប្រជាធិបតេយ្យប្រព័ន្ធយុត្តិធម៌ត្រូវបានបំផ្លាញទាំងស្រុង ។ ប្រជាពលរដ្ឋត្រូវរងនូវការកាប់សំលាប់ និងការរំលោភបំពានសិទ្ធិសេរីភាពដោយគ្មានការជំនុំជម្រះរកយុត្តិធម៌នោះទេ ជាងនេះទៅទៀតក្នុងរបបនេះគេមិនអនុញ្ញាតឱ្យមាននូវកម្មសិទ្ធិឯកជនឡើយ ។ ក្រោយឆ្នាំ១៩៧៩ ប្រព័ន្ធយុត្តិធម៌ក៏ពុំសូវមានការរីកចម្រើនអ្វីដែរ លុះអំឡុងឆ្នាំ១៩៩៣ មកដល់ពេលបច្ចុប្បន្ននេះយើងសង្កេតឃើញថា វិស័យុត្តិធម៌របស់ប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។ ដោយគិតចាប់តាំងពីឆ្នាំ១៩៩៣ មកប្រព័ន្ធតុលាការមានបែងចែកជាបីថ្នាក់គឺ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ តុលាការកំពូលគឺជាសាលាជម្រះក្តីចុងក្រោយបង្អស់ដែលមានសមត្ថកិច្ចជំនុំជម្រះក្តីលើគ្រប់រឿងក្តីទាំងអស់តាមរយៈការបង្កើតឱ្យមានសភាជំនាញតាមប្រភេទនៃរឿងក្តី ។ ក្នុងចំណោមសភាទាំងនោះ មានសភាផ្នែករដ្ឋប្បវេណីដែលទទួលបន្ទុកដោះស្រាយបណ្តឹងសាទុក្ខនៃរឿងក្តីរដ្ឋប្បវេណីដែលធ្វើឧបាស្រ័យពីតុលាការថ្នាក់ក្រោមមក ។

បើយើងនិយាយអំពីនីតិវិធីនៃការជំនុំជម្រះលើកទី១ ប្រហែលជាមានប្រជាជនភាគច្រើនអាចមានកាយល់ដឹងខ្លះ ប៉ុន្តែប្រសិនបើយើងសួរអំពីនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខនៃរឿងក្តីរដ្ឋប្បវេណីប្រហែលជាមិនមានប្រជាជនច្រើនប៉ុន្មានទេ ដែលអាចយល់ដឹងអំពីនីតិវិធីនេះ ។ មានប្រជាជនតិចណាស់ដែលបានដឹងថា ក្នុងរឿងក្តីរដ្ឋប្បវេណីនៅក្រោយពេលដែលសាលាឧទ្ធរណ៍បានចេញសាលដីកា បើខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចនោះដោយខ្លួនយល់ថាសេចក្តីសម្រេចនោះធ្វើឡើងដោយផ្ទុយច្បាប់ គេអាចដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការកំពូល ដើម្បីឱ្យតុលាការនេះ ធ្វើការជំនុំជម្រះតាមការទាមទាររបស់ខ្លួន ។ មានអ្នកខ្លះទៀតមិនបានដឹងផងថា អ្វីទៅជាបណ្តឹងសាទុក្ខ ។

ដោយសង្កេតឃើញថាមានបញ្ហាអសកម្មទាំងនេះហើយ ទើបជម្រុញទឹកចិត្តឱ្យយើងខ្ញុំលើកយកប្រធានបទស្តីពី **"នីតិវិធីបណ្តឹងសាទុក្ខនៃរឿងក្តីរដ្ឋប្បវេណី"** ដើម្បីយកមកធ្វើការពន្យល់ និងធ្វើការស្រាយបំភ្លឺ ។ ពេលដែលយើងធ្វើការលើកយកប្រធានបទស្តីពីនីតិវិធីបណ្តឹងសាទុក្ខនៃរឿងក្តីរដ្ឋប្បវេណីមកនិយាយនោះនឹងមានចម្ងល់ចោទឡើងថា៖

- តើអ្វីទៅជាបណ្តឹងសាទុក្ខ? អ្វីទៅជារឿងក្តីរដ្ឋប្បវេណី?

- តើដើម្បីធ្វើបណ្តឹងសាទុក្ខត្រូវធ្វើយ៉ាងដូចម្តេច?
- តើត្រូវមានមូលហេតុអ្វីខ្លះដើម្បីធ្វើបណ្តឹងសាទុក្ខ?
- តើនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខប្រព្រឹត្តទៅយ៉ាងណា?

ដោយសង្កេតឃើញថាប្រជាជនភាគច្រើន ក៏ដូចជាសិស្ស និស្សិតមួយចំនួន ពុំសូវមានការយល់ដឹងអំពីនីតិវិធីនៃបណ្តឹងសាទុក្ខនោះទេ ហេតុនេះហើយទើបបានជាយើងខ្ញុំសម្រេចកំណត់យកប្រធានបទស្តីពី **នីតិវិធីបណ្តឹងសាទុក្ខនៃរឿងក្តីរដ្ឋប្បវេណី** យកមកធ្វើការស្រាវជ្រាវ ដើម្បីដោះស្រាយចម្ងល់នេះជូនមហាជនក្នុងការសិក្សាស្រាវជ្រាវ ។ ជាងនេះទៅទៀតគឺដើម្បីបង្កើនចំណេះដឹង និងទុក្ខជាឯកសារសម្រាប់សិស្ស និស្សិតជំនាន់ក្រោយៗទៀតធ្វើការសិក្សា និងស្រាវជ្រាវបន្ថែមទៀត ។

រាល់នីតិវិធីដែលយើងខ្ញុំធ្វើការបកស្រាយក្នុងស្នាដៃនេះ មិនមានវិសាលភាពគ្របដណ្តប់ទៅលើនីតិវិធីបណ្តឹងសាទុក្ខនៃរឿងក្តីរដ្ឋប្បវេណីដែលធ្វើទៅតុលាការបរទេស ឬមួយក៏នីតិវិធីបណ្តឹងសាទុក្ខនៃរឿក្តីផ្នែករដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។ ពោលគឺក្នុងស្នាដៃនេះ យើងខ្ញុំផ្តោតសំខាន់តែទៅលើនីតិវិធីបណ្តឹងសាទុក្ខនៃរឿងក្តីផ្នែករដ្ឋប្បវេណីដែលធ្វើនៅក្នុងតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។

ស្នាដៃនេះពិតជាមានសារៈសំខាន់ ដើម្បីរួមចំណែកក្នុងការពង្រីកចំណេះដឹងផ្នែកច្បាប់ជូនដល់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ ជាពិសេសប្រជាជនកម្ពុជាដែលពុំសូវ ឬពុំមានការយល់ដឹងអំពីនីតិវិធីនៃការធ្វើបណ្តឹងសាទុក្ខ និងនីតិវិធីនៃការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណីនៅតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ យើងខ្ញុំជឿជាក់ថាស្នាដៃនេះនឹងអាចចូលរួមចំណែកលើកស្ទួយនីតិរដ្ឋនៅកម្ពុជាឱ្យកាន់តែប្រសើរឡើងមួយកម្រិតថែមទៀត តាមរយៈការចូលរួមចំណែកលើកស្ទួយវឌ្ឍនភាពនៃចំណេះដឹងផ្នែកច្បាប់ដល់ប្រជាជន ។

ដើម្បីចងក្រងបង្កើតជាស្នាដៃនេះឡើង យើងបានធ្វើការសិក្សាផ្នែកទ្រឹស្តីពីសាស្ត្រាចារ្យជាច្រើន ហើយយើងខ្ញុំបានចុះទៅធ្វើការស្រាវជ្រាវឯកសារនៅតុលាការកំពូល និងបានធ្វើការស្រាវជ្រាវឯកសារនៅតាមបណ្ណាល័យជាច្រើនកន្លែងដូចជា បណ្ណាល័យរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បណ្ណាល័យរបស់ព្រឹទ្ធសភា បណ្ណាល័យរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការជាដើម ។ ហើយធ្វើការប្រមែប្រមូលឯកសារដែលពាក់ព័ន្ធពីប្រភពទាំងនោះយកមកធ្វើការសិក្សា វិភាគ និងចងក្រងជាស្នាដៃនេះឡើង ។ ជាងនេះទៅទៀត យើងខ្ញុំក៏បានទៅចូលរួមស្តាប់និងកត់ត្រាអំពីដំណើរការនៃនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខនៃរឿក្តីផ្នែករដ្ឋប្បវេណីក្នុងសវនាការជាសាធារណៈរបស់តុលាការកំពូល ហើយក៏បានធ្វើការសាកសួរមន្ត្រីដែលបម្រើការនៅក្នុង

តុលាការកំពូលអំពីនីតិវិធីនៃការជំនុំជម្រះក្តីរបស់តុលាការកំពូលផងដែរ ។

សារណានេះត្រូវបានធ្វើការបែងចែកជា ៣ ជំពូក ដែល**ជំពូកទី១** និយាយអំពីសញ្ញាញទូទៅនៃបណ្តឹងសាទុក្ខ ។ ជំពូកទី១ ត្រូវបានបែងចែកជា ៥ ចំណុចទៀត គឺ ចំណុចទី១ យើងធ្វើការលើកឡើងត្រួសៗអំពីប្រវត្តិនៃបណ្តឹងសាទុក្ខ ចំណុចទី២ បង្ហាញអំពីរចនាសម្ព័ន្ធតុលាការកំពូលបច្ចុប្បន្ន រីឯចំណុចទី៣ និយាយអំពីគោលបំណងនៃបណ្តឹងសាទុក្ខ ចំណែកឯចំណុចទី៤ គឺល័ក្ខខ័ណ្ឌនៃបណ្តឹងសាទុក្ខ និងចំណុចទី៥ និយាយអំពីមូលហេតុនៃការធ្វើបណ្តឹងសាទុក្ខ ។ ចំណែកឯ **ជំពូកទី២** បង្ហាញអំពីនីតិវិធីនៃបណ្តឹងសាទុក្ខ ហើយត្រូវបានបែងចែកជា ៦ ចំណុចធំៗ គឺ ចំណុចទី១ របៀបធ្វើបណ្តឹងសាទុក្ខ ចំណុចទី២ ប្រធាននៃបណ្តឹងសាទុក្ខ ចំណុចទី៣ អានុភាពនៃបណ្តឹងសាទុក្ខ ចំណុចទី៤ ការដកពាក្យបណ្តឹងសាទុក្ខ ចំណុចទី៥ បណ្តឹងសាទុក្ខបន្ទាប់បន្សំ និងចំណុចទី៦ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ រីឯ **ជំពូកទី៣** និយាយអំពី នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការបញ្ចប់បណ្តឹង ដែលត្រូវបានបែងចែកជា ២ ផ្នែកគឺ ផ្នែកទី១ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងផ្នែកទី២ ការបញ្ចប់បណ្តឹង ។

# ជំពូកទី ១

# សញ្ញាណទូទៅ

# នៃបណ្តឹងសាទុក្ខ

# ជំពូកទី១ : សញ្ញាណទូទៅនៃបណ្ដឹងសាទុក្ខ

នៅក្នុងរឿងក្ដីរដ្ឋប្បវេណីបណ្ដឹងសាទុក្ខ គឺជាប្រភេទមួយនៃបណ្ដឹងឧបាស្រ័យទៅតុលាការកំពូល ចំពោះសាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី២ ដោយសាលាឧទ្ធរណ៍ ឬជាសាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី១ តាមបញ្ញត្តិច្បាប់ពិសេស ឬមួយក៏ជាសាលក្រមចុងក្រោយដែលបានជំនុំជម្រះលើកទី១ ដោយសាលាដំបូងក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍ ប៉ុន្តែរក្សាទុកនូវសិទ្ធិប្ដឹងសាទុក្ខ[1] ។

ចំពោះបណ្ដឹងរដ្ឋប្បវេណី គឺជាបណ្ដឹងដែលមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណីដោយផ្អែកលើច្បាប់ដើម្បីការពារបុគ្គលឯកជន[2] ។ ចំណែកឯនីតិរដ្ឋប្បវេណីវាជាច្បាប់សម្រាប់គ្រប់គ្រងទំនាក់ទំនងទាំងអស់របស់ពលរដ្ឋខាងផ្លូវឯកជន[3] ។

នីតិវិធីបណ្ដឹងសាទុក្ខនៃរឿងក្ដីរដ្ឋប្បវេណី គឺសិក្សាទៅលើលំហូនីតិវិធីនៃការធ្វើសកម្មភាពបណ្ដឹង និងការដោះស្រាយវិវាទរវាងបុគ្គលឯកជនតាមច្បាប់ដើម្បីគ្រប់គ្រងទំនាក់ទំនងទាំងអស់របស់ពលរដ្ឋខាងផ្លូវឯកជននៅតុលាការកំពូល ។

ដើម្បីយល់ដឹងឱ្យកាន់តែច្បាស់អំពីនីតិវិធីនេះ យើងសូមលើកយកប្រវត្តិនៃការដោះស្រាយបណ្ដឹងសាទុក្ខ និងតុលាការដែលទទួលបន្ទុកជំនុំជម្រះបណ្ដឹងនេះ យកមកធ្វើការសិក្សាត្រួសៗជាមុនសិន ។

## ១. ប្រវត្តិនៃបណ្ដឹងសាទុក្ខ

### ១.១. រចនាសម្ព័ន្ធតុលាការពីឆ្នាំ ១៩៣៧

ចាប់តាំងពីឆ្នាំ១៩៣៧ មកដល់ឆ្នាំ១៩៧០ នីតិវិធីនៃបណ្ដឹងត្រូវបានចាប់ផ្ដើមតាមរយៈការដាក់ពាក្យបណ្ដឹងដោយភាគីទៅសាលាលហុដែលមានចៅក្រមម្នាក់ទទួលបន្ទុកជំនុំជម្រះ[4] ។ ចំពោះសេចក្ដីសម្រេចរបស់សាលាលហុមានពីរប្រភេទគឺ សេចក្ដីសម្រេចមិនអាចធ្វើឧទ្ធរណ៍បាន និងសេចក្ដីសម្រេចដែលអាចធ្វើឧទ្ធរណ៍បាន[5] ។ ចំពោះសេក្ដីសម្រេចដែលអាចធ្វើឧទ្ធរណ៍បានគឺជាសេចក្ដី

[1] ទីស្ដីការគណៈរដ្ឋមន្ត្រី, *សន្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី* (បោះពុម្ពលើកទី១ ឆ្នាំ២០០៧) ចំណុចទី៧៩ ទំព័រទី៧១

[2] *កម្រងឯកសារបណ្ដុះបណ្ដាលមន្ត្រីសាធារណៈ: ស្ដីអំពីច្បាប់ និងសាលាជម្រះក្ដីកម្ពុជា* ទំព័រទី៨៩

[3] សាស្ត្រាចារ្យ ខាំ សុមករា, *នីតិរដ្ឋប្បវេណី* (បោះពុម្ពលើកទី២ ឆ្នាំ២០១២) ទំព័រទី២

[4] លោក កុយ នាម និង ឡុង បញ្ញារុធ, *អយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប* (បោះពុម្ពលើកទី១ ឆ្នាំ២០០៦) តារាងឧបសម្ព័ន្ធទី៦

[5] បើតាមវចនានុក្រមសម្ដេចសង្ឃរាជជួន ណាត *ឧទ្ធរណ៍* មានន័យថា ជាការរើឡើង ឬការរើសើ ឬការធ្វើជាថ្មីទៀត

សម្រេចដែលដាក់ទោសគុក ឬពិន័យលើសពី ៣រៀល និងជម្ងឺចិត្តលើសពី ៥រៀល ។ ការធ្វើឧទ្ធរណ៍គឺជាការធ្វើទៅសាលាមជ្ឈឹមនៅតាមបណ្តាខេត្ត និងក្រុងភ្នំពេញដែលមានចៅក្រម ០១ រូប និងព្រះរាជអាជ្ញា ០១ រូប ដែលធ្វើការសម្រេច ខ ច្បាប់ និងខរឿងហេតុ ។ នៅក្រោយពេលដែលសាលាមជ្ឈឹមបានចេញសេចក្តីសម្រេច បើភាគីដែលមិនសុខចិត្តអាចធ្វើពាក្យបណ្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍បាន ។ ចំពោះការជំនុំជម្រះរបស់សាលាឧទ្ធណ៍ត្រូវធ្វើឡើងដោយមាន ចៅក្រម ០៣ រូប និងព្រះរាជ្យបំរើ ០១ រូប ។ ប្រសិនបើមានភាគីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ភាគីនោះអាចប្តឹងទៅសាលាវិនិច្ឆ័យធិបតីដែលជាសាលាជំនុំជម្រះសេចក្តីចុងក្រោយគេ[6] ។ ចំពោះការវិនិច្ឆ័យរបស់សាលាវិនិច្ឆ័យធិបតីគឺគេពិនិត្យតែផ្លូវច្បាប់ប៉ុណ្ណោះដែលមានចាងហ្វាង ០១ រូប និងអមដោយចៅក្រមប្រឹក្សា ០២ រូប ។

ចំណែកឯសេចក្តីសម្រេចរបស់សាលាលហុដែលមិនអាចធ្វើឧទ្ធរណ៍បានភាគីអាចធ្វើការប្តឹងដោយផ្ទាល់មកសាលាវិនិច្ឆ័យធិបតីដោយមិនចាំបាច់ឆ្លងកាត់ សាលាមជ្ឈឹម និងសាលា ឧទ្ធរណ៍ទេ ។

### ១.២. រចនាសម្ព័ន្ធតុលាការពីឆ្នាំ១៩៧០

ទោះបីជានៅឆ្នាំ១៩៧០ មកដល់ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាមានការផ្លាស់ប្តូររបបដឹកនាំពីរបបរាជានិយមមកជារបបសាធារណៈរដ្ឋក៏ដោយ ក៏របបសាធារណៈរដ្ឋរបស់សេនាប្រមុខ លន់ នល់ មិនបានផ្លាស់ប្តូររចនាសម្ព័ន្ធរបស់តុលាការដែលបន្សល់ពីរបបរាជានិយមដែរ គឺរចនាសម្ព័ន្ធរបស់តុលាការត្រូវបានរក្សាទុកនៅដដែល ។

### ១.៣. រចនាសម្ព័ន្ធតុលាការពីឆ្នាំ១៩៧៥

បន្ទាប់ពីកំលាំងទ័ពរបស់ខ្មែរក្រហមបានផ្តួលរំលំរបបសាធារណៈរដ្ឋរបស់សេនាប្រមុខលន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបមួយនេះបានបំផ្លាញប្រព័ន្ធច្បាប់ និងប្រព័ន្ធតុលាការទាំងអស់គ្មានសេសសល់ ។ បើទោះបីជានៅក្នុងមាត្រា៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានបង្កើតឱ្យមាន "តុលាការប្រជាជន" ក្តីក៏គេមិនឃើញមានតុលាការដែរ[7] ។ ពាក្យថា តុលាការប្រជាជននេះត្រូវបានប្រើដោយកម្មាភិបាល ឬប្រជាពលរដ្ឋស្នូលរបស់ខ្មែរក្រហមដែលអាចប្រដូចទៅនឹងប្រព័ន្ធយុត្តិធម៌មួយដែលធ្វើអ្វីតាមទំនើងចិត្ត និងអមនុស្សធម៌ ។ ពាក្យនេះស្តាប់ទៅហាក់បីដូចជាត្រូវបានទទួលការវិនិច្ឆ័យសេចក្តីដោយប្រជាជន ប៉ុន្តែការពិតនោះគឺមិនមានប្រជាជនណាម្នាក់ជាអ្នកធ្វើការកាត់សេចក្តី

[6] *សាលាវិនិច្ឆ័យធិបតី* សមមូលនឹងតុលាការកំពូល បច្ចុប្បន្ន

[7] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ប្រកាសឲ្យប្រើ០៥ មករា ១៩៧៦, មាត្រា ៩ "*តុលាការ ជាតុលាការរបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ជាជន ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាពដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬដែលល្មើសនឹងច្បាប់ រដ្ឋរបស់ប្រជាជន តុលាការគ្រប់ជាន់ថ្នាក់ ត្រូវសភាតំណាងប្រជាជនជ្រើសរើស និងតែងតាំង*" ។

នោះទេ ។ គេសង្កេតឃើញកម្មាភិបាលដែលមានដូចជា ប្រធានភូមិ ប្រធានក្រុមប្រជាជនមូលដ្ឋាន ឬឈ្លបដែលជាអ្នកចោទប្រកាន់ថាអ្នកនេះ បានប្រព្រឹត្តិខុស ឬអ្នកនោះក្បត់អង្គការតែប៉ុណ្ណោះ[8] ។ ចំពោះបទល្មើសវិញគេឃើញថាបទប្បញ្ញត្តិមាត្រា១០ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានធ្វើការបែងចែកជាពីរប្រភេទតែប៉ុណ្ណោះ គឺត្រូវចាត់ទុកថាជាបទល្មើសទី១ ចំពោះប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋប្រជាជនត្រូវផ្តន្ទាទោសកំរិតខ្ពស់បំផុត ទី២ ចំពោះប្រភេទល្មើសក្រៅពីប្រភេទខាងលើ ហើយត្រូវអប់រំ កសាងក្នុងក្របខ័ណ្ឌអង្គការរដ្ឋ ឬក្នុងក្របខ័ណ្ឌអង្គការប្រជាជន ។

### ១.៤. រចនាសម្ព័ន្ធតុលាការពីឆ្នាំ១៩៧៩

ប្រព័ន្ធយុត្តិធម៌ដែលត្រូវបានបំផ្លិចបំផ្លាញ និងលុបបំបាត់ចោលទាំងស្រុងក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានចាប់ផ្តើមកសាងឡើងវិញនៅអំឡុងឆ្នាំ១៩៨២ នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានសម្រេចបង្កើតតុលាការប្រជាជនខេត្ត-ក្រុង ជាតុលាការដែលមានតែមួយថ្នាក់ប៉ុណ្ណោះ ។ ចំពោះតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលទើបតែត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូលដែលត្រូវបានប្រកាសឱ្យប្រើតាមក្រឹត្យលេខ២៨ក្រចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥ ។ បន្ទាប់មកនៅឆ្នាំ១៩៨៧ មានច្បាប់មួយទៀតពាក់ព័ន្ធនឹងតុលាការកំពូលនេះគឺ ក្រឹត្យច្បាប់លេខ៣៥ ស្តីពីការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល[9] ។

### ១.៥. រចនាសម្ព័ន្ធតុលាការពីឆ្នាំ១៩៩៣

អស់រយៈពេលជាច្រើនឆ្នាំដែលប្រព័ន្ធតុលាការត្រូវបានបំផ្លិចបំផ្លាញ ហើយក៏មិនមានបទប្បញ្ញត្តិច្បាប់ដែលធ្វើការកំណត់រចនាសម្ព័ន្ធតុលាការឱ្យមានលក្ខណៈស្តង់ដារជាលក្ខណៈសាកល សម្រាប់ការពារសិទ្ធិរបស់បុគ្គលឱ្យបានពេញលេញនៅឡើយទេ ។ រហូតមកដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៣ នាសម័យប្រជុំលើកទី២៤ នៃរដ្ឋសភា នីតិកាលទី១ រដ្ឋសភាបានធ្វើការអនុម័តច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ។ តាមរយៈច្បាប់នេះសាលាជម្រះក្តីនៅកម្ពុជាត្រូវបានគេបែងចែកជាពីរជាន់គឺ តុលាការជាន់ទាប និងតុលាការជាន់ខ្ពស់ ។ តុលាការជាន់ទាបរួមមាន តុលាការខេត្ត ក្រុង និងតុលាការយោធា ។ តុលាការខេត្ត ក្រុងមានទីតាំងនៅតាមខេត្ត ក្រុង និងមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃខេត្ត ក្រុងនោះទាំងមូល ។ ចំណែកឯតុលាការយោធាវិញ

---

[8] *ប្រជាជនមូលដ្ឋាន* ជាប្រជាជនដែលបានរស់នៅក្នុងតំបន់ត្រួតត្រាដោយខ្មែរក្រហមក្នុងពេលច្បាំងជាមួយរបបសាធារណរដ្ឋ

[9] គេហទំព័ររបស់តុលាការកំពូល និង មហាអយ្យការអមតុលាការកំពូល, http://www.supremecourt.gov.kh/index.php/km/about-us

មានទីតាំងនៅទីក្រុងភ្នំពេញតែមួយគត់ដែលមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីកម្ពុជាទាំងមូល[10] ។ ចំពោះតុលាជាន់ខ្ពស់វិញមានសាលាឧទ្ធរណ៍ និងតុលាការកំពូល ដែលមានសម្ថកិច្ចលាតសន្ធឹងលើដែនដីប្រទេសកម្ពុជាទាំងមូល[11] ។ ក្រៅពីការបែងចែកប្រព័ន្ធដោះស្រាយវិវាទបែបនេះ ក៏មានច្បាប់សម្រាប់កំណត់អំពីនីតិវិធីផងដែរគឺ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលត្រូវបានរដ្ឋសភាអនុម័តនាថ្ងៃទី ២៨ ខែមករា ឆ្នាំ១៩៩៣ គឺក្នុងពេលជាមួយគ្នានឹងច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ មានច្បាប់ ស្តីពីនីតិវិធីព្រហ្មទណ្ឌ បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាកា និងច្បាប់ព្រហ្មទណ្ឌសម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជាក្នុងសម័យអន្តរកាល (ដែលត្រូវបានគេហៅថា ច្បាប់ព្រហ្មទណ្ឌអន្តរកាល) សម្រាប់គ្រប់គ្រងវិស័យព្រហ្មទណ្ឌ ។ ចំពោះវិស័យរដ្ឋប្បវេណីវិញគេឃើញមានតែក្រឹត្យច្បាប់ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា(ក្រឹត្យច្បាប់លេខ៣៨) ដែលបន្សល់ទុកពីរបបមុនតែប៉ុណ្ណោះ ។ ចំពោះនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីវិញមិនមានច្បាប់ណាមួយដែលកំណត់ពីនីតិវិធីទេគឺ គេអនុវត្តដូចគ្នានឹងនីតិវិធីព្រហ្មទណ្ឌ ជាឧទាហរណ៍ កថាខណ្ឌទី១ មាត្រា២០៨ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ បានចង្អុលបង្ហាញថា "តុលាការកំពូលក្នុងពេលជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ **ក៏ដូចជារឿងរដ្ឋប្បវេណី**ត្រូវមានប្រធាននៃសាលាជំរះក្តីជាន់ខ្ពស់នេះ អមដោយចៅក្រម ០៤រូប តំណាងអយ្យការ ០១ រូប និងក្រឡាបញ្ជី ០១ រូប" ។ ហើយមានលិខិតបទដ្ឋានមួយចំនួនទៀតដែលទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណីដូចជា ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាស់ឲ្យប្រើដោយក្រឹត្យលេខ : ០៧ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ និងសារាចរលេខ : ០៤ សរច ៨៤ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៤ ស្តីពីសេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី ។ រហូតមកដល់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ទើបមានក្រមនីតិវិធីរដ្ឋប្បវេណីថ្មីមួយដែលត្រូវបានឡាយព្រះហស្តលេខាប្រកាស ឱ្យប្រើដោយព្រះបាទនរោត្តម សីហមុនី ។ នៅឆ្នាំ២០១៤ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការថ្មីមួយទៀតត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលចូលមកនិរាករណ៍ច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា[12] ។

## ២. រចនាសម្ព័ន្ធតុលាការកំពូលសម័យបច្ចុប្បន្ន

សម័យបច្ចុប្បន្នរចនាសម្ព័ន្ធតុលាការកំពូលត្រូវបានបែងចែកទៅតាមបញ្ញត្តិនៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ : នស/រកម/០៧១៤/

[10] ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា, លេខ ០៦ ក្រ, ០៨ កុម្ភៈ ១៩៩៣, មាត្រា១ និង ២

[11] ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា, លេខ ០៦ ក្រ, ០៨ កុម្ភៈ ១៩៩៣, មាត្រា៣

[12] ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ៩១

០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

**ក.សមាសភាពតុលាការកំពូល**

តុលាការកំពូលត្រូវគ្រប់គ្រង និងដឹកនាំដោយ ៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅតុលាការកំពូល[13] ។

ហើយតុលាការកំពូលត្រូវបង្កើតឱ្យមានសភាជំនាញផ្សេងៗពីគ្នា ដើម្បីបំពេញការងារទៅតាមវិស័យដែលជាជំនាញរបស់ខ្លួន មានដូចជា ៖

- សភាព្រហ្មទណ្ឌ
- សភារដ្ឋប្បវេណី
- សភាពាណិជ្ជកម្ម
- សភាការងារ ។

ប៉ុន្តែ ក្នុងករណីដែលចាំបាច់ សភាជំនាញផ្សេងៗទៀតរបស់តុលាការអាចត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ។ ក្រៅពីសភាជំនាញខាងលើនេះ នៅមានសភាចំនួនពីរទៀតដែលត្រូវបង្កើតឱ្យមានផងដែរគឺ សភាពេញអង្គ និងសភារួមក្រុម ។ សភានីមួយៗចេញសេចក្ដីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងនាមតុលាការកំពូល[14] ។

**ខ.សមាសភាពសភាជំនាញ**

សមាសភាពសភាជំនាញនីមួយៗនៃតុលាការកំពូលមាន ៖

- ប្រធានសភា
- ចៅក្រម
- ក្រឡាបញ្ជី ។

ប្រធានតុលាការកំពូលត្រូវចេញដីកាចាត់តាំង អនុប្រធានតុលាការកំពូលឱ្យទទួលបន្ទុកធ្វើជាប្រធានសភាទៅតាមជំនាញនីមួយៗ និងបទពិសោធន៍ការងារ ។ ប្រសិនបើខ្វះអនុប្រធាន ប្រធាន

[13] ច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ៥៦

[14] ច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤,មាត្រា ៥៧

តុលាការកំពូល អាចចាត់តាំងចៅក្រមណាម្នាក់ឱ្យធ្វើជាប្រធានសភាជំនាញណាមួយបាន ។ ចំពោះចំនួនចៅក្រម និងក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានតុលាការកំពូល[15] ។ ជាគោលការណ៍សភានីមួយៗនៃតុលាការកំពូលសម្រេចសេចក្តីដោយចៅក្រម ០៥ (ប្រាំ) រូប ដែលមានចៅក្រម ០១រូបធ្វើជាប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះនោះ[16] ប៉ុន្តែ ចំពោះសភាពេញអង្គ និងសភារួមក្រុមត្រូវជំនុំជម្រះដោយចៅក្រមយ៉ាងតិច ០៩(ប្រាំបួន) រូប ។

**គ.សភារដ្ឋប្បវេណី**

សភារដ្ឋប្បវេណី នៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលដីកា និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងរដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ព្រមទាំងលើបណ្តឹងសាទុក្ខ ចំពោះសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង និងរឿងក្តីផ្សេងៗទៀតដោយអនុវត្តតាមបទប្បញ្ញត្តិ ស្តីពីនីតិវិធីរដ្ឋប្បវេណី[17] ។

**ឃ.សភារួមក្រុម**

កាលណាមានវិវាទស្តីអំពីសមត្ថកិច្ច ឬវិវាទច្បាប់រវាងសភាច្រើនផ្សេងគ្នា ប្រធានតុលាការកំពូលអាចផ្តួចផ្តើមគំនិតដោយខ្លួនឯង ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយ ដើម្បីបង្កើតឱ្យមានសភារួមក្រុមឡើងដោយដីកាសម្រេច ។ មានន័យថានៅពេលដែលមានរឿងក្តីណាមួយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬបញ្ហានោះត្រូវបានដោះស្រាយដោយខ្វែងគំនិតគ្នានៅចំពោះមុខសភាផ្សេងគ្នានៃតុលាការកំពូលត្រូវបង្កើតសភារួមក្រុមឡើងដើម្បីសម្រេចអំពីបញ្ហានោះ ។ សភារួមក្រុមត្រូវមានសមាសភាពចៅក្រមយ៉ាងតិចចំនួន ០៩(ប្រាំបួន)រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាដែលពាក់ព័ន្ធនោះ ហើយត្រូវស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ។ ការប្រព្រឹត្តិទៅរបស់សភានេះ ត្រូវធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ។ ប្រធានតុលាការកំពូលចេញដីកាសម្រេច ដោយអនុលោមតាមសេចក្តីសម្រេចរបស់សភារួមក្រុម ។ សេចក្តីសម្រេចនេះ មានអំណាចបង្ខំឱ្យសភាទាំងអស់នៃតុលាការកំពូល និងតុលាការថ្នាក់ក្រោមគោរពតាម[18] ។

**ង.សភាពេញអង្គ**

ក្នុងករណីដែលមានបណ្តឹងសាទុក្ខលើកទី២ ចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ឬ

[15] ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ៥៨ មាត្រា ៦០

[16] ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ៥៩

[17] ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ៦៥

[18] ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ៦៣

បណ្តឹងជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬសាលដីកាស្ថាពរពីភាគី ឬពីព្រះមហាក្សត្រដែលជាប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តុលាការកំពូលត្រូវបង្កើតឱ្យមានសភាពេញអង្គ ដើម្បីដោះស្រាយបណ្តឹងនោះ ។ សភាពេញអង្គត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩(ប្រាំបួន)រូប ដែលមានតំណាងនៃសភាទាំងអស់របស់តុលាការកំពូល ។ ការប្រព្រឹត្តទៅនៃសភានេះ ត្រូវធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ហើយត្រូវស្ថិតក្រោមអធិបតីភាពប្រធានតុលាការកំពូល ។ សភាពេញអង្គចេញសេចក្តីសម្រេចក្នុងនាមតុលាការកំពូល[19] ។

## ៣. គោលបំណងនៃបណ្តឹងសាទុក្ខ

មនុស្សម្នាក់ៗតែងមានការយល់ឃើញ និងធ្វើការវិនិច្ឆ័យអំពីបញ្ហាអ្វីមួយផ្សេងៗគ្នា ពេលខ្លះអ្នកនោះអាចធ្វើការវិនិច្ឆ័យភ័ន្តច្រឡំក៏មាន ។ ហើយពេលខ្លះទៀតការវិនិច្ឆ័យនោះក៏អាចបណ្តាលឱ្យមាននូវចំណុចខ្វះចន្លោះផងដែរ ។ ពេលខ្លះចំពោះចៅក្រមដែលមានវិជ្ជាជីវៈផ្នែកច្បាប់ក៏ដោយក៏អាចធ្វើការវិនិច្ឆ័យលើរឿងក្តីណាមួយមានភាពខ្វះចន្លោះ ឬមានការភ័ន្តច្រឡំ ដែលអាចបណ្តាលឱ្យមានការសម្រេចសេចក្តីមិនត្រឹមត្រូវដើម្បីផ្តល់យុត្តិធម៌ទៅភាគី ។ ហេតុនេះហើយបានជាទាមទារឱ្យមានយន្តការនៃការត្រួតពិនិត្យ និងធ្វើការកែតម្រូវតាមរយៈការបង្កើតឱ្យមាននូវតុលាការដែលមានឋានានុក្រមខ្ពស់ជាង ដែលមានសិទ្ធិ និងអំណាចគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយសារការដាក់ពាក្យបណ្តឹងរបស់ភាគីដែលមិនពេញចិត្តនឹងសេចក្តីសម្រេចនោះ[20] ។ ម្យ៉ាងទៀត វាក៏ជាយន្តការមួយដើម្បីផ្តល់ទៅឱ្យភាគីនូវសិទ្ធិប្តឹងជំទាស់នឹងសេចក្តីសម្រេចនោះរហូតដល់ពេលដែលខ្លួនយល់ឃើញថា វាជាសេចក្តីសម្រេចដែលសមរម្យនិងអាចទទួលយកបាន ។ នៅក្នុងករណីដែលសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមនោះមិនត្រឹមត្រូវ តុលាការដែលមានឋានានុក្រមខ្ពស់ជាងនោះអាចធ្វើការកែប្រែ ឬលុបចោលសេចក្តីសម្រេចនោះបាន ។ ការបង្កើតឱ្យមាននីតិវិធីបែបនេះ គឺដើម្បីការពារភាគីដែលខាតបង់ផលប្រយោជន៍ពីការជំនុំជម្រះដែលមិនត្រឹមត្រូវនៅតុលាការថ្នាក់ក្រោម ។ ហើយសាលដីកានោះក៏ជាយុត្តិសាស្ត្រសម្រាប់តុលាការថ្នាក់ក្រោមធ្វើការអនុវត្តតាមផងដែរ វាជាយន្តការមួយសម្រាប់ធ្វើឱ្យមានការឯកភាពគ្នានូវចំណុចដែលខ្វែងគំនិត គ្នាក្នុងការអនុវត្តច្បាប់នៃតុលាការថ្នាក់ក្រោមជាច្រើនផ្សេងៗគ្នា ។

[19] ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ៦២

[20] ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ១១ កថាខណ្ឌទី៣

## ៤. ល័ក្ខខ័ណ្ឌនៃបណ្តឹងសាទុក្ខ

ជាគោលការណ៍ដើម្បីឱ្យបណ្តឹងមួយមានសុពលភាពទៅបាន លុះត្រាតែបណ្តឹងនោះបានធ្វើឡើងស្របទៅតាមល័ក្ខខ័ណ្ឌច្បាប់ដែលនៅជាធរមាន ។ ចំពោះបណ្តឹងសាទុក្ខវិញ ដើម្បីឱ្យដើមបណ្តឹងសាទុក្ខអាចធ្វើបណ្តឹងមានសុពលភាពទៅបាន លុះត្រាតែបណ្តឹងនោះត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌស្របច្បាប់នៃបណ្តឹងសាទុក្ខ ។ ល័ក្ខខ័ណ្ឌស្របច្បាប់នៃបណ្តឹងសាទុក្ខមានលក្ខខណ្ឌនៃរយៈពេល និងសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបាន ។

### ៤.១. ល័ក្ខខ័ណ្ឌរយៈពេល

ចំពោះល័ក្ខខ័ណ្ឌនៃរយៈពេលត្រូវបានបែងចែកជាពីរ គឺរយៈពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ និងរយៈពេលនៃការដាក់លិខិតបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខ ។

#### ៤.១.១. រយៈពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ

ដើម្បីដាក់ពាក្យបណ្តឹងសាទុក្ខបាន លុះត្រាតែភាគីនៃបណ្តឹងនោះបានធ្វើឡើងក្នុងអំឡុងពេលដែលច្បាប់បានកំណត់ ។ ចំពោះរយៈពេលនៃការធ្វើបណ្តឹងសាទុក្ខគឺមិនខុសគ្នាទៅនឹងរយៈពេលនៃបណ្តឹងឧទ្ធរណ៍នោះទេ គឺត្រូវធ្វើឡើងក្នុងអំឡុងពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬសាលដីកា ឬថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ[21] ។ មានន័យថានៅក្រោយពេលដែលភាគីបានទទួលការបញ្ជូននូវអនុសារសាលក្រមរបស់សាលាដំបូង ឬសាលដីការបស់សាលាឧទ្ធរណ៍ហើយ បើពិនិត្យឃើញថា សេចក្តីសម្រេចនោះធ្វើឡើងដោយមិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្ត ភាគីអាចធ្វើការប្តឹងជំទាស់ចំពោះសេចក្តីសម្រេចនោះក្នុងរយៈពេល ០១(មួយ) ខែ ។ បើភាគីមិនបានធ្វើការប្តឹងជំទាស់ក្នុងរយៈពេលនេះ សេចក្តីសម្រេចនោះនឹងចូលជាស្ថាពរដែលមានអានុភាពអនុវត្ត ដូច្នេះ ភាគីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចនោះនឹងបាត់បង់នូវសិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខនោះខ្លួនមិនអាចធ្វើបណ្តឹងសាទុក្ខបានឡើយ ។

ដូចគ្នាផងដែរក្នុងករណីដែលភាគីមិនបានធ្វើការប្តឹងសាទុក្ខក្នុងរយៈពេល ០១ខែ បន្ទាប់ពីបានទទួលការជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះភាគីនឹងបាត់បង់សិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខដូចគ្នាដែរ ។ ចំពោះដីកាសម្រេចនៅទីនេះ គឺសំដៅតែទៅលើសេក្តីសម្រេចដែលចេញដោយសាលាដំបូងដែលជាតុលាការនៃនីតិវិធីជំនុំជម្រះលើកទី១ ប៉ុណ្ណោះ ។ ហើយត្រូវបានធ្វើឡើងក្នុងករណីដែលភាគីមានការព្រមព្រៀងគ្នាជា

[21] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៦៤

លាយល័ក្ខណ៍អក្សរថាពួកគេនឹងមិនប្តឹងឧទ្ធរណ៍ តែរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ[22] ។ ហើយវាមិនមែនជាសេចក្តីសម្រេចដែលចេញដោយសាលាឧទ្ធរណ៍នោះទេ ព្រោះថាតុលាការសាលាឧទ្ធរណ៍មិនអាចចេញសាលក្រមកំបាំងមុខបានទេ[23] ។

### ៤.១.២. រយៈពេលដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ

ប្រសិនបើនៅពេលដាក់ពាក្យបណ្តឹង ដើមបណ្តឹងសាទុក្ខមិនបានសរសេរអំពីមូលហេតុនៃបណ្តឹងសាទុក្ខនៅក្នុងពាក្យបណ្តឹងនោះទេ នោះដើមបណ្តឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខទៅតុលាការនៃបណ្តឹងសាទុក្ខក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូនលិខិតទទួលពាក្យបណ្តឹង[24] ។

## ៤.២. សេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបាន

ចំពោះសេចក្តីសម្រេចដែលអាចបើកសិទ្ធិឱ្យភាគីអាចធ្វើបណ្តឹងសាទុក្ខបាន គឺត្រូវតែជាសេចក្តីសម្រេចដែលធ្វើឡើងដោយស្ថាប័នដែលមានសមត្ថកិច្ច និងមិនទាន់ចូលជាស្ថាពរ ។ បើយើងនិយាយអំពីស្ថាប័នដែលមានសមត្ថកិច្ចនៅទីនេះ គឺសំដៅតែទៅលើស្ថាប័នយុត្តាធិការដែលអាចចេញសេចក្តីសម្រេចហើយមានអានុភាពចាប់បង្ខំ ពោលគឺមានតែតុលាការសាលាដំបូង ឬសាលាឧទ្ធរណ៍តែប៉ុណ្ណោះ ដោយមិនសំដៅទៅលើសេចក្តីសម្រេចដែលចេញដោយមជ្ឈត្តករ ឬសេចក្តីសម្រេចដែលធ្វើឡើងដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលជាសេចក្តីសម្រេចក្រៅប្រព័ន្ធតុលាការ ឬដោយស្ថាប័នដទៃទៀតឡើយ ។

ចំពោះសេចក្តីសម្រេចដែលចេញដោយស្ថាប័នតុលាការនោះទៀតសោត ត្រូវតែជាសាលក្រមឬសាលដីកាចុងក្រោយ គឺមិនមែនជាសាលក្រមរបៀប ឬដីកាសម្រេច ឬសេចក្តីសម្រេចផ្សេងៗទៀតឡើយ ។ ចំពោះសាលក្រមរបៀបមិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ធ្វើបណ្តឹងសាទុក្ខដោយឯករាជ្យបានឡើយ ការប្តឹងត្រូវផ្អែកលើសាលក្រម ឬសាលដីកាចុងក្រោយ ។ ប្រសិនបើគេបានប្តឹងសាទុក្ខចំពោះសាលក្រមចុងក្រោយ ឬសាលដីកាចុងក្រោយ សាលក្រមរបៀបនោះក៏ជាកម្មវត្ថុនៃការវិនិច្ឆ័យជាមួយគ្នានៅតុលាការកំពូលផងដែរ[25] ។ ដូចគ្នានេះផងដែរចំពោះសេចក្តីសម្រេចលើ

---

[22] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៣ កថាខណ្ឌទី២

[23] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៧៣ វាក្យខ័ណ្ឌទី២ *បានហាមមិនឲ្យចេញសាលក្រមកំបាំងមុខឡើយ ។*

[24] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៨៩ កថាខណ្ឌទី១

[25] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា២៨៣ កថាខណ្ឌទី៦

បន្ទុកនៃប្រាក់ប្រដាប់ក្ដីដែលជាប់ជាមួយនឹងសាលក្រម ឬសាលដីកាចុងក្រោយក៏មិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ធ្វើបណ្ដឹងសាទុក្ខដោយឯករាជ្យតែឯងបានឡើយ[26] ។

ជាទូទៅនៅក្រោយពេលដែលសាលាដំបូងបានចេញសាលក្រម ភាគីដែលកើតទុក្ខមិនសុខចិត្តនឹងសាលក្រមនោះអាចធ្វើបណ្ដឹងឧទ្ធរណ៍បានតាមរយៈការដាក់ពាក្យបណ្ដឹងនៅសាលាដំបូងដែលចេញសាលក្រមនោះក្នុងអំឡុងពេល និងតាមនីតិវិធីដែលច្បាប់បានកំណត់ ។ ហើយប្រសិនបើនៅក្រោយពេលដែលសាលាឧទ្ធរណ៍បានចេញសាលដីកា ភាគីនៅតែមិនសុខចិត្តទៀត នោះភាគីអាចធ្វើបណ្ដឹងសាទុក្ខទៅតុលាការកំពូលដែលជាតុលាការនៃការជំនុំជម្រះចុងក្រោយ ។ ក៏ប៉ុន្ដែ មានករណីពិសេសប្រសិនបើភាគីមានការព្រមព្រៀងគ្នាថា មិនធ្វើបណ្ដឹងឧទ្ធរណ៍នៅក្រោយពេលដែលសាលាដំបូងចេញសាលក្រមតែរក្សាសិទ្ធិធ្វើបណ្ដឹងសាទុក្ខ ហើយបានធ្វើលិខិតជាលាយល័ក្ខណ៍អក្សរនោះភាគីអាចធ្វើបណ្ដឹងសាទុក្ខទៅតុលាការកំពូលតែម្ដង ដោយមិនចាំបាច់ឆ្លងកាត់សាលាឧទ្ធរណ៍ក៏បាន ។ ចំពោះការយល់ព្រមដើម្បីផ្លោះសាលាឧទ្ធរណ៍ទៅតុលាការកំពូលនេះ អាចធ្វើបានក្នុងករណីដែលជារឿងក្ដីផ្នែករដ្ឋប្បវេណី ឬពាណិជ្ជកម្មដែលតម្លៃកម្មវត្ថុនៃបណ្ដឹងមិនលើសពី ៥.០០០.០០០ (ប្រាំលាន) រៀល តែប៉ុណ្ណោះ[27] ។

## ៥. មូលហេតុនៃបណ្ដឹងសាទុក្ខ

ដើម្បីឱ្យតុលាការនៃបណ្ដឹងសាទុក្ខ សម្រេចធ្វើការជំនុំជម្រះទៅតាមពាក្យបណ្ដឹងរបស់ខ្លួនលុះត្រាតែក្នុងពាក្យបណ្ដឹងរបស់ដើមបណ្ដឹងសាទុក្ខនោះបានសរសេរនូវមូលហេតុត្រឹមត្រូវតាមបទ-ប្បញ្ញត្តិច្បាប់ ។ ប៉ុន្ដែ ប្រសិនបើនៅក្នុងពាក្យបណ្ដឹងសាទុក្ខនោះ មិនបានសរសេរនូវមូលហេតុនៃបណ្ដឹងសាទុក្ខទេ ដើមបណ្ដឹងសាទុក្ខត្រូវដាក់នូវលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខនោះទៅតុលាការនៃបណ្ដឹងសាទុក្ខនោះក្នុងរយៈពេលដែលច្បាប់បានកំណត់ ។ ផ្ទុយមកវិញ ប្រសិនបើក្នុងពាក្យបណ្ដឹងនោះមិនមានមូលហេតុនៃបណ្ដឹងសាទុក្ខទេ ហើយបើខ្លួនមិនបានដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខក្នុងពេលកំណត់ទេ តុលាការនៃបណ្ដឹងសាទុក្ខត្រូវច្រានចោលបណ្ដឹងសាទុក្ខនោះ[28] ។ ចំពោះមូលហេតុនៃបណ្ដឹងសាទុក្ខត្រូវបានបែងចែកជាពីរ គឺមូលហេតុទូទៅ និងមូលហេតុដាច់ខាត ។

[26] ក្រសួងយុត្តិធម៌, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា ២៨៦

[27] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៦០, មាត្រា២៨៣

[28] ក្រសួងយុត្តិធម៌, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា២៨៤

### ៥.១.មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ

ជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខធ្វើការវិនិច្ឆ័យតែលើអង្គច្បាប់ប៉ុណ្ណោះ ហេតុនេះហើយបានជាមាត្រា២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តអំពីមូលហេតុទូទៅនៃបណ្តឹងសាទុក្ខ បានអនុញ្ញាតអោយដើម បណ្តឹងសាទុក្ខអាចយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬសាលក្រម[29] ។ ដើមបណ្តឹងសាទុក្ខត្រូវសរសេរបញ្ជាក់អំពីបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្ត និងមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្តិនោះ ។ ហើយប្រសិនបើមូលហេតុនោះមានទំនាក់ទំនងជាមួយនឹងនីតិវិធីនៃបណ្តឹង ត្រូវសរសេរបញ្ជាក់អំពីអង្គហេតុដែលផ្ទុយនោះឱ្យបានច្បាស់លាស់ផងដែរ ។

### ៥.២.មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ

ជាទូទៅដើម្បីធ្វើបណ្តឹងសាទុក្ខបាន ដើមបណ្តឹងសាទុក្ខត្រូវយកមូលហេតុនៃការវិនិច្ឆ័យ ឬការសម្រេចសេចក្តីរបស់តុលាការសាលាដំបូង ឬសាលាឧទ្ធរណ៍ដែលបានធ្វើឡើងផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្តិនានា ដែលមានឥទ្ធិពលទៅលើសាលក្រម ឬសាលដីកានោះ ។ ក្នុងចំណោមមូលហេតុនៃភាពផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្តនេះផងដែរ ប្រសិនបើពិនិត្យឃើញថាមានកំហុសធ្ងន់ធ្ងរផ្នែកនីតិវិធី នោះដើមបណ្តឹងសាទុក្ខអាចយកមូលហេតុនេះ មកធ្វើជាមូលហេតុនៃបណ្តឹងសាទុក្ខបានជាដរាប ដោយពុំចាំបាច់ធ្វើការបញ្ជាក់អំពីឥទ្ធិពលនៃការបំពាននោះមកលើសាលក្រម ឬសាលដីកាដែលតុលាការចេញនោះក៏បាន ។ មូលហេតុដែលផ្ទុយនឹងនីតិវិធីនេះហៅថា "មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ" មូលហេតុទាំងនោះរួមមាន[30] ៖

**-តុលាការដែលចេញសាលក្រម ឬសាលដីកាមិនត្រូវបានចាត់តាំងស្របទៅតាមច្បាប់** ៖ ដូចជាករណីមានបញ្ហាអំពីចំនួនចៅក្រមនៃក្រុមប្រឹក្សាជំនុំជម្រះដែលធ្វើឡើងផ្ទុយនឹងបញ្ញត្តិនៃមាត្រា២៣ ឬករណីដែលចៅក្រមមិនត្រូវបានចាត់តាំងជាចៅក្រមជំនុំជម្រះតាមច្បាប់ដូចមានចែងក្នុងមាត្រា២៦ និងមាត្រា២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ជាដើម ។ ជាឧទាហរណ៍ រឿងក្តីដែលច្បាប់កំណត់ត្រូវធ្វើការវិនិច្ឆ័យដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម តែបែរជាត្រូវបានធ្វើការជំនុំជម្រះដោយចៅក្រមទោល ។ លើសពីនេះទៅទៀតចៅក្រមដែលធ្វើការជំនុំជម្រះនោះមិនត្រូវបានចាត់តាំងដោយប្រធានតុលាការ ហើយប្រពន្ធរបស់ចៅក្រមនោះ គឺជាភាគីនៅក្នុងរឿងក្តីនោះទៀតផង ។

**-ចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាបានចូលរួម** ៖ តាមច្បាប់មានតែចៅក្រមដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលជាមូលដ្ឋាននៃការ

[29] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៤

[30] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៥

ចេញសាលក្រម ឬសាលដីកាប៉ុណ្ណោះ ទើបអាចចេញសាលក្រម ឬសាលដីកាបាន[31] ។ តែក្នុងករណីចៅក្រមដែលមិនបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីជាមូលដ្ឋាននៃការចេញសាលក្រម ឬសាលដីកា បានចេញសាលក្រម ឬសាលដីកា នោះដើមបណ្តឹងសាទុក្ខអាចយកបញ្ហានេះធ្វើជាមូលហេតុនៃបណ្តឹងសាទុក្ខបាន ។ ករណីមួយផ្សេងទៀត ប្រសិនបើតុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកា ឬសាលក្រមដើម ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ។ ក្នុងករណីនេះ ចៅក្រមនៃតុលាការដើមដែលបានចេញសាលក្រម ឬសាលដីកាលើកមុននោះមិនអនុញ្ញាតឱ្យចូលរួមក្នុងការសម្រេចសេចក្តីនោះម្តងទៀតបានឡើយ[32] ។

**-ភាពផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ** : សមត្ថកិច្ចផ្តាច់មុខជាសមត្ថកិច្ចដែលកំណត់ដោយបញ្ញត្តិច្បាប់ ដោយមិនទទួលស្គាល់សមត្ថកិច្ចតុលាការផ្សេងទៀត ហើយក៏មិនអនុញ្ញាតឱ្យផ្តល់សមត្ថកិច្ចនេះទៅតុលាការណាមួយដោយឆន្ទៈរបស់ភាគីឡើយ[33] ។ ឧទាហរណ៍បណ្តឹងលែងលះគ្នា និងបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃបុត្តភាព ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬលំនៅឋាននាពេលដែលភាគីនោះទទួលមរណភាព[34] ។

**-ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្តឹង** : ជាទូទៅសិទ្ធិតំណាងក្នុងការធ្វើសកម្មភាពបណ្តឹងកើតមានតាមរយៈកិច្ចសន្យា និងការកំណត់ដោយច្បាប់ ។ ឧទាហរណ៍ថា "ក" បានធ្វើការអះអាងថាខ្លួនជាមេធាវីដែលតំណាងឱ្យចុងចម្លើយ "ខ" ដើម្បីធ្វើសកម្មភាពបណ្តឹងឧទ្ធរណ៍តែតាមការពិត "ខ" មិនបានប្រគល់សិទ្ធិតំណាងឱ្យ "ក" ទេ ឬមួយសិទ្ធិតំណាងដែល "ខ" បានប្រគល់ឱ្យ "ក" ដើម្បីធ្វើសកម្មភាពបណ្តឹងពីមុននោះបានរលត់បាត់ទៅហើយ រីឯ "ខ" ក៏មិនបានដឹងពីសកម្មភាពបណ្តឹងដែល "ក" បានធ្វើដែរ ។ ក្នុងករណីនេះ "ខ" អាចយកមូលហេតុនេះ ដើម្បីធ្វើជាមូលហេតុនៃបណ្តឹងសាទុក្ខបាន ។ ប៉ុន្តែ ប្រសិនបើនៅពេលក្រោយ "ខ" បានធ្វើសច្ចានុមតិលើសកម្មភាពនោះ "ខ" មិនអាចយកមូលហេតុនេះដើម្បីធ្វើបណ្តឹងសាទុក្ខបានឡើយ ។

**-ភាពផ្ទុយនឹងបញ្ញត្តិស្តីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ** : ជាទូទៅសវនាការត្រូវបើកជាសាធារណៈដែលអនុញ្ញាតឱ្យសាធារណៈជនអាចចូលស្តាប់បាន ។ ក៏ប៉ុន្តែ ក្នុង

---

[31] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨៥

[32] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៩៩

[33] មេធាវី អ៊ីវ ប៉ូលី, *មេរៀនសង្ខេបនីតិវិធីរដ្ឋប្បវេណី* (បោះពុម្ពលើកទី១ ឆ្នាំ២០១០), ទំព័រ១៧

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០

ករណីដែលតុលាការធ្វើជាអសាធារណៈដែលផ្ទុយនឹងបញ្ញត្តិមាត្រា១១៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះមានន័យថាផ្ទុយនឹងច្បាប់ ។

-**សាលក្រម ឬសាលដីកាគ្មានសំអាងហេតុ ឬមានសំអាងហេតុតែផ្ទុយនឹងគ្នា** : ក្នុងសាលក្រម ឬសាលដីកាត្រូវតែមានសំអាងហេតុ ហើយសំអាងហេតុនោះត្រូវតែស្របទៅនឹងសេចក្តីសម្រេចផងដែរ ។ ប្រសិនបើសំអាងហេតុនោះមិនគាំទ្រសេចក្តីសម្រេចទេនោះមានន័យថា សំអាងហេតុផ្ទុយគ្នា ។

# ជំពូកទី ២
# នីតិវិធីនៃបណ្តឹងសាទុក្ខ

# ជំពូកទី២ : នីតិវិធីនៃបណ្តឹងសាទុក្ខ

នីតិវិធីនៃបណ្តឹងសាទុក្ខមិនមានលក្ខណៈខុសគ្នាពីនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ប៉ុន្មានទេ បើយើងពិនិត្យមើលក្នុងបញ្ញត្តិមាត្រា២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចង្អុលបង្ហាញឱ្យយកបញ្ញត្តិជំពូកទី២ នៃគន្ថីទី៣ (បណ្តឹងឧទ្ធរណ៍) មកអនុវត្តដូចគ្នាចំពោះនីតិវិធីនៃបណ្តឹងសាទុក្ខ លើកលែងតែមានបញ្ញត្តិពិសេស ។ ចំពោះបញ្ញត្តិនៃបណ្តឹងឧទ្ធរណ៍ដែលត្រូវយកមកអនុវត្តដូចគ្នាក្នុងបណ្តឹងសាទុក្ខមានដូចជា[35]៖

- ការព្រមព្រៀងមិនប្តឹងឧទ្ធរណ៍ក្នុង កថាខណ្ឌទី១ ចំណុច **ក** នៃមាត្រា២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍)
- ការកម្រិតបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី នៃមាត្រា២៦១
- សេចក្តីសម្រេចដែលត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ នៃមាត្រា២៦២
- ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍ មាត្រា២៦៣
- អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ មាត្រា២៦៤
- កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា២៦៥ (របៀបប្តឹងឧទ្ធរណ៍)
- សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍ មាត្រា២៦៦
- ការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ មាត្រា២៦៧
- ការដកពាក្យបណ្តឹងឧទ្ធរណ៍មាត្រា២៦៩
- បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ មាត្រា២៧០
- កថាខណ្ឌទី១ នៃមាត្រា២៧២ (ទំហំនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍)
- ការអនុវត្តដូចគ្នាតាមបញ្ញត្តិ ស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី១ មាត្រា២៧៣ (តែក៏មានកម្រិតដោយហេតុថាបណ្តឹងសាទុក្ខជាបណ្តឹងដែលវិនិច្ឆ័យលើអង្គច្បាប់)
- កថាខណ្ឌទី១ នៃមាត្រា២៧៤ (អានុភាពនៃសកម្មភាពបណ្តឹងនៅក្នុងការជំនុំជម្រះលើកទី១ ជាអាទិ៍)
- កថាខណ្ឌទី២ នៃមាត្រា២៧៧ (ការច្រានចោលបណ្តឹងឧទ្ធរណ៍) និង
- ទំហំនៃការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី១ មាត្រា២៧៨

[35] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា ២៨៦

## ១. របៀបធ្វើបណ្តឹងសាទុក្ខ

នៅក្រោយពេលដែលតុលាការបានចេញសាលក្រម ឬសាលដីកាប្រសិនបើភាគីមិនសុខចិត្តនឹងសាលក្រម ឬសាលដីកាអាចធ្វើបណ្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចនោះបាន ។ បណ្តឹងសាទុក្ខត្រូវតែធ្វើឡើងដោយការដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរទៅតុលាការដែលបានចេញសាលក្រម ឬសាលដីកានោះ ។

### ១.១. របៀបដាក់ពាក្យបណ្តឹងសាទុក្ខ

ដើម្បីធ្វើបណ្តឹងសាទុក្ខភាគីដែលមិនសុខចិត្តនឹងសាលក្រម ឬសាលដីកាដែលតុលាការបានចេញនោះត្រូវសរសេរពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរ ហើយត្រូវយកពាក្យបណ្តឹងសាទុក្ខនោះទៅដាក់នៅតុលាការដែលបានចេញសាលក្រម ឬសាលដីកានោះក្នុងអំឡុងពេលកំណត់សម្រាប់ធ្វើបណ្តឹងសាទុក្ខ ។ បន្ទាប់មកតុលាការដើមត្រូវធ្វើការផ្ញើឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងសាទុក្ខនោះ និងសំណុំរឿងទៅតុលាការនៃបណ្តឹងសាទុក្ខ[36] ។

### ១.២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងសាទុក្ខ

ដើម្បីធ្វើបណ្តឹងសាទុក្ខទៅតុលាការ ដើមបណ្តឹងសាទុក្ខត្រូវតែសរសេរពាក្យបណ្តឹងសាទុក្ខជាលាយល័ក្ខណ៍អក្សរដាក់ទៅតុលាការដើម ភាគីមិនអាចធ្វើបណ្តឹងសាទុក្ខដោយផ្ទាល់មាត់ដូចនីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិចបានឡើយ ។ ចំពោះពាក្យបណ្តឹងត្រូវសរសេរនូវចំណុចមួយចំនួនដូចជា[37] ៖

ក.ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។ ការសរសេរឈ្មោះ និងអាសយដ្ឋានរបស់ភាគីពិតជាមានសារៈសំខាន់ណាស់ដើម្បីឱ្យតុលាការធ្វើការបញ្ជូនដីកាកោះ និងលិខិត ឬឯកសារផ្សេងៗទៅភាគីនោះ ។

ខ.សញ្ញាណនៃសាលក្រម ឬសាលដីកាចុងក្រោយដែលតុលាការដើមបានចេញនោះ និងសេចក្តីដែលប្តឹងសាទុក្ខនោះ ។ ការសរសេរបែបនេះ គឺចង្អុលបង្ហាញអំពីអ្វីដែលខ្លួនមិនសុខចិត្ត និងអ្វីដែលខ្លួនទាមទារ ដើម្បីឱ្យតុលាការយកមកធ្វើការវិនិច្ឆ័យ ដោយហេតុថាតុលាការមិនអាចធ្វើការវិនិច្ឆ័យនូវអ្វីដែលភាគីមិនបានធ្វើឧបាស្រ័យឡើយ "គោលការណ៍តុលាការអកម្ម" ។

គ.មូលហេតុនៃបណ្តឹងសាទុក្ខ វាជាចំណុចសំខាន់នៃពាក្យបណ្តឹងសាទុក្ខព្រោះតុលាការនៃបណ្តឹងសាទុក្ខវិនិច្ឆ័យទៅលើអង្គច្បាប់ ហេតុនេះពាក្យបណ្តឹងត្រូវសរសេរអំពីមូលហេតុនៃបណ្តឹងនោះ ។

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៧

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៦៥ កថាខណ្ឌទី២,៣

### ១.៣. ការពិនិត្យពាក្យបណ្តឹង

នៅក្រោយពេលដែលបានទទួលពាក្យបណ្តឹងសាទុក្ខពីតុលាការដើម តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការត្រួតពិនិត្យពាក្យបណ្តឹងនោះ ។ ក្នុងករណីដែលពិនិត្យឃើញថាពាក្យបណ្តឹងនោះមិនបានសរសេរនូវចំណុចដែលត្រូវសរសេរ ដែលបានរៀបរាប់ខាងលើនេះទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវកំណត់អំឡុងពេលសមរម្យមួយ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនោះ ។ ប្រសិនបើដើមបណ្តឹងសាទុក្ខមិនបានកែតម្រូវចំណុចខ្វះខាតនោះក្នុងរយៈពេលកំណត់ទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវលើកចោលពាក្យបណ្តឹងសាទុក្ខនោះដោយដីកាសម្រេច[38] ។ ប៉ុន្តែ ប្រសិនបើដើមបណ្តឹងសាទុក្ខមិនបានសរសេរអំពីមូលហេតុបណ្តឹងសាទុក្ខនៅក្នុងពាក្យបណ្តឹងទេ ដើមបណ្តឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់ អំពីមូលហេតុនៃបណ្តឹងសាទុក្ខក្នុងអំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីទទួលការបញ្ជូននូវលិខិតទទួលពាក្យបណ្តឹងសាទុក្ខនោះ[39] ។ ក្នុងករណីនេះផងដែរ ប្រសិនបើដើមបណ្តឹងសាទុក្ខមិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុក្នុងអំឡុងពេលនេះទេ ឬមួយក៏បានដាក់លិខិតបញ្ជាក់អំពីមូលហេតុ តែសរសេរមិនត្រឹមត្រូវតាមការកំណត់នៃមូលហេតុទូទៅនៃបណ្តឹងសាទុក្ខ ឬមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ នោះតុលាការនៃបណ្តឹងសាទុក្ខត្រូវលើកចោលបណ្តឹងសាទុក្ខនោះ[40] ។

### ១.៤. ប្រាក់ប្រដាប់ក្តី

ដើម្បីធ្វើបណ្តឹងទៅតុលាការបានត្រឹមត្រូវតាមច្បាប់ ហើយត្រូវបានតុលាការយកបណ្តឹងនោះមកធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តីតាមផ្លូវច្បាប់លុះត្រាតែដើមបណ្តឹងសាទុក្ខបានបង់ប្រាក់ប្រដាប់ក្តី ។ ប្រសិនបើដើមបណ្តឹងសាទុក្ខមិនបានធ្វើការបង់ប្រាក់ប្រដាប់ក្តីទេ បណ្តឹងនោះនឹងត្រូវតុលាការលើកចោលដោយដីកាសម្រេច ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីប្រាក់ប្រដាប់ក្តីត្រូវបានបែងចែកជា៣ ប្រភេទគឺ ពន្ធដាក់ពាក្យសុំ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងប្រាក់ប្រដាប់ក្តីភាគី ។

#### ១.៤.១.ពន្ធដាក់ពាក្យសុំ

ពន្ធដាក់ពាក្យសុំ ជាពន្ធដែលតុលាការតម្រូវឱ្យអ្នកដាក់ពាក្យសុំបង់ជាមុននៅពេលដែលដាក់ពាក្យសុំ ។ ពន្ធនេះអាចជាពន្ធនៃការដាក់ពាក្យបណ្តឹង ឬពន្ធដាក់ពាក្យសុំផ្សេងៗទៀតដែលទាក់ទងនឹងសកម្មភាពនៃបណ្តឹង[41] ។ ការបង់ពន្ធដាក់ពាក្យសុំត្រូវធ្វើឡើងដោយការបង់ជាប្រាក់នៅកន្លែងទទួលពាក្យនៃតុលាការនោះ ។ ពាក្យសុំដែលមិនបានបង់ពន្ធនៅពេលដាក់ពាក្យទេ ត្រូវចាត់

---

[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៦៦
[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៩
[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៩០
[41] មេធាវី អ៊ីវ ប៉ូលី, *មេរៀនសង្ខេបនីតិវិធីរដ្ឋប្បវេណី* (បោះពុម្ពលើកទី១ ឆ្នាំ២០១០), ទំព័រ២០

ទុកថាជាពាក្យសុំមិនស្របច្បាប់[42] ។

ប៉ុន្តែ ចំពោះបុគ្គលដែលគ្មានលទ្ធភាព ឬទ្រព្យធនសម្រាប់ការបង់ប្រាក់ដែលចាំបាច់ដើម្បីរៀបចំ និងប្រព្រឹត្តិទៅនីតិវិធីនៃបណ្តឹងបានទេ ឬក៏បុគ្គលដែលអាចមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាពដោយសារការបង់ប្រាក់នេះ តុលាការអាចចេញដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្តឹងតាមពាក្យសុំបាន ។ ការផ្តល់ជំនួយសង្គ្រោះអាចជាដីកាសម្រេចពន្យាពេលបង់ប្រាក់ប្រដាប់ក្តីតុលាការ ឬការអនុគ្រោះមិនបាច់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការតែម្តង ។ តែទោះជាយ៉ាងនេះក្តីប្រសិនបើអាចដឹងច្បាស់ថាគ្មានលទ្ធភាពនឹងឈ្នះក្តីសោះ តុលាការមិនអាចផ្តល់ជំនួយសង្គ្រោះលើបណ្តឹងបានឡើយ[43] ។ ការផ្តល់ជំនួយសង្គ្រោះលើបណ្តឹង គឺដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន និងគោរពនូវគោលការណ៍សិទ្ធិពឹងពាក់តុលាការរបស់បុគ្គលដែលមានជីវភាពក្រីក្រ ឬមានការលំបាកយ៉ាងខ្លាំងក្នុងការចិញ្ចឹមជីវិតដោយសារការបង់ប្រាក់នោះ ។

ពន្ធដាក់ពាក្យសុំត្រូវបានគេគណនាជាភាគតាមតម្លៃនៃកម្មវត្ថុនៃបណ្តឹងនោះ បើយោងតាមបញ្ញត្តិនៃមាត្រា៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីពន្ធត្រូវបានបែងចែកជា ៤ភាគ ដូចជា[44] ៖

| ម.៦១(១) | កម្មវត្ថុនៃបណ្តឹង(A) | រូបមន្តក្នុងការគណនា |
|---|---|---|
| ក | តិចជាង ឬស្មើនឹង ១០លានរៀល | $A \times 10/1{,}000$ |
| ខ | លើសពី ១០លានរៀល ដល់ ១០០លានរៀល | $100{,}000៛ + [(A - 10{,}000{,}000) \times 7/1{,}000]$ |
| គ | លើសពី ១០០លានរៀល ដល់ ១០០០លានរៀល | $730{,}000៛ + [(A - 100{,}000{,}000) \times 3/1{,}000]$ |
| ឃ | លើសពី ១០០០លានរៀល | $3{,}430{,}000៛ + [(A - 1{,}000{,}000{,}000) \times 1/1{,}000]$ |

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១ កថាខណ្ឌទី៧

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦៩

[44] រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សៀវភៅ ស្តីពី ការពន្យល់អំពីនីតិវិធីជម្រះក្តីលើកទី១* (បោះពុម្ពលើកទី២ ឆ្នាំ២០០៩), ទំព័រ១៣

ចំពោះរូបមន្តដែលបានបង្ហាញខាងលើនេះ ជារូបមន្តសម្រាប់គណនាតម្លៃពន្ធដាក់ពាក្យសុំនៃនីតិវិធីជំនុំជម្រះលើកទី១ ប៉ុណ្ណោះ ។ ចំណែកឯពន្ធដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ត្រូវបង់ ១,៥ ដងនៃតម្លៃដែលបានគណនាខាងលើ ចំពោះការគណនាតម្លៃនៃពន្ធដាក់ពាក្យបណ្ដឹងសាទុក្ខវិញត្រូវស្មើ ២ ដងនៃតម្លៃដែលគណនាឃើញខាងលើនេះ[45] ។ ឧទាហរណ៍កម្មវត្ថុនៃបណ្ដឹងមានចំនួន ១០.០០០.០០០ (ដប់លាន) រៀលនោះ ៖

- ពន្ធដាក់ពាក្យសុំនៅក្នុងនីតិវិធីជំនុំជម្រះលើកទី១
  $= 10{,}000{,}000 \times 10/1{,}000 = 100{,}000$ រៀល
- ពន្ធដាក់ពាក្យសុំនៅក្នុងនីតិវិធីបណ្ដឹងឧទ្ធរណ៍ $= 100{,}000$៛ $\times 1.5 = 150{,}000$រៀល
- ពន្ធដាក់ពាក្យសុំនៅក្នុងនីតិវិធីបណ្ដឹងសាទុក្ខ $= 100{,}000$៛ $\times 2 = 200{,}000$រៀល

### ១.៤.២. ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ ជាប្រាក់ប្រដាប់ក្ដីដែលភាគី ឬបុគ្គលដែលទាក់ទងទៅនឹងរឿងក្ដីត្រូវបង់ជាមុនទៅតាមការកំណត់របស់តុលាការសម្រាប់ការចំណាយរបស់តុលាការ ដើម្បីឱ្យតុលាការធ្វើសកម្មភាពតាមនីតិវិធី ។ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធមានដូចជា[46] ៖

- ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការធ្វើការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងៗទៀត ។
- ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និងស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតដែលប្រព្រឹត្តទៅនៅក្រៅតុលាការ ។

អ្នកដែលស្នើសុំឱ្យតុលាការធ្វើសកម្មភាពអ្វីមួយ (ដូចជាការពិនិត្យភស្តុតាង ឬការស្រាវជ្រាវអង្គហេតុ)ជាអ្នកបង់ប្រាក់ប្រដាប់ក្ដីនេះ ដើម្បីឱ្យតុលាការធ្វើសកម្មភាពតាមការស្នើសុំនោះ ។ ក្នុងករណីនេះ តុលាការត្រូវបង្គាប់ឱ្យអ្នកដាក់ពាក្យស្នើសុំនោះបង់ប្រាក់ប្រដាប់ក្ដីនេះជាមុន ។ ប្រសិនបើសាមីខ្លួនមិនបានបង់ជាមុនទេ នោះតុលាការអាចមិនធ្វើសកម្មភាពដែលចាំបាច់ត្រូវតែមានប្រាក់ប្រដាប់ក្ដីនោះបាន ។ រីឯប្រាក់ប្រដាប់ក្ដីសម្រាប់សកម្មភាពដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ តុលាការអាចកំណត់ឱ្យភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដី ជាអ្នកទទួលបន្ទុកក្នុងការបង់ប្រាក់ប្រដាប់ក្ដីនេះ ។

ក្នុងករណីដែលមិនបានបង់ប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធនេះជាមុនទេ តុលាការអាចប្រមូលពី

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១ កថាខណ្ឌទី៣
[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦២

អ្នកដែលត្រូវទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី[47] ។ ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីដែលចាញ់ក្តី ក្នុងករណីដែលភាគីចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗត្រូវទទួលខុសត្រូវដោយឆន្ទានុសិទ្ធិ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏តុលាការអាចសម្រេចឱ្យភាគីដែលឈ្នះក្តីទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីទាំងអស់ ឬមួយភាគបានដែរ ប្រសិនបើភាគីដែលឈ្នះក្តីនោះបានប្រព្រឹត្តសកម្មភាពបណ្តឹងណាមួយដែលមិនចាំបាច់ក្នុងការតទល់ ឬការការពារខ្លួន ឬបានធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ។ ចំពោះអ្នកធ្វើសហបណ្តឹងត្រូវទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីទៅតាមភាគស្មើៗគ្នា ។ ប៉ុន្តែតុលាការអាចសម្រេចទៅតាមកាលៈទេសៈឱ្យភាគីដែលធ្វើសហបណ្តឹងទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីដោយសាមគ្គី ឬឱ្យភាគីណាមួយដែលបានប្រព្រឹត្តសកម្មភាពបណ្តឹងណាដែលមិនចាំបាច់ក្នុងការតទល់ ឬការពារខ្លួនជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីច្រើនជាងភាគីដែលបានធ្វើសហបណ្តឹងផ្សេងទៀតបាន ។ ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងដោយអាណត្តិ ឬក្រឡាបញ្ជីបានធ្វើឱ្យចំនួនទឹកប្រាក់ប្រដាប់ក្តីដែលគ្មានប្រយោជន៍កើនឡើងដោយចេតនា ឬដោយកំហុសធ្ងន់ធ្ងររបស់ខ្លួន តុលាការដែលទទួលពាក្យបណ្តឹងអាចបង្គាប់ឱ្យអ្នកនោះសងនូវចំនួននៃប្រាក់ប្រដាប់ក្តីនោះវិញបាន ។ ការសម្រេចនេះ ត្រូវធ្វើដោយដីកាសម្រេចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន[48] ។

### ១.៤.៣. ប្រាក់ប្រដាប់ក្តីភាគី

ប្រាក់ប្រដាប់ក្តីភាគី គឺជាប្រាក់ប្រដាប់ក្តីដែលកំណត់ដោយតុលាការដោយពិចារណាលើលក្ខណៈនៃរឿងក្តី ឬលទ្ធភាពទ្រព្យធនរបស់ភាគីជាអាទិ៍ ។ ប្រាក់ប្រដាប់ក្តីភាគីមានដូចជា[49] ៖

- ថ្លៃធ្វើលិខិតមានដូចជា លិខិតពាក្យបណ្តឹង លិខិតពាក្យសុំផ្សេងៗទៀត ឬឯកសារផ្សេងៗដូចជា ឯកសារត្រៀមជាដើម និងថ្លៃដាក់ឯកសារនោះទៅតុលាការ ។
- សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងសោហ៊ុយស្នាក់នៅសម្រាប់ភាគី និងអ្នកតំណាង ដើម្បីបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ ។
- សោហ៊ុយផ្សេងៗទៀត ដែលតុលាការទទួលស្គាល់ថា ជាសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនូវនីតិវិធីបណ្តឹង ។

## ១.៥. ការបញ្ជូន

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹង

[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦២ កថាខណ្ឌទី៥

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦៤

[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦៣

អំពីខ្លឹមសារនៃឯកសារដែលត្រូវធ្វើការបញ្ជូនតាមផ្លូវបណ្តឹងចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ។ រីឯការជូនដំណឹង គឺជាវិធីដែលមានលក្ខណៈទូលាយ និងងាយស្រួលជាងវិធីនៃការបញ្ជូន ដោយហេតុថាការជូនដំណឹងមន្ត្រីប្រតិបត្តិការបញ្ជូនអាចប្រើគ្រប់មធ្យោបាយ (ដូចជា តាមទូរស័ព្ទ អ៊ីម៉ែល សំបុត្រជាដើម) ដើម្បីឱ្យអ្នកដែលត្រូវទទួលការបញ្ជូនបានដឹង ក្នុងនោះនីតិវិធីនៃការបញ្ជូនក៏ជាមធ្យោបាយមួយនៃការជូនដំណឹងផងដែរ ។

នៅក្រោយពេលដែលបានទទួលពាក្យបណ្តឹងពីតុលាការដើម តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការពិនិត្យពាក្យបណ្តឹងនោះ និងធ្វើការបញ្ជូនលិខិត ឬដីកា ឬក៏ឯកសារផ្សេងៗទៅភាគីតាមភាពចាំបាច់ដែលត្រូវធ្វើការបញ្ជូន ប្រសិនបើមិនចាំបាច់ទេតុលាការគ្រាន់តែធ្វើការជូនដំណឹងជាការគ្រប់គ្រាន់ ។ ចំពោះភាគីដែលត្រូវធ្វើការបញ្ជូននៅពេលនេះមានពីរគឺ ការបញ្ជូនទៅភាគីខាងដើមបណ្តឹងសាទុក្ខ និងការបញ្ជូនទៅភាគីខាងចុងបណ្តឹងសាទុក្ខ ។

បន្ទាប់ពីបានទទួលពាក្យបណ្តឹងសាទុក្ខ និងពិនិត្យឃើញថា ពាក្យបណ្តឹងនោះត្រឹមត្រូវតាមច្បាប់ហើយ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបញ្ជូននូវលិខិតទទួលពាក្យបណ្តឹងសាទុក្ខ និងដីកាកោះ ឬឯកសារផ្សេងទៀតទៅដើមបណ្តឹងសាទុក្ខ[50] ។ ប្រសិនបើពិនិត្យឃើញថាពាក្យបណ្តឹងនោះមិនត្រឹមត្រូវ ឬមិនបានសរសេរនូវចំណុចដែលត្រូវសរសេរតាមការកំណត់ដោយច្បាប់ នោះតុលាការត្រូវចេញដីកាបង្គាប់ឱ្យកែតម្រូវពាក្យបណ្តឹងនោះ ហើយត្រូវជូនដំណឹងទៅដើមបណ្តឹងសាទុក្ខ[51] ។

ពាក្យបណ្តឹងសាទុក្ខ និងដីកាកោះ ឬឯកសារផ្សេងៗទៀតក៏ត្រូវតែធ្វើការបញ្ជូនទៅចុងបណ្តឹងសាទុក្ខ ការកំណត់បែបនេះគឺដើម្បីធានានូវគោលការណ៍ចំពោះមុខដែលត្រូវធ្វើការកោះហៅភាគី និងធ្វើការសាកសួរមុនធ្វើការកាត់សេចក្តី[52] ។

### ១.៥.១. វិធីនៃការបញ្ជូន

ដើម្បីធ្វើការបញ្ជូនត្រឹមត្រូវតាមច្បាប់ លុះត្រាតែវិធីនៃការបញ្ជូននោះធ្វើឡើងស្របទៅតាមច្បាប់ ។ នៅក្នុងបញ្ញត្តិច្បាប់ វិធីនៃការបញ្ជូនមាន ៣ របៀបសំខាន់ៗគឺ ការបញ្ជូនដោយប្រគល់ ការបញ្ជូនទៅបរទេស និងការបញ្ជូនតាមការផ្សាយជាសាធារណៈ ។

#### ១.៥.១.១. ការបញ្ជូនដោយប្រគល់

ជាគោលការណ៍ការបញ្ជូនដោយប្រគល់ ត្រូវធ្វើឡើងដោយការប្រគល់នូវឯកសារដែលត្រូវ

[50] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៨

[51] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៦, ២៦៦ វាក្យខណ្ឌទី១ កថាខណ្ឌទី១

[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៦៧

ធ្វើការបញ្ជូនទៅឱ្យជនដែលត្រូវទទួលការបញ្ជូននោះ[53] ។ ហើយការប្រគល់នោះត្រូវធ្វើឡើងនៅលំនៅឋាន ឬទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូននោះ ។ ពាក្យថាលំនៅឋាន គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ក្នុងករណីដែលទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវចាត់ទុកជាលំនៅឋាន[54] ។ ចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់អាចធ្វើទៅនៅទីកន្លែងអាជីវកម្ម ឬទីស្នាក់ការ ឬលំនៅឋានរបស់អ្នកតំណាងនោះ ។

ទោះជាយ៉ាងនេះក្ដី ប្រសិនបើមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬជូនដំណឹងអំពីការផ្លាស់ប្ដូរទីកន្លែងនោះត្រូវធ្វើការបញ្ជូនទៅទីកន្លែងដែលបានជូនដំណឹងនោះ ។ ការជូនដំណឹងខាងលើនេះត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ក្នុងករណីដែលពាក្យបណ្ដឹងដែលបានបញ្ជាក់អំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬអ្នកដែលទទួលការបញ្ជូន ក៏ត្រូវចាត់ទុកថាភាគីបានជូនដំណឹងជាលាយល័ក្ខណ៍អក្សរអំពីទីកន្លែង[55] ។ ការជូនដំណឹងនេះត្រូវមានអានុភាពចាប់ពីពេលនីតិវិធីជំនុំជម្រះលើកទី១ រហូតដល់តុលាការជាន់ខ្ពស់លើកលែងតែមានការជូនដំណឹងអំពីការផ្លាស់ប្ដូរទីកន្លែងដែលត្រូវធ្វើការបញ្ជូន ។ ការបញ្ជូនដោយប្រគល់ត្រូវបានបែងចែកជា ៣ គឺ ការបញ្ជូនដោយជួបប្រទះ ការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល ។

ក. ការបញ្ជូនដោយជួបប្រទះ

ការបញ្ជូនដោយជួបប្រទះ ជាការប្រគល់នូវឯកសារដែលត្រូវធ្វើការបញ្ជូននោះ ទៅអ្នកដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលជួបប្រទះជននោះ ។ ជាគោលការណ៍ ការបញ្ជូនត្រូវធ្វើឡើងនៅទីកន្លែងដែលបានជូនដំណឹង ប៉ុន្តែប្រសិនបើជនដែលត្រូវទទួលការបញ្ជូននោះពុំច្បាស់លាស់ថាមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅទីកន្លែងដែលបានជួបប្រទះជននោះ ។ ការបញ្ជូនដោយជួបប្រទះនេះអាចធ្វើទៅបានក្នុងករណីដែលជននោះមិនបានប្រកែកទទួលការបញ្ជូននោះ[56] ។

ខ. ការបញ្ជូនដោយបង្គ្រប់កិច្ច

ការបញ្ជូនដោយបង្គ្រប់កិច្ច ជាការបញ្ជូនដោយប្រគល់នូវឯកសារដែលត្រូវធ្វើការបញ្ជូនទៅជនដទៃទៀតផ្សេងពីអ្នកដែលត្រូវទទួលការបញ្ជូន នៅកន្លែងដែលត្រូវទទួលការបញ្ជូននោះ ។

---

[53]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៧ កថាខណ្ឌទី

[54] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៩

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥០

[56] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥១

ក្នុងករណីដែលមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលត្រូវធ្វើការបញ្ជូនទេ នោះមន្ត្រីប្រតិបត្តិកិច្ចការបញ្ជូនអាចប្រគល់ឯកសារដែលត្រូវធ្វើការបញ្ជូនទៅអ្នកបម្រើ ឬអ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬអ្នកដែលនៅជាមួយដែលមានការយល់ដឹងសមរម្យក្នុងការទទួលការប្រគល់ឯកសារនោះបាន[57] ។ អ្នកដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារគឺជាអ្នកដែលអាចយល់ដឹងច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន និងអត្ថន័យនៃឯកសារដែលបានទទួល ហើយមានសមត្ថភាពអាចយកឯកសារនោះទៅប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូននោះ ។

គ. ការបញ្ជូនដោយទុកចោល

ការបញ្ជូនដោយទុកចោល ជាការបញ្ជូនដោយទុកឯកសារដែលត្រូវធ្វើការបញ្ជូននៅកន្លែងបញ្ជូននោះ ។ ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬអ្នកបម្រើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះ ឬអ្នកដែលនៅជាមួយដែលមានការយល់ដឹងសមរម្យបានប្រកែកមិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវមន្ត្រីប្រតិបត្តិកិច្ចការបញ្ជូនអាចទុកឯកសារនោះនៅកន្លែងដែលត្រូវបញ្ជូននោះបាន[58] ។

### ១.៥.១.២. ការបញ្ជូននៅបរទេស

ករណីជនដែលត្រូវទទួលការបញ្ជូនមានទីលំនៅ នៅបរទេស ហើយពុំមានទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការដែលអាចបញ្ជូនបាននៅក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនអាចធ្វើបានតាមវិធី ៖

- ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិបរទេស គប្បីបញ្ជូនដោយប្រគល់ឱ្យទៅក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន ។
- ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរ តែរស់នៅបរទេសគប្បីបញ្ជូនដោយប្រគល់ឱ្យឯកអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន ។

មុននឹងបញ្ជូនតុលាការគប្បីមើល សន្ធិសញ្ញា ឬអនុសញ្ញា ឬកិច្ចព្រមព្រៀងផ្សេងៗទៀតរវាងប្រទេសនោះ និងប្រទេសកម្ពុជាអំពីការជួយគ្នាផ្នែកច្បាប់ជាមុនសិន ព្រោះករណីខ្លះក្នុងលិខិតុបករណ៍អន្តរជាតិទាំងនោះមានចែងអំពីនីតិវិធីនៃការបញ្ជូន[59] ។

---

[57] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥២ កថាខណ្ឌទី១
[58] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥២ កថាខណ្ឌទី២
[59] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៣

### ១.៥.១.៣. ការបញ្ជូនតាមការផ្សាយជាសាធារណៈ

ការបញ្ជូនតាមការផ្សាយជាសាធារណៈអាចធ្វើឡើងដោយការបិទប្រកាសនៅកន្លែងបិទប្រកាសរបស់តុលាការ ឬកន្លែងដែលតុលាការទទួលស្គាល់ថាសមស្រប អាចជាប៉ុស្តិ៍នគរបាលសាលាឃុំ ឬសាលាសង្កាត់ជាដើម ដែលត្រូវប្រកាសថាក្រឡាបញ្ជីជាអ្នករក្សាទុកនូវឯកសារដែលត្រូវធ្វើការបញ្ជូន ហើយអាចប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូននោះនៅពេលណាក៏បាន(ក្នុងម៉ោងធ្វើការ) ។

ក.ល័ក្ខខ័ណ្ឌនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ

ដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបានលុះត្រាតែមានល័ក្ខខ័ណ្ឌដូចខាងក្រោម[60]៖

- ទោះបីប្រឹងប្រែងស្រាវជ្រាវរកលំនៅឋាន ឬទីសំណាក់របស់ភាគី ឬទីកន្លែងផ្សេងទៀតយ៉ាងណាក៏មិនអាចរកឃើញ ។
- ដឹងពីទីកន្លែងដែលត្រូវបញ្ជូន ប៉ុន្តែការបញ្ជូនមិនអាចធ្វើបានទោះជាព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលក៏ដោយ ។
- តុលាការមិនអាចធ្វើការបញ្ជូនទៅបរទេសដោយប្រគល់កិច្ចការបញ្ជូននោះ ។
- តុលាការមិនបានទទួលលិខិតបញ្ជាក់ ពីការបញ្ជូនពីក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសក្នុងអំឡុងពេល ៦ខែ ចាប់ពីពេលបញ្ជូននោះ ។
- មានពាក្យសុំពីភាគី ដែលស្នើសុំឱ្យតុលាការធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ហើយត្រូវបានតុលាការអនុញ្ញាត ។ ប៉ុន្តែដើម្បីជៀសវាងការយឺតយ៉ាវ តុលាការក៏អាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិបាន ទោះបីជាគ្មានពាក្យសុំក៏ដោយ ។

ចំពោះការបញ្ជូនជាលើកទី២ តាមការផ្សាយជាសាធារណៈទៅភាគីដដែល ត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិ[61] ។ ប្រសិនបើធ្លាប់បានបញ្ជូនទៅភាគីណាមួយតាមការបញ្ជូនតាមការផ្សាយជាសាធារណៈ នោះការបញ្ជូនលើកក្រោយៗទៀតតុលាការអាចសម្រេចធ្វើការបញ្ជូនតាម វិធីផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិ ។ ប៉ុន្តែ ចំពោះការបញ្ជូនទៅបរទេសត្រូវតែមានពាក្យសុំរបស់ភាគីរាល់លើកនៃការផ្សាយជាសារធារណៈ ។ ឧទាហរណ៍ ៖ ប្រសិនបើនៅនីតិវិធីជំនុំជម្រះលើកទី១ និងនីតិវិធីជំនុំជម្រះបណ្តឹងឧទ្ធរណ៍តុលាការបានធ្វើការបញ្ជូនទៅលោក "ក" ដោយវិធីនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ ។ នោះនៅក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខតុលាការអាចធ្វើការបញ្ជូន

---

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៥

[61] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៥ កថាខណ្ឌទី៤

តាមការផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិមិនចាំបាច់មានពាក្យសុំពីភាគីឡើយ ។ ប៉ុន្តែ ប្រសិនបើលោក "ក" រស់នៅបរទេសត្រូវតែមានពាក្យសុំពីភាគីទើបអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន ។

ខ.របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ

ការបញ្ជូនតាមការផ្សាយជាសាធារណៈត្រូវធ្វើឡើងតាមវិធីដូចតទៅ[62] ៖

- ក្រឡាបញ្ជីត្រូវបិទប្រកាសនៅកន្លែងបិទប្រកាសរបស់តុលាការ ឬកន្លែងដែលតុលាការទទួលស្គាល់ថាសមរម្យ ត្រូវប្រកាសថា ក្រឡាបញ្ជីរក្សាទុកនូវឯកសារដែលត្រូវធ្វើការបញ្ជូន និងអាចប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូននោះនៅពេលណាក៏បាន ។
- ចំពោះការបញ្ជូនដីកាកោះ ត្រូវបិទដីកាកោះនោះនៅកន្លែងសម្រាប់បិទប្រកាសតែម្តង ។
- តុលាការអាចចុះក្នុងរាជកិច្ច ឬក្នុងសារព័ត៌មានដោយផ្សាយថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ។
- ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដែលត្រូវធ្វើនៅបរទេស ក្រឡាបញ្ជីមិនចាំបាច់ផ្សាយក្នុងរាជកិច្ច ឬសារព័ត៌មានក៏បាន ដោយគ្រាន់តែជូនដំណឹងថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈរួចហើយ ។

គ.អានុភាពនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ

ការបញ្ជូនតាមការផ្សាយជាសាធារណៈនឹងមានអានុភាពនៅក្រោយអំឡុងពេល ២សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានបានបិទប្រកាសនោះ ។ ក៏ប៉ុន្តែ ការបញ្ជូនតាមការផ្សាយជាសាធារណៈជាលើកទី២ នឹងមានអានុភាពនៅថ្ងៃបន្ទាប់នៃថ្ងៃបិទប្រកាសនោះ ។ អានុភាពនៅទីនេះមានន័យថា ការបញ្ជូនមានសុពលភាព ហើយត្រូវចាត់ទុកថា អ្នកដែលត្រូវទទួលការបញ្ជូនបានទទួលការបញ្ជូននោះ ។ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដែលត្រូវធ្វើនៅបរទេសនឹងមានអានុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ៦សប្តាហ៍បន្ទាប់ពីថ្ងៃបិទប្រកាស់[63] ។

### ១.៥.២. របាយការណ៍នៃការបញ្ជូន

នៅក្រោយពេលដែលបានប្រតិបត្តិកិច្ចការបញ្ជូនត្រឹមត្រូវតាមនីតិវិធីរួចរាល់ហើយ មន្ត្រីប្រតិបត្តិការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីការបញ្ជូននោះ ហើយផ្ញើទៅតុលាការ ។ របាយការណ៍នៃការបញ្ជូនត្រូវតែសរសេរនូវចំណុចដូចជា[64] ៖

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៦

[63] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៧

[64] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៤

- សញ្ញាណនៃរឿងក្តី និងឯកសារដែលបានធ្វើការបញ្ជូន : ត្រូវសរសេរអំពីឈ្មោះសំណុំរឿង លេខ និងកាលបរិច្ឆេទដែលបានចុះ ហើយក៏ត្រូវសរសេរពាយឈ្មោះឯកសារដែលបានធ្វើការបញ្ជូននោះផងដែរ ។
- ឈ្មោះជនដែលត្រូវទទួលការបញ្ជូន : ដោយហេតុថាឯកសារនៃការបញ្ជូនត្រូវធ្វើទៅចំពោះបុគ្គលណាមួយច្បាស់លាស់ហេតុនេះហើយ ត្រូវសរសេរចង្អុលបង្ហាញឱ្យចំឈ្មោះអ្នកដែលត្រូវទទួលការបញ្ជូននោះ ។
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន ។
- វិធីនៃការបញ្ជូន : នៅក្រោយពេលដែលបានធ្វើការបញ្ជូនមន្ត្រីប្រតិបត្តិការបញ្ជូនត្រូវសរសេរចង្អុលប្រាប់ពីវិធីដែលខ្លួនបានបញ្ជូនតាមវិធីដូចជា បញ្ជូនដោយជួបប្រទះ ឬទុកចោលជាដើម ។
- ចំណាត់ការរបស់មន្ត្រីប្រតិបត្តិការបញ្ជូន ក្នុងករណីដែលជនដែលត្រូវទទួលការបញ្ជូនមិនចេះអក្សរ : ត្រូវសរសេរបញ្ជាក់ថា ខ្លួនបានអានឱ្យជននោះស្តាប់ និងបានពន្យល់ ។
- ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដែលបានទទួលឯកសារ : ការធ្វើបែបនេះ គឺដើម្បីបង្ការការប្រកែកថាខ្លួនមិនបានទទួលឯកសារដែលនាំឱ្យបាត់បង់ឯកសារ ហើយក៏ជាការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបញ្ជូនផងដែរ ។
- ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូន ជនដែលត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារបញ្ជូនដោយបង្គ្រប់កិច្ច ប្រកែកមិនព្រមទទួល : ក្នុងករណីដែលជនដែលត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារបញ្ជូនដោយបង្គ្រប់កិច្ចប្រកែកមិនព្រមទទួលត្រូវសរសេរអំពីមូលហេតុនៃការប្រកែកនោះ ។
- ហេតុការណ៍ នៅក្នុងករណីដែលបានធ្វើការបញ្ជូនដោយបង្គ្រប់កិច្ច ឬបញ្ជូនដោយទុកចោល : ត្រូវសរសេរអំពីមូលហេតុដែលធ្វើការបញ្ជូនតាមការបញ្ជូនដោយបង្គ្រប់កិច្ច ឬការបញ្ជូនដោយទុកចោល ។
- ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន ។

ក្នុងករណីដែលបានព្យាយាមធ្វើការបញ្ជូនតែមិនអាចសម្រេចបាន មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីហេតុការណ៍នោះ និងសរសេរអំពីវិធីនៃការបញ្ជូន និងចុះហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន ហើយដាក់ជូនទៅតុលាការ ។

## ២. ប្រធាននៃបណ្តឹងសាទុក្ខ

ដើម្បីឱ្យបណ្តឹងសាទុក្ខមានចលនា លុះត្រាតែមានការចូលរួមធ្វើសកម្មភាពបណ្តឹងដោយបុគ្គលដែលពាក់ព័ន្ធក្នុងបណ្តឹង ។ បុគ្គលដែលចូលរួមធ្វើសកម្មភាព ដើម្បីឱ្យបណ្តឹងមានចលនា ហៅថាប្រធាននៃបណ្តឹងសាទុក្ខ ។ ប្រធាននៃបណ្តឹងសាទុក្ខរួមមាន តុលាការ ភាគី អ្នកតំណាង អ្នកចូលរួមអន្តរាគមន៍ និងសហបណ្តឹង ។

### ២.១. តុលាការនៃបណ្តឹងសាទុក្ខ

ក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខមានតែតុលាការកំពូលតែមួយគត់ គឺជាប្រធាននៃនីតិវិធីដែលអនុវត្តអំណាចរបស់ខ្លួនតាមរយៈការប្រើប្រាស់សិទ្ធិដឹកនាំនីតិវិធីនៃបណ្តឹង ។

### ២.២. ភាគីនៃបណ្តឹងសាទុក្ខ

ភាគីជាជនដែលទាមទារនូវសាលដីកាក្នុងនាមខ្លួន ដើម្បីដោះស្រាយវិវាទព្រមទាំងជនដែលត្រូវបានចង្អុលឈ្មោះនៅក្នុងសាលដីកានោះ ក្នុងនាមភាគីម្ខាងទៀត ។ ភាគីនៅក្នុងនីតិវិធីជំនុំជម្រះលើកទី១ ត្រូវបានគេហៅថា ដើមចោទ និងចុងចម្លើយ រីឯនៅក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ត្រូវបានគេហៅថា ដើមបណ្តឹងឧទ្ធរណ៍ និងចុងបណ្តឹងឧទ្ធរណ៍ ចំណែកឯនៅក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខត្រូវបានគេហៅថា ដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខ ។

រឿងក្តីរដ្ឋប្បវេណី ជារបបមួយដែលដោះស្រាយវិវាទរវាងបុគ្គលឯកជនតាមរយៈការកំណត់ជាស្ថាពរនូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងកាតព្វកិច្ច ឬទំនាក់ទំនងគតិយុត្តតាមផ្លូវនីតិឯកជន ។ ហេតុនេះ ដើម្បីឱ្យភាគីអាចក្លាយជាប្រធាននៃបណ្តឹងសាទុក្ខ ហើយអាចធ្វើសកម្មភាពនៃបណ្តឹងសាទុក្ខមានសុពលភាពបានលុះត្រាតែជននោះជានីតិជនពេញសមត្ថភាព គឺមិនមែនជាអនីតិជន ឬជនដែលត្រូវបានកម្រិតសមត្ថភាពនោះទេ ។ ទោះជាយ៉ាងនេះក្តី មិនមានការរារាំងចំពោះអនីតិជនដែលអាចធ្វើសកម្មភាពដោយឯករាជ្យ ដែលទទួលសិទ្ធិតាមក្រមរដ្ឋប្បវេណីដើម្បីក្លាយជាបុគ្គលមានសមត្ថភាពជាភាគីតាមផ្លូវបណ្តឹងទេ ដូចជា អនីតិជនដែលត្រូវបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្ម អនីតិជនដែលទទួលបានអត្តាធីនភាពជាដើម[65] ។ ការកំណត់អំពីសមត្ថភាពដើម្បីក្លាយជាភាគីបែបនេះគឺមិនរំលោភទៅលើសិទ្ធិរបស់អនីតិជន ឬជនដែលត្រូវបានកម្រិតសមត្ថភាពឡើយ ដោយហេតុថាច្បាប់បានអនុញ្ញាតឱ្យជនទាំងនេះអាចធ្វើសកម្មភាពបណ្តឹងតាមរយៈអ្នកតំណាងរបស់ខ្លួន[66] ។

---

[65] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២០ និងមាត្រា ២២

[66] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី៣

## ២.៣. អ្នកតំណាង

ការធ្វើសកម្មភាពនៃបណ្តឹងសាទុក្ខភាគីអាចធ្វើសកម្មភាពនេះដោយខ្លួនឯងផ្ទាល់ ឬតាមរយៈអ្នកតំណាង ។ របបតំណាងជារបបមួយដែលអ្នកតំណាងតាមផ្លូវបណ្តឹងជាអ្នកធ្វើសកម្មភាពបណ្តឹង ឬទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ ឬរបស់ភាគីម្ខាងទៀត ដោយផ្អែកលើឆន្ទៈរបស់ខ្លួនក្នុងនាមជាភាគី(ជំនួសឱ្យភាគី) ហើយអានុភាពនៃការធ្វើសកម្មភាពនោះនឹងមានអានុភាពទៅលើភាគី[67] ។ អ្នកតំណាងតាមផ្លូវបណ្តឹងមានពីរ គឺអ្នកតំណាងដោយអាណត្តិ និងអ្នកតំណាងដែលច្បាប់បានកំណត់ ។

### ២.៣.១. អ្នកតំណាងដោយអាណត្តិ

អ្នកតំណាងដោយអាណត្តិ គឺជាអ្នកដែលបានទទួលសិទ្ធិតំណាងជាលាយល័ក្ខណ៍អក្សរពីម្ចាស់សិទ្ធិដោយផ្អែកលើឆន្ទៈរបស់ម្ចាស់សិទ្ធិ ហើយធ្វើសកម្មភាពជំនួសឱ្យម្ចាស់សិទ្ធិក្នុងនាមម្ចាស់សិទ្ធិ ។

ក.លក្ខណៈសម្បត្តិរបស់អ្នកតំណាង

ទោះបីជាភាគីជាជនដែលមានការយល់ដឹង និងមានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹងក្តី ក៏ច្បាប់បានបង្កើតឱ្យមានរបបតំណាងដោយអាណត្តិផងដែរ ។ ដោយហេតុថាតាមធម្មតាការធ្វើសកម្មភាពដោយភាគីផ្ទាល់ពុំសូវត្រឹមត្រូវតាមច្បាប់ និងពុំសូវមានប្រសិទ្ធភាពនោះទេ ព្រោះថាប្រជាជនភាគច្រើនពុំសូវមានចំណេះដឹងផ្នែកច្បាប់នោះទេ ។ ជាគោលការណ៍អ្នកតំណាងដោយអាណត្តិត្រូវជាមេធាវី[68] ។ ប៉ុន្តែ អ្នកតំណាងដោយអាណត្តិក៏អាចជាជនក្រៅពីមេធាវីដែរ ដូចជា ៖

- ករណីដែលច្បាប់អនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវីធ្វើសកម្មភាពបណ្តឹងជំនួសភាគី
- ករណីភាគីជារដ្ឋ ស្ថាប័ននីតិរដ្ឋបាល ឬស្ថាប័នរដ្ឋដទៃទៀត ហើយស្ថាប័ននោះបានតែងតាំងបុគ្គលិកនៃស្ថាប័ននោះធ្វើជាអ្នកតំណាង ។
- ករណីដែលតុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជនដែលមិនមែនជាមេធាវីក្នុងរឿងក្តីដែលមានកម្មវត្ថុនៃបណ្តឹងតិចជាង១.០០០.០០០(មួយលាន) រៀល ។

ទោះបីជាសកម្មភាពដែលបានធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ បង្កើតអានុភាពដូចគ្នានឹងសកម្មភាពដែលធ្វើដោយភាគីក្តី ក៏អានុភាពនៃសាលដីកានោះមិនមានអានុភាពចំពោះអ្នក

[67] ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្តឹង* (ភ្នំពេញ ឆ្នាំ២០០៨) ទំព័រ២៨ កថាភាគទី១ ចំណុចទី១

[68] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣

តំណាងដោយអាណត្តិឡើយ ព្រោះថាអ្នកតំណាងដោយអាណត្តិមិនមែនជាភាគីឡើយ[69] ។

ខ.សិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ

នៅក្នុងនីតិវិធីនៃបណ្តឹងអ្នកតំណាងដោយអាណត្តិមានសិទ្ធិធ្វើរាល់សកម្មភាពបណ្តឹងដូចជា ការដាក់ពាក្យបណ្តឹង ការឆ្លើយដោះសារចំពោះបណ្តឹង ការប្តឹងតប ការចូលរួមអន្តរាគមន៍ ការធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ការផ្សះផ្សា ការលះបង់ការទាមទារ និងការទទួលស្គាល់នូវការទាមទារចំពោះរឿងក្តីដែលខ្លួនបានទទួលដោយអាណត្តិ ។ សិទ្ធិតំណាងដែលត្រូវបានប្រគល់សម្រាប់បណ្តឹងរាប់បញ្ចូលទាំងសិទ្ធិលើការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ការទទួលនូវការសង និងការជ្រើសតាំងអនុតំណាង ។ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាមេធាវីភាគីពុំអាចកម្រិតនូវសិទ្ធិតំណាងបានទេ ។ ប៉ុន្តែ ចំពោះការដាក់ពាក្យបណ្តឹងតប ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់នូវការទាមទារ ការដកខ្លួនពីបណ្តឹង ការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និងការជ្រើសតាំងអនុតំណាងម្ចាស់សិទ្ធិអាចធ្វើការកម្រិតនូវសិទ្ធិតំណាងទាំងនេះបាន[70] ។

សិទ្ធិអំណាចនៃអ្នកតំណាងដោយអាណត្តិមិនត្រូវរលត់ឡើយទោះបីជាភាគីទទួលមរណភាព ឬបាត់បង់សមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង ឬមានករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានប្តូរក៏ដោយ[71] ។ ប៉ុន្តែ សិទ្ធិរបស់អ្នកតំណាងដោយអាណត្តិនឹងត្រូវរលត់ដោយសារមរណភាពនៃអ្នកតំណាងនោះ ឬការបាត់បង់លក្ខណសម្បត្តិរបស់អ្នកតំណាង ឬការបញ្ចប់កិច្ចសន្យាអាណត្តិជាដើម ។ ភាគីអាចដកសិទ្ធិតំណាងដោយអាណត្តិនៅពេលណាក៏បាន ហើយអ្នកតំណាងដោយអាណត្តិក៏អាចឈប់ធ្វើជាអ្នកតំណាងនៅពេលណាក៏បានដែរ ។ ចំពោះការដកសិទ្ធិតំណាង ឬការឈប់ធ្វើជាអ្នកតំណាងត្រូវមានការជូនដំណឹងនេះពីសាមីខ្លួន ឬអ្នកតំណាងទៅភាគីម្ខាងទៀត បើពុំនោះទេនឹងមិនមានអានុភាពឡើយ[72] ។

### ២.៣.២. អ្នកតំណាងដែលច្បាប់បានកំណត់

អ្នកតំណាងដែលច្បាប់បានកំណត់ គឺជាអ្នកដែលទទួលបាននូវសិទ្ធិតំណាងឱ្យអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ តាមរយៈបទប្បញ្ញត្តិនៃច្បាប់ ឬសេចក្តីសម្រេចរបស់តុលាការ គឺមិនមែនទទួលបានសិទ្ធិនេះដោយផ្អែកលើឆន្ទៈរបស់ភាគីឡើយ ។ ចំពោះអ្នកតំណាងសម្រាប់

[69] ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្តឹង* (ភ្នំពេញ ឆ្នាំ២០០៨) ទំព័រ៣១ ចំណុចទី៣

[70] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤

[71] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥

[72] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦

អនីតិជនគឺអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន រីឯអ្នកតំណាងសម្រាប់ជននៅក្រោមអាណាព្យាបាលទូទៅ គឺអ្នកអាណាព្យាបាលទូទៅ[73] ។ រាល់ការធ្វើសកម្មភាពបណ្តឹងរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពទាំងនេះត្រូវធ្វើឡើងតាមរយៈអ្នកតំណាងរបស់ខ្លួន ពោលគឺជនទាំងនេះមិនអាចធ្វើសកម្មភាពបណ្តឹងដោយឯកឯងបានឡើយ ។ បើទោះបីជាអ្នកតំណាងដែលច្បាប់បានកំណត់ធ្វើសកម្មភាពបណ្តឹងជំនួសជនដែលខ្លួនតំណាងក៏ដោយក៏អ្នកតំណាងមិនមែនជាភាគីទេ ហេតុនេះអ្នកតំណាងមិនអាចក្លាយជាអ្នកដែលមានឈ្មោះក្នុងសាលដីកាទេ ។ ប៉ុន្តែ មានករណីមួយចំនួនក្រមនីតិវិធីរដ្ឋប្បវេណីបានចាត់ទុកអ្នកតំណាងដែលច្បាប់បានកំណត់ដូចជាសាមីភាគីដែរ មានដូចជា ករណីចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹងនៃមាត្រា៧៥ កថាខណ្ឌទី២ ចំណុច ក ការសាកសួរអ្នកតំណាងដែលច្បាប់បានកំណត់នៃមាត្រា១៤២ ការផ្អាក និងការទទួលបន្តនីតិវិធីនៃបណ្តឹងនៃមាត្រា១៧៣ កថាខណ្ឌទី១ ចំណុច គ និងចំណុចត្រូវសរសេរនៅក្នុងលិខិតសាលក្រមនៃមាត្រា១៨៩ កថាខណ្ឌទី១ ចំណុច គ ជាដើម ។

ក្នុងករណីដែលគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ពុំអាចប្រតិបត្តិនូវសិទ្ធិតំណាងនោះ បុគ្គលដែលមានបំណងធ្វើសកម្មភាពបណ្តឹងចំពោះបុគ្គលដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង អាចដាក់ពាក្យសុំទៅតុលាការដែលទទួលបណ្តឹងឱ្យជ្រើសតាំងអ្នកតំណាងពិសេស ដោយធ្វើសេចក្តីបញ្ជាក់ជំបូងថា ការខូចខាតអាចនឹងកើតឡើងដោយសារការយឺតយ៉ាវនោះ[74] ។

ចំពោះជននៅក្រោមហិតូបត្ថម្ភ អាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបានតែត្រូវទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ បើពុំនោះទេសកម្មភាពនោះនឹងអាចធ្វើការលុបចោលបាន[75] ។ ប៉ុន្តែ ការធ្វើសកម្មភាពបណ្តឹងចំពោះបណ្តឹង(បណ្តឹងតវ៉ា) ឬបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវបានធ្វើដោយភាគីម្ខាងទៀតដោយពុំចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ ។ ផ្ទុយមកវិញចំពោះការដកពាក្យបណ្តឹង ការសះជា ការលះបង់ការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ឬដកពាក្យបណ្តឹងសាទុក្ខត្រូវមានការយល់ព្រមពិសេសពីហិតូបត្ថម្ភកៈ ។ ពីព្រោះថាសកម្មភាពទាំងនេះ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ជននៅក្រោមហិតូបត្ថម្ភ ដែលចាំបាច់ត្រូវមានការ ប្រគល់សិទ្ធិពិសេសពីហិតូបត្ថម្ភកៈ[76] ។

[73] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៨ និង២៥
[74] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦
[75] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣០ ចណុច ឃ
[76] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣

### ២.៤. សហបណ្តឹង

សហបណ្តឹង គឺជាការធ្វើបណ្តឹងមួយប្រភេទដែលមានដើមចោទ ឬចុងចម្លើយច្រើននាក់ ។ ភាគីនៅក្នុងសហបណ្តឹងត្រូវបានហៅថា សហដើមចោទ និងសហចុងចម្លើយ ។ សហបណ្តឹងមានពីរប្រភេទគឺ សហបណ្តឹងចាំបាច់ និងសហបណ្តឹងធម្មតា ។ សហបណ្តឹងចាំបាច់ធ្វើឡើងក្នុងករណីដែលសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនឹងត្រូវសម្រេចជាស្ថាពរបានលុះត្រាតែមានការចូលរួមពីអ្នកធ្វើសហបណ្តឹងទាំងអស់ ។ ចំណែកឯសហបណ្តឹងធម្មតាធ្វើឡើងក្នុងករណីដែលបុគ្គលម្នាក់ៗនៃបណ្តឹងមានសិទ្ធិចាត់ចែងសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងដាច់ដោយឡែកពីគ្នាបាន[77] ។

#### ២.៤.១. លក្ខខ័ណ្ឌនៃសហបណ្តឹង

សហបណ្តឹងអាចធ្វើបានក្នុងករណីដែលមានបុគ្គលច្រើននាក់ដែល ៖

- បើសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនោះដូចគ្នា ។
- បើសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនោះផ្អែកលើមូលហេតុដូចគ្នាលើអង្គហេតុ និងអង្គច្បាប់ ។
- បើសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនោះមានប្រភេទដូចគ្នា ហើយផ្អែកលើមូលហេតុដែលមានប្រភេទដូចគ្នាលើអង្គហេតុ និងអង្គច្បាប់ ។

ប្រសិនបើមានករណីដូចបានរៀបរាប់ខាងលើនេះបុគ្គលទាំងនោះអាចប្តឹង ឬអាចត្រូវគេប្តឹងក្នុងនាមជាអ្នកសហបណ្តឹង[78] ។

#### ២.៤.២. ការជ្រើសរើសភាគី និងឋានៈនៃសហបណ្តឹង

នៅក្នុងករណីដែលមានបុគ្គលច្រើននាក់ដែលមានផលប្រយោជន៍រួមមួយអាចធ្វើការជ្រើសរើសបុគ្គលម្នាក់ ឬច្រើននាក់ពីក្នុងចំណោមបុគ្គលទាំងនោះដើម្បីធ្វើជាដើមចោទ ឬចុងចម្លើយសម្រាប់បុគ្គលទាំងនោះបាន ។ ក្រោយពេលដែលបានជ្រើសរើសដើមចោទ ឬចុងចម្លើយរួចហើយពេលដែលតុលាការកំពុងចាត់ការបណ្តឹងភាគីផ្សេងទៀតត្រូវដកខ្លួនដោយស្វ័យប្រវត្តិ ។ ចំពោះអ្នកដែលបានធ្វើការជ្រើសរើសដើមចោទ ឬចុងចម្លើយរួចហើយអាចធ្វើការលុបចោល ឬផ្លាស់ប្តូរអ្នកដែលខ្លួនបានធ្វើការជ្រើសរើសនោះបាន ។ ប្រសិនបើអ្នកដែលត្រូវបានជ្រើសរើសនោះបានបាត់បង់លក្ខណៈជាភាគីដោយសារបានទទួលមរណភាព ឬដោយមូលហេតុផ្សេងទៀត ភាគីដែល

[77] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី* (បោះពុម្ពលើកទី១ ឆ្នាំ២០០៧) ចំណុច ១២៨, ១២៩, ១៣០ ទំព័រ៨៥

[78] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៩

ត្រូវបានជ្រើសរើសផ្សេងទៀតអាចធ្វើសកម្មភាពបណ្តឹងសម្រាប់បុគ្គលទាំងអស់បាន[79] ។

### ២.៥. អ្នកចូលរួមជួយអន្តរាគមន៍

តតិយជនណាដែលមានការទាក់ទងនឹងផលប្រយោជន៍តាមផ្លូវច្បាប់អំពីលទ្ធផលនៃបណ្តឹងអាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹង ដើម្បីជួយភាគីណាម្ខាងបាន[80] ។ ដើម្បីអាចចូលរួមជួយអន្តរាគមន៍បាន អ្នកចូលរួមជួយអន្តរាគមន៍ត្រូវដាក់ពាក្យសុំទៅតុលាការដែលខ្លួននឹងត្រូវធ្វើសកម្មភាពបណ្តឹង ។ ហើយត្រូវធ្វើការបញ្ជាក់ថាតើខ្លួនចូលរួមជួយអន្តរាគមន៍សម្រាប់ភាគីខាងណានៃបណ្តឹង និងមូលហេតុនៃការចូលរួមឱ្យបានច្បាស់លាស់ផង[81] ។ ប្រសិនបើភាគីប្តឹងតវ៉ានឹងការចូលរួមជួយអន្តរាគមន៍ តុលាការត្រូវសម្រេចសេចក្តីនូវការអនុញ្ញាត ឬមិនអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍ដោយដីកាសម្រេច ។ ក្នុងករណីនេះ អ្នកចូលរួមជួយអន្តរាគមន៍ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុនៃការចូលរួម ។ ការប្តឹងតវ៉ានេះមិនអាចធ្វើបានឡើយនៅក្រោយពេលដែលភាគីបានឆ្លើយទាញហេតុផលនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ដោយគ្មានការប្តឹងតវ៉ា[82] ។ ទោះបីជាមានការប្តឹងតវ៉ាចំពោះការចូលរួមជួយអន្តរាគមន៍ក៏ដោយក៏អ្នកចូលរួមជួយអន្តរាគមន៍អាចធ្វើសកម្មភាពបណ្តឹងបានដែររហូតដល់ពេលដែលសេចក្តីសម្រេចរបស់តុលាការថាមិនអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍នោះចូលជាស្ថាពរ ។ ជាងនេះទៅទៀតទោះបីជាតុលាការសម្រេចមិនអនុញ្ញាតនោះបានចូលជាស្ថាពរក្តីក៏សកម្មភាពនោះ នៅតែមានអានុភាពដែរបើភាគីបានលើកឡើងនូវសកម្មភាពនោះ[83] ។

#### ២.៥.១. សិទ្ធិអំណាចនៃអ្នកចូលរួមជួយអន្តរាគមន៍

អ្នកចូលរួមជួយអន្តរាគមន៍អាចដាក់វិធីតទល់ ឬការពារខ្លួន ធ្វើការប្តឹងតវ៉ាង ធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មី និងធ្វើសកម្មភាពបណ្តឹងផ្សេងៗទៀតដែលទាក់ទងនឹងបណ្តឹងនោះ ។ ប៉ុន្តែ ចំពោះសកម្មភាពដែលអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍មិនអាចធ្វើបាននៅពេលដែលខ្លួនត្រូវបានគេចូលរួមជួយ នោះអ្នកចូលរួមជួយអន្តរាគមន៍នោះក៏មិនអាចធ្វើសកម្មភាពនោះបានឡើយ[84] ។ មានន័យថាអ្នកដែលចូលរួមជួយអន្តរាគមន៍អាចធ្វើបានតែសកម្មភាពភាពណាដែលអ្នកដែលត្រូវខ្លួនចូលរួមជួយអន្តរាគមន៍នោះអាចធ្វើបានប៉ុណ្ណោះ ។ ហើយ

[79] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤២
[80] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៣
[81] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៦, ២៧៣, ៤៤
[82] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៥
[83] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៦ កថាខណ្ឌទី៣ និងទី៤
[84] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៦

ប្រសិនបើសកម្មភាពណាដែលអ្នកចូលរួមជួយអន្តរាគមន៍បានធ្វើឱ្យមានការប៉ះពាល់ប្រឆាំងនឹងសកម្មភាពអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ សកម្មភាពនោះនឹងគ្មានអានុភាពឡើយ ។

### ២.៥.២. អានុភាពសេចក្ដីសម្រេចចំពោះអ្នកចូលរួមជួយអន្តរាគមន៍

ជាគោលការណ៍អានុភាពនៃសាលដីកាមានតែទៅលើភាគីប៉ុណ្ណោះ ប៉ុន្តែវាក៏អាចមានអានុភាពពិសេសទៅលើអ្នកចូលរួមជួយអន្តរាគមន៍ផងដែរ ។ នៅពេលណាដែលអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ចាញ់ក្ដី នោះអ្នកចូលរួមជួយអន្តរាគមន៍ក៏ត្រូវទទួលខុសត្រូវចំពោះការចាញ់ក្ដីនោះជាមួយគ្នាដែរដើម្បីឱ្យមានសមភាព ។ ហេតុនេះហើយអានុភាពនេះត្រូវកើតឡើងរវាងអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ និងអ្នកចូលរួមជួយអន្តរាគមន៍តែពេលចាញ់ក្ដីតែប៉ុណ្ណោះ[85] ។ ផ្ទុយមកវិញ ប្រសិនបើសកម្មភាពដែលអ្នកចូលរួមជួយអន្តរាគមន៍មិនអាចធ្វើបាននៅក្រោយពេលដែលខ្លួនចូលរួមជួយអន្តរាគមន៍(ដូចបានរៀបរាប់ខាងលើ) ឬសកម្មភាពរបស់អ្នកចូលរួមជួយអន្តរាគមន៍ប្រឆាំងនឹងអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ ឬអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍បានរារាំងសកម្មភាពបណ្ដឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ ឬមួយអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍មិនបានធ្វើសកម្មភាពបណ្ដឹងដែលអ្នកចូលរួមជួយអន្តរាគមន៍មិនអាចធ្វើបានដោយចេតនា ឬដោយកំហុសរបស់ខ្លួននោះសាលដីកានឹងមិនមានចំណងទៅលើអ្នកចូលរួមជួយអន្តរាគមន៍ឡើយ ។

### ២.៥.៣. ការចូលរួមជួយអន្តរាគមន៍ និងសហបណ្ដឹង

នៅពេលដែលសាលដីកាមានអានុភាពស្ពានរវាងអ្នកចូលរួមជួយអន្តរាគមន៍ និងភាគីម្ខាងទៀតនៃអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ ឋានៈរបស់អ្នកចូលរួមជួយអន្តរាគមន៍លើបណ្ដឹងមានដូចគ្នានឹងអ្នកធ្វើសហបណ្ដឹងចាំបាច់ដែរ ។ ប៉ុន្តែ មិនមានន័យថារាល់សកម្មភាពរបស់អ្នកចូលរួមជួយអន្តរាគមន៍សុទ្ធតែមានអានុភាពដូចសហបណ្ដឹងចាំបាច់នោះទេ គឺមានតែសកម្មភាពមួយចំនួនតែប៉ុណ្ណោះ[86] ។ សកម្មភាពទាំងនោះមានដូចជា ៖

- សកម្មភាពរបស់អ្នកចូលរួមជួយអន្តរាគមន៍ ទោះបីជាមានការប៉ះពាល់នឹងសកម្មភាពបណ្ដឹងរបស់អ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ក៏ដោយ ឱ្យតែអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍នោះមានផលប្រយោជន៍អានុភាពនេះនឹងកើតមានឡើង ។ ជាឧទាហរណ៍ទោះបីជាអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍បានបោះបង់សិទ្ធិប្ដឹងសាទុក្ខក៏ដោយ ក៏អ្នកចូលរួមជួយអន្តរាគមន៍អាចធ្វើបណ្ដឹងសាទុក្ខបានដែរ ហើយពេលនោះអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍នោះមិនអាចដកពាក្យបណ្ដឹងសាទុក្ខនោះមកវិញបានទេ ។

---

[85] ក្រសួងយុត្តិធម៌, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា៤៧

[86] ក្រសួងយុត្តិធម៌, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា៤៨

- អំឡុងពេលដែលអ្នកចូលរួមជួយអន្តរាគមន៍អាចប្តឹងសាទុក្ខបាននោះត្រូវគិតដោយឡែកពីអំឡុងពេលដែលអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍អាចប្តឹងសាទុក្ខបាន ។
- ប្រសិនបើមានមូលហេតុនៃការផ្អាក ឬបង្អង់នូវនីតិវិធីកើតឡើងចំពោះអ្នកចូលរួមជួយអន្តរាគមន៍ តុលាការអាចបង្គាប់ឱ្យបង្អង់នូវនីតិវិធីនោះបាន ។

## ៣. អានុភាពនៃពាក្យបណ្តឹងសាទុក្ខ

នៅក្រោយពេលដែលពាក្យបណ្តឹងសាទុក្ខត្រូវបានដាក់ទៅដល់តុលាការនៃបណ្តឹងសាទុក្ខនោះវានឹងបង្កើតឱ្យមាននូវអានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលដីកា ឬសាលក្រមរបស់តុលាការដើម អនុភាពនៃការផ្ទេរការជម្រះក្តី និងអានុភាពអវិភាគនៃបណ្តឹងសាទុក្ខ ។

### ៣.១. អានុភាពបង្អាក់ការចូលជាស្ថាពរ

នៅក្រោយពេលដែលបណ្តឹងសាទុក្ខត្រូវបានធ្វើឡើងត្រឹមត្រូវតាមអំឡុងពេលកំណត់ នោះវានឹងរារាំងអានុភាពនៃការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា ។ មានន័យថានៅពេលដែលដើមបណ្តឹងសាទុក្ខបានធ្វើបណ្តឹងក្នុងអំឡុងពេលមួយខែបន្ទាប់ពីបានទទួលលិខិតសាលក្រម ឬសាលដីកា ទោះបីជារយៈពេលនៃការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកាបានចូលមកដល់ ឬបានកន្លងផុតក៏ដោយក៏សាលក្រម ឬសាលដីកានោះមិនអាចចូលជាស្ថាពរដែរ[87] ។

### ៣.២. ការផ្ទេរការជំនុំជម្រះក្តី

នៅពេលដែលមានពាក្យបណ្តឹងសាទុក្ខ នោះការជំនុំជម្រះដោយតុលាការថ្នាក់ក្រោម(សាលាដំបូង ឬសាលាឧទ្ធរណ៍)នឹងត្រូវផ្ទេរទៅតុលាការនៃបណ្តឹងសាទុក្ខជាអ្នកមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យ និងចេញសេចក្តីសម្រេច ។

### ៣.៣. អានុភាពអវិភាគនៃបណ្តឹងសាទុក្ខ

ទោះបីជាដើមបណ្តឹងសាទុក្ខបានធ្វើឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រម ឬសាលដីកាដើមក៏ដោយក៏បណ្តឹងនោះមានអានុភាពបង្អាក់ការចូលជាស្ថាពរ និងមានការផ្ទេរការជំនុំជម្រះត្រូវកើតមានឡើងទៅលើការទាមទារទាំងអស់ដែលមាននៅក្នុងសាលក្រម ឬសាលដីកានោះ ។ នេះគេហៅថាភាពអវិភាគនៃបណ្តឹងសាទុក្ខ បានសេចក្តីថាទោះបីជាដើមបណ្តឹងសាទុក្ខធ្វើបណ្តឹងតែមួយផ្នែកនៅក្នុងសាលក្រម ឬសាលដីកាដើមក៏ផ្នែកដែលមិនបានធ្វើឧបាស្រ័យមិនអាចចូលជាស្ថាពរ ហើយក៏មិនអាចយកទៅអនុវត្តបានឡើយ ។ លើកលែងតែមានការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយតុលាការដើម ឬក៏ដោយតុលាការនៃបណ្តឹងសាទុក្ខ ទើបផ្នែកដែលមិនបានធ្វើឧបាស្រ័យ

[87] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៦, ២៧៣, ១៩៣ កថាខណ្ឌទី២

នោះអាចអនុវត្តបាន[88] ។

## ៤. បណ្តឹងសាទុក្ខបន្ទាប់បន្សំ

នៅក្រោយពេលដែលដើមបណ្តឹងសាទុក្ខបានធ្វើឧបាស្រ័យចំពោះសាលក្រម ឬសាលដីកាដែលចេញដោយតុលាការដើម ចុងបណ្តឹងសាទុក្ខក៏អាចឆ្លៀតឱកាសនេះដើម្បីធ្វើឧបាស្រ័យទៅជាមួយគ្នានឹងសេចក្តីឧបាស្រ័យរបស់ដើមបណ្តឹងសាទុក្ខ ដើម្បីទាមទារឱ្យតុលាការធ្វើការផ្លាស់ប្តូរនូវភាគដែលខ្លួនចាញ់នៅក្នុងសាលក្រម ឬសាលដីការបស់តុលាការដើម ។ ជាឧទាហរណ៍ នៅពេលដែលសាលាឧទ្ធរណ៍បានចេញសាលដីកា សម្រេចឱ្យដើមបណ្តឹងឧទ្ធរណ៍ឈ្នះ ២ចំណុច ក្នុងចំណោម ៣ ចំណុចដែលខ្លួនបានទាមទារ ពេលនោះដើមបណ្តឹងឧទ្ធរណ៍មិនធ្វើបណ្តឹងសាទុក្ខបន្តទៀតទេ ។ ប៉ុន្តែ ចុងបណ្តឹងឧទ្ធរណ៍ បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលដីកា ដែលតុលាការបានកាត់សេចក្តីឱ្យដើមបណ្តឹងឧទ្ធរណ៍ឈ្នះនោះ (២ចំណុចដែលដើមបណ្តឹងឧទ្ធរណ៍បានឈ្នះ) ។ ឆ្លៀតពេលមានពាក្យបណ្តឹងសាទុក្ខ ដើមបណ្តឹងឧទ្ធរណ៍ក៏បានធ្វើឧបាស្រ័យនូវចំណុចដែលតុលាការសម្រេចឱ្យខ្លួនចាញ់អមទៅជាមួយបណ្តឹងសាទុក្ខរបស់ចុងបណ្តឹងឧទ្ធរណ៍ ។ បណ្តឹងដែលធ្វើឡើងដោយឆ្លៀតឱកាសដែលមានបណ្តឹងសាទុក្ខបែបនេះគេហៅថា បណ្តឹងសាទុក្ខបន្ទាប់បន្សំ ។ ទោះបីជាអំឡុងពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខត្រូវបានកន្លងផុត ឬមួយចុងបណ្តឹងសាទុក្ខបានលះបង់សិទ្ធិធ្វើបណ្តឹងសាទុក្ខក្តី ក៏ចុងបណ្តឹងសាទុក្ខអាចធ្វើបណ្តឹងសាទុក្ខបន្ទាប់បន្សំនេះបានដែរ ។ ប៉ុន្តែ បណ្តឹងនេះត្រូវតែធ្វើឡើងមុនពេលបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះបណ្តឹងសាទុក្ខ ។

ដោយហេតុថាបណ្តឹងសាទុក្ខបន្ទាប់បន្សំ ជាបណ្តឹងដែលឆ្លៀតឱកាសដែលមានបណ្តឹងសាទុក្ខពីភាគីម្ខាងទៀត ដូច្នេះ នៅពេលដែលបណ្តឹងសាទុក្ខត្រូវបានដក ឬត្រូវបានតុលាការលើកចោលនោះបណ្តឹងសាទុក្ខបន្ទាប់បន្សំក៏ត្រូវបាត់បង់អានុភាពទៅជាមួយគ្នាផងដែរ ។ តែប្រសិនបើបណ្តឹងសាទុក្ខបន្ទាប់បន្សំនោះត្រូវបានធ្វើឡើងដោយមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់សម្រាប់ធ្វើបណ្តឹងសាទុក្ខ បណ្តឹងសាទុក្ខបន្ទាប់បន្សំនោះត្រូវចាត់ទុកថាជាបណ្តឹងសាទុក្ខឯករាជ្យ[89] ។

ជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តីត្រឹមកម្រិតដែលដើមបណ្តឹងសាទុក្ខបានធ្វើឧបាស្រ័យតែប៉ុណ្ណោះ ប៉ុន្តែនៅពេលដែលមានបណ្តឹងសាទុក្ខ

[88] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩៣ កថាខ័ណ្ឌទី២ មាត្រា១៩៦ និង ២៩៨

[89] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា២៨៦, ២៧៣ និង២៧០

បន្ទាប់បន្សំ នោះទំហំនៃការវិនិច្ឆ័យក៏ត្រូវពង្រីកដែរ ។ ចំពោះរបៀបប្តឹងសាទុក្ខបន្ទាប់បន្សំត្រូវធ្វើដូចគ្នានឹងការធ្វើបណ្តឹងសាទុក្ខដែរ[90] ។

## ៥. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលផ្ទាល់មាត់

នៅក្រោយពេលដែលបានទទួលពាក្យបណ្តឹងសាទុក្ខ និងពិនិត្យឃើញថាបណ្តឹងនោះធ្វើឡើងត្រឹមត្រូវហើយ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការកំណត់នូវកាលបរិច្ឆេទសម្រាប់ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានឆាប់រហ័ស និងធ្វើការកោះហៅគូភាគីឱ្យចូលរួម ។ គួរបញ្ជាក់ផងដែរថាបណ្តឹងសាទុក្ខធ្វើឡើងដោយផ្អែកលើមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬសាលក្រម និងអនិយតភាពនៃនីតិវិធីប៉ុណ្ណោះ ដូច្នេះតុលាការធ្វើការវិនិច្ឆ័យតែទៅលើអង្គច្បាប់ប៉ុណ្ណោះ ហេតុនេះ តុលាការមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីរៀបចំនូវសេចក្តីអះអាងរបស់ភាគីកំណត់ចំណុចវិវាទ និងរៀបចំភស្តុតាងទេ ព្រោះនីតិវិធីនេះត្រូវបានធ្វើនៅក្នុងនីតិវិធីជំនុំជម្រះលើកទី១ រួចហើយ ហេតុនេះតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់តែម្តង ។ នៅក្រោយពេលដែលបានកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចរាល់ តុលាការត្រូវធ្វើការបញ្ជូនដីកាកោះទៅភាគី ដើម្បីឱ្យភាគីចូលរួមក្នុងនីតិវិធី ។ ការបញ្ជូនដីកាកោះអាចធ្វើការបញ្ជូនទៅភាគីជាមួយគ្នានឹងលិខិតទទួលពាក្យបណ្តឹង លើកលែងតែករណីដែលតុលាការលើកចោលពាក្យបណ្តឹងសាទុក្ខនោះ ឬតុលាការបង្គាប់ឱ្យដើម បណ្តឹងសាទុក្ខដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឬមួយតុលាការចេញដីកាបង្គាប់ឱ្យកែតម្រូវជាដើម[91] ។

[90] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៦, ២៧៨

[91] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៨

# ជំពូកទី ៣
# នីតិវិធីទាញហេតុផល
# ដោយផ្ទាល់មាត់ និងការ
# បញ្ឈប់បណ្ដឹង

# ជំពូកទី៣ : នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការបញ្ចប់បណ្តឹង

## ផ្នែកទី១ : នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

### ១. ទំហំនៃការទាញហេតុផលដោយផ្ទាល់មាត់

ដើម្បីធ្វើការវិនិច្ឆ័យ និងចេញសាលដីកានៃបណ្តឹងសាទុក្ខតុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែករណីដែលតុលាការច្រានចោលបណ្តឹងសាទុក្ខដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់[92] ។ ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងត្រឹមទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្តូរនៅក្នុងសាលក្រម ឬសាលដីកានៃតុលាការដើមតែប៉ុណ្ណោះ[93] ។ ការទាញហេតុ ផលដោយផ្ទាល់មាត់ត្រូវធ្វើតែទៅលើចំណុចណាដែលបានធ្វើឧបាស្រ័យតែប៉ុណ្ណោះ ចំពោះចំណុចណាដែលភាគីមិនបានធ្វើឧបាស្រ័យតុលាការមិនអាចយកមកធ្វើការវិនិច្ឆ័យឡើយ ។ ការកំណត់បែបនេះ គឺទាញចេញពីគោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្តូរដែលធ្វើខូចប្រយោជន៍ ។ មានន័យថា ការផ្លាស់ប្តូរសាលក្រម ឬសាលដីការបស់តុលាការដើមអាចធ្វើបានត្រឹមតែកម្រិតដែលបានធ្វើឧបាស្រ័យបណ្តឹងសាទុក្ខតែប៉ុណ្ណោះ ។ ប៉ុន្តែ ប្រសិនបើមានពាក្យបណ្តឹងសាទុក្ខបន្ទាប់បន្សំ ការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងសាទុក្ខក៏ត្រូវប្រែប្រួលតាមការទាមទារនោះដែរ ។ តុលាការមិនត្រូវធ្វើការវិនិច្ឆ័យទៅលើចំណុចណាដែលភាគីមិនបានទាមទារឡើយ[94] ។

### ២.នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

#### ២.១. ការទាញហេតុផលដោយផ្ទាល់មាត់

##### ក. សមាសភាពចៅក្រមជំនុំជម្រះ

សភារដ្ឋប្បវេណីនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងសាទុក្ខចំពោះសាលដីកាផ្នែករដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ឬសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង ។ ការជំនុំជម្រះក្តីត្រូវធ្វើឡើងដោយមានចៅក្រមចំនួន ០៥(ប្រាំ) រូប ក្នុងនោះមានចៅក្រម ០១(មួយ) រូប ត្រូវបានចាត់តាំងឱ្យធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជម្រះដើម្បីធ្វើជាអ្នកដឹកនាំកិច្ចដំណើរការនៃនីតិវិធី[95] ។

---

[92] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៩៤

[93] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៧២ កថាខណ្ឌទី១

[94] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា២៧៨

[95] ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៥៩ និងមាត្រា៦៥

**ខ. សកម្មភាពនៃការទាញហេតុផលដោយផ្ទាល់មាត់**

នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់របស់តុលាការនៃបណ្ដឹងសាទុក្ខ គឺជាការវិនិច្ឆ័យតែទៅលើអង្គច្បាប់ប៉ុណ្ណោះ ។ តុលាការនៃបណ្ដឹងសាទុក្ខធ្វើការពិនិត្យ និងវិនិច្ឆ័យតែអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយលើការអនុវត្តច្បាប់តែប៉ុណ្ណោះ ។ ការវិនិច្ឆ័យនេះ គឺផ្អែកទៅលើការអះអាងរបស់ភាគី និងភស្តុតាងដែលបានដាក់នៅតុលាការដើម តាមរយៈការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះអង្គហេតុដែលបានទទួលស្គាល់នៅតុលាការដើម ហើយតុលាការនៃបណ្ដឹងសាទុក្ខមិនទទួលស្គាល់អង្គហេតុឡើងវិញទេ ។ ការវិនិច្ឆ័យលើអង្គច្បាប់របស់តុលាការនៃបណ្ដឹងសាទុក្ខ គឺដើម្បីឱ្យមានការឯកភាពគ្នារបស់តុលាការថ្នាក់ក្រោមក្នុងការបកស្រាយច្បាប់ និងអនុវត្តច្បាប់ ។ ដោយហេតុថាសេចក្ដីសម្រេចរបស់តុលាការនៃបណ្ដឹងសាទុក្ខជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ហើយសេចក្ដីសម្រេចនេះអាចក្លាយទៅជាយុត្តិសាស្ត្រសម្រាប់ ឱ្យតុលាការថ្នាក់ក្រោមធ្វើការអនុវត្តតាម[96] ។

**សកម្មភាពទាញហេតុផលដោយផ្ទាល់មាត់ចាប់ផ្ដើមដោយ :**

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រកាសបើកនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ លើបណ្ដឹងសាទុក្ខដោយមានប្រកាសពីសមាសភាពនៃសមាជិកក្រុមប្រឹក្សាជំនុំជម្រះដែលបានចូលរួមធ្វើការវិនិច្ឆ័យ ក្រឡាបញ្ជី និងតំណាងមហាអយ្យការ(ករណីមានតំណាងមហាអយ្យការចូលរួម) ។

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រកាស អំពីសញ្ញាណនៃសំណុំរឿងដែលត្រូវធ្វើការជំនុំជម្រះដោយបង្ហាញឈ្មោះដើមបណ្ដឹងសាទុក្ខ មេធាវីរបស់ដើមបណ្ដឹងសាទុក្ខ ចុងបណ្ដឹងសាទុក្ខ មេធាវីរបស់ចុងបណ្ដឹងសាទុក្ខ តតិយជន និងកម្មវត្ថុនៃបណ្ដឹងសាទុក្ខ ។

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះបង្គាប់ឱ្យក្រឡាបញ្ជីរាយការណ៍ អំពីវត្តមានរបស់ជនដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ។

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះបង្គាប់ឱ្យចៅក្រមទទួលបញ្ជាអានរបាយការណ៍នៃសំណុំរឿងដោយមានរៀបរាប់ អំពីដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះរបស់ប្រធានតុលាការកំពូល ឈ្មោះ និងអាសយដ្ឋានរបស់គូភាគី អ្នកតំណាងរបស់គូភាគី(ករណីមានមានអ្នកតំណាង) តតិយជនដែលពាក់ព័ន្ធ កម្មវត្ថុនៃបណ្ដឹងសាទុក្ខ អង្គហេតុ និងដំណើរការនៃនីតិវិធីព្រមទាំងសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោម ទម្រង់ច្បាប់នៃបណ្ដឹងសាទុក្ខ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ និងឯកសារត្រៀមដែលចុងបណ្ដឹងសាទុក្ខបានដាក់មកតុលាការជាលើកដំបូង ។

[96] ក្រសួងយុត្តិធម៌, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា២៨៣

-ក្រោយពីចៅក្រមទទួលបញ្ជាអានរបាយការណ៍ចប់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះសួរយោបល់តំណាងមហាអយ្យការចំពោះសំណុំរឿង(ករណីមានតំណាងមហាអយ្យការចូលរួម) ។

-បន្ទាប់មកចូលដល់នីតិវិធីពិនិត្យមូលហេតុនៃបណ្ដឹងសាទុក្ខ ដោយប្រធានក្រុមប្រឹក្សាអញ្ជើញដើមបណ្ដឹងសាទុក្ខមកឈរពីមុខតុលាការឱ្យប្រាប់អំពីសាវតាជាតិរបស់ខ្លួន មូលហេតុនៃការប្ដឹងសាទុក្ខចំពោះសាលដីកាដើម ឬសាលក្រមដើម និងឱ្យធ្វើសេចក្ដីថ្លែងការណ៍បន្ថែមលើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខដែលខ្លួនបានដាក់ជូនមកតុលាការ ។

-បន្ទាប់មកប្រធានក្រុមប្រឹក្សាអញ្ជើញចុងបណ្ដឹងសាទុក្ខ មកឈរពីមុខតុលាការឱ្យប្រាប់អំពីសាវតាជាតិរបស់ខ្លួន និងធ្វើសេចក្ដីថ្លែងការណ៍តបទៅនឹងសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងសាទុក្ខ ។

-បើមានភាគីណាមួយអវត្តមាន ឬភាគីទាំងពីរអវត្តមាន ប្រធានក្រុមប្រឹក្សាបញ្ជាឱ្យក្រឡាបញ្ជីអានមូលហេតុនៃបណ្ដឹងសាទុក្ខ ឬឯកសារត្រៀមរបស់ភាគីដែលអវត្តមាននោះ ។

-ប្រធានក្រុមប្រឹក្សាអាចអនុញ្ញាតឱ្យភាគីធ្វើការអះអាងបន្ថែមទៀតបានបើយល់ឃើញថាចាំបាច់ បន្ទាប់មកប្រធានក្រុមប្រឹក្សាអញ្ជើញមេធាវីរបស់ដើមបណ្ដឹងសាទុក្ខធ្វើសេចក្ដីថ្លែងការណ៍ចុងក្រោយ ពេលមេធាវីរបស់ដើមបណ្ដឹងសាទុក្ខធ្វើសេចក្ដីថ្លែងការណ៍ចប់ ប្រធានក្រុមប្រឹក្សាអញ្ជើញមេធាវីរបស់ចុងបណ្ដឹងសាទុក្ខធ្វើសេចក្ដីថ្លែងការណ៍ចុងក្រោយម្ដង ។

-ពេលមេធាវីរបស់គូភាគីបានធ្វើសេចក្ដីថ្លែងការណ៍ចប់ហើយ ប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រកាសបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយថយទៅពិភាក្សាក្នុងបន្ទប់ពិភាក្សារបស់តុលាការ ។

-នៅដំណាក់កាលប្រកាសសាលដីកានេះ សម្លេងស្នូរកណ្ដឹងរោទិ៍ម្ដងតំណាងមហាអយ្យការចូល ក្នុងបន្ទប់ជំនុំជម្រះ(ករណីមានតំណាងមហាអយ្យការចូលរួមសវនាការ) ស្នូរកណ្ដឹងរោទិ៍ពីរដងក្រុមប្រឹក្សាចូលបន្ទប់ជំនុំជម្រះ ហើយប្រធានក្រុមប្រឹក្សាបង្គាប់ឱ្យដើមបណ្ដឹងសាទុក្ខ និងចុងបណ្ដឹងសាទុក្ខមកឈរនៅចំពោះមុខតុលាការ រួចប្រធានក្រុមប្រឹក្សា ឬចៅក្រមណាម្នាក់ប្រកាសសាលដីកាក្រោយពេលប្រកាសសាលដីកា ប្រធានក្រុមប្រឹក្សាប្រកាសបិទសវនាការ[97] ។

## ២.២ ការទាញហេតុផលដោយផ្ទាល់មាត់ ករណីមានបណ្ដឹងសាទុក្ខលើកទី២

### ក. សមាសភាពចៅក្រមជំនុំជម្រះ

ក្នុងករណីដែលតុលាការនៃបណ្ដឹងសាទុក្ខ បានបដិសេធនូវសាលដីកាដើម ហើយបានបញ្ជូន

[97] តុលាការកំពូល, *រូបមន្តនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៃរឿងក្ដីរដ្ឋប្បវេណី*

រឿងក្តីនោះត្រឡប់ទៅតុលាការដើមវិញ ឬផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា ដើម្បីឱ្យធ្វើការជំនុំជម្រះរឿងក្តីនោះម្តងទៀត បន្ទាប់មកនៅពេលដែលតុលាការដើមដែលបានទទួលការបញ្ជូនរឿងក្តីត្រឡប់មកវិញ ឬតុលាការដែលបានទទួលការផ្ទេររឿងក្តីនោះបានចេញសាលដីកា ហើយបើមានភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ ហើយបានប្តឹងសាទុក្ខម្តងទៀត ពេលនោះនីតិវិធីតុលាការនៃបណ្តឹងសាទុក្ខនឹងធ្វើការជំនុំជម្រះដោយសភាពេញអង្គ ។ សភាពេញអង្គត្រូវបង្កើតឱ្យមានដំណើរការដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទីពីរ និងបណ្តឹងជំនុំជម្រះសាជាថ្មី ក្នុងករណីដែលមានការស្នើសុំឱ្យមានការពិនិត្យ និងសម្រេចឡើងវិញចំពោះរឿងក្តីណាមួយពីព្រះមហាក្សត្រដែលជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ សភាពេញអង្គប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩(ប្រាំបួន) រូប ដែលមានចៅក្រមជាតំណាងនៃសភាទាំងអស់នៃតុលាការកំពូល ហើយសភាពេញអង្គដំណើរការក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល[98] ។

### ខ. សកម្មភាពនៃការទាញហេតុផលដោយផ្ទាល់មាត់

សកម្មភាពទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងករណីបណ្តឹងសាទុក្ខលើកទីពីរនេះ គឺធ្វើទៅតាមលំដាប់លំដោយដូចគ្នានឹងសកម្មភាពទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងបណ្តឹងសាទុក្ខលើកដំបូងដែរ ប៉ុន្តែអាចមានសាក្សី និងអ្នកជំនាញចូលរួមក្នុងសវនាការដែរ ដោយប្រធានក្រុមប្រឹក្សាអាចអញ្ជើញសាក្សី និងអ្នកជំនាញនោះមកឈរមុខតុលាការ ដើម្បីឱ្យអ្នកទាំងនោះជួយបំភ្លឺដល់រឿងក្តី ដើម្បីឱ្យតុលាការងាយស្រួលក្នុងការវិនិច្ឆ័យ និងចេញសាលដីកា ។ ករណីមានបន្ថែមសាក្សី និងអ្នកជំនាញនេះដោយសារតែបណ្តឹងសាទុក្ខលើកទីពីរនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការពិនិត្យឡើងវិញទាំងអង្គហេតុ និងអង្គច្បាប់ ។

## ផ្នែកទី២ : ការបញ្ចប់បណ្តឹងសាទុក្ខ

### ១.ការបញ្ចប់បណ្តឹងដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ

#### ១.១. ការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ

នៅពេលដែលនីតិវិធីបណ្តឹងសាទុក្ខកំពុងដំណើរការ ក្នុងករណីដែលមានភាគីណាមួយបានទទួលមរណភាពហើយគ្មានអ្នកណាទទួលបន្តនូវសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនាំឱ្យ

---

[98] ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ៦២

បណ្តឹងនោះត្រូវបានបញ្ចប់ ។ តាមធម្មតាបើទោះបីជាមានភាគីណាម្ខាងបានទទួលមរណភាពក៏ដោយក៏សន្តតិជនរបស់ភាគីនោះនឹងត្រូវទទួលបន្តនូវនីតិវិធីនៃបណ្តឹងដែលបានធ្វើពីមុនមក ហើយនីតិវិធីបណ្តឹងសាទុក្ខនោះមិនត្រូវបានបញ្ចប់ទេ ប៉ុន្តែបើមានករណីដែលភាគីដែលបានទទួលមរណភាពនោះពុំមានអ្នកដែលត្រូវទទួលបន្តនូវនីតិវិធីនៃបណ្តឹងដោយសារសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង តុលាការនៃបណ្តឹងសាទុក្ខនឹងចេញសាលដីកាបញ្ចប់បណ្តឹងនោះដោយស្វ័យប្រវត្តដោយមានខ្លឹមសារថា បណ្តឹងសាទុក្ខត្រូវបានបញ្ចប់ដោយសារមរណភាពរបស់ភាគី ។

ក្នុងករណីដែលសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងបានរលត់ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គលនាំឱ្យសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងត្រូវធ្លាក់លើបុគ្គលតែម្នាក់ ហើយដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខបានក្លាយទៅជាបុគ្គលតែមួយដោយសារតែភាគីណាម្ខាងបានទទួលបន្តនូវឋានៈ តាមផ្លូវបណ្តឹងរបស់ភាគីម្ខាងទៀត ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គល ឬដោយសន្តតិកម្ម[99] ។ ករណីនេះតុលាការនឹងចេញសាលដីកាបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តដោយសារតែមានភាគីជាបុគ្គលតែមួយ ។

### ១.២. ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី

សកម្មភាពភាគីមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសកម្មភាពនៃបណ្តឹងផ្នែករដ្ឋប្បវេណី ។ ក្នុងនោះផងដែរសកម្មភាពនៃការដកពាក្យបណ្តឹង ការលះបង់ ឬការទទួលស្គាល់ការទាមទារ និងការសះជាតាមផ្លូវបណ្តឹងរបស់ភាគីនឹងធ្វើឱ្យសកម្មភាពនៃបណ្តឹងត្រូវបញ្ចប់ផងដែរ ។ ការបញ្ចប់បណ្តឹងតាមរយៈសកម្មភាពទាំងនេះហៅថា ការបញ្ចប់បណ្តឹងដោយសកម្មភាពរបស់ភាគី ។

#### ១.២.១. ការដកពាក្យបណ្តឹង

ទោះបីជានីតិវិធីបណ្តឹងកំពុងដំណើការក៏ដោយក៏ដើមបណ្តឹងសាទុក្ខអាចធ្វើការដកពាក្យបណ្តឹងទាំងអស់ ឬមួយផ្នែកបានដែររហូតដល់ពេលដែលតុលាការនៃបណ្តឹងសាទុក្ខចេញសាលដីកាចុងក្រោយ ។ ដោយហេតុថា បណ្តឹងជាសកម្មភាពរបស់ដើមបណ្តឹងក្នុងការទាមទារឱ្យតុលាការនៃបណ្តឹងសាទុក្ខចេញសេចក្តីសម្រេចលុបចោល ឬកែប្រែសាលដីកាដើម ឬសាលក្រមដើម ដូច្នេះការដកពាក្យបណ្តឹងធ្វើឡើងតាមឆន្ទៈរបស់ដើមបណ្តឹងប៉ុណ្ណោះ ហេតុនេះចុងបណ្តឹងសាទុក្ខពុំមានសិទ្ធិដកពាក្យបណ្តឹងឡើយ ។ ក៏ប៉ុន្តែ ក្រោយពីចុងបណ្តឹងសាទុក្ខបានដាក់ឯកសារត្រៀមជាលើកដំបូងតាមការបង្គាប់របស់តុលាការ ឬបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ ការដកពាក្យបណ្តឹងសាទុក្ខដោយផ្អែកតែទៅលើឆន្ទៈរបស់ដើមបណ្តឹងសាទុក្ខពុំមានអានុភាពឡើយ លើកលែងតែមានការយល់ព្រមពីចុងបណ្តឹងសាទុក្ខផងដែរ ។ ពីព្រោះថា ចុងបណ្តឹងសាទុក្ខបានឆ្លើយ

[99] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៦, ២៧៣, ១៧៤

តបទៅនឹងការទាមទាររបស់ដើមបណ្តឹង ហើយចុងបណ្តឹងសាទុក្ខក៏មានផលប្រយោជន៍ក្នុងការទទួលបានសាលដីកាឈ្នះក្តីដែរ[100] ។

### ក. ល័ក្ខខ័ណ្ឌចាំបាច់នៃការដកពាក្យបណ្តឹងសាទុក្ខ

ការដកពាក្យបណ្តឹងសាទុក្ខត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ប៉ុន្តែនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ការដកពាក្យបណ្តឹងរបស់ដើមបណ្តឹងសាទុក្ខអាចធ្វើឡើងដោយផ្ទាល់មាត់ក៏បាន[101] ។ នៅពេលដែលមានការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវចុះអំពីការដកពាក្យបណ្តឹងនោះនៅក្នុងកំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីកុំឱ្យមានវិវាទនៅពេលក្រោយ[102] ។ ប្រសិនបើការដកពាក្យបណ្តឹងធ្វើឡើងជាលាយល័ក្ខណ៍អក្សរ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវបញ្ជូនលិខិតដកពាក្យបណ្តឹងនោះទៅចុងបណ្តឹងសាទុក្ខ ។ បើចុងបណ្តឹងសាទុក្ខមិនប្តឹងតវ៉ាក្នុងអំឡុងពេល ០២ សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូនលិខិតដកពាក្យបណ្តឹងទេ ត្រូវបានចាត់ទុកថាចុងបណ្តឹងសាទុក្ខបានយល់ព្រមនឹងការដកពាក្យបណ្តឹងនេះ ។ បើដើមបណ្តឹងសាទុក្ខធ្វើការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែចុងបណ្តឹងសាទុក្ខបានអវត្តមាននៅកាលបរិច្ឆេទនោះ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបញ្ជូនឯកសារចម្លងនៃកំណត់ហេតុដែលបានចុះអំពីការដកពាក្យបណ្តឹងនោះទៅចុងបណ្តឹងសាទុក្ខ ។ ក្នុងអំឡុងពេល ០២ សប្តាហ៍បន្ទាប់ពីបានទទួលនូវការបញ្ជូននោះ បើចុងបណ្តឹងសាទុក្ខមិនបានធ្វើការតវ៉ាទេ ត្រូវចាត់ទុកថាខ្លួនបានយល់ព្រមចំពោះការដកពាក្យបណ្តឹងសាទុក្ខនោះផងដែរ ។ ប៉ុន្តែបើដើមបណ្តឹងសាទុក្ខធ្វើការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលភាគីចុងបណ្តឹងសាទុក្ខមានវត្តមាននៅកាលបរិច្ឆេទនោះដែរ ហើយចុងបណ្តឹងសាទុក្ខមិនបានតវ៉ាក្នុងអំឡុងពេល ០២ សប្តាហ៍គិតពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នោះក៏ត្រូវចាត់ទុកថា ចុងបណ្តឹងសាទុក្ខបានយល់ព្រមចំពោះការដកពាក្យបណ្តឹងនោះដែរ[103] ។

ត្រូវចាត់ទុកថាដកពាក្យបណ្តឹងផងដែរ ក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយភាគីទាំងពីរមិនបានដាក់ពាក្យសុំឱ្យ

[100] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៧ កថាខណ្ឌទី១, ២៩៣

[101] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៧ កថាខណ្ឌទី៣

[102] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១១៩ កថាខណ្ឌទី១ ចំណុច ក

[103] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២១៧ កថាខណ្ឌទី៤ និង៥

តុលាការនៃបណ្តឹងសាទុក្ខកំណត់កាលបរិច្ឆេទនោះជាថ្មីម្តងទៀត ក្នុងអំឡុងពេល ០១ (មួយ) ខែទេ នោះក៏ត្រូវចាត់ទុកថាបានដកពាក្យបណ្តឹងសាទុក្ខដែរ ។ ហើយបើភាគីទាំងសងខាងមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីរដងជាប់គ្នាក៏ត្រូវចាត់ទុក្ខថាបានដកពាក្យបណ្តឹងសាទុក្ខផងដែរ[104] ។

ការដកពាក្យបណ្តឹងសាទុក្ខជាសកម្មភាពមួយយ៉ាងសំខាន់ដែលធ្វើឱ្យនីតិវិធីបណ្តឹងត្រូវបានបញ្ចប់ ហេតុនេះ សកម្មភាពនេះត្រូវធ្វើឡើងដោយជនដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង ។ ចំពោះអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើការដកពាក្យបណ្តឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ លើកលែងតែអនីតិជនដែលអាចធ្វើសកម្មភាពដោយឯករាជ[105] ។ ចំពោះជននៅក្រោមហិតូបត្ថម្ភ ឬអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវមានការប្រគល់សិទ្ធិពិសេសដើម្បីធ្វើសកម្មភាពដកពាក្យបណ្តឹងសាទុក្ខបាន[106] ។ ចំណែកអ្នកតំណាងដោយអាណត្តិដែលមានការប្រគល់សិទ្ធិរួចហើយ ការកំណត់សិទ្ធិដកពាក្យបណ្តឹង ឬធ្វើសកម្មភាពផ្សេងៗទៀតភាគីអាចកម្រិតសិទ្ធិតំណាងនៅក្នុងកិច្ចសន្យាអាណត្តិនោះបាន[107] ។

### ខ. អានុភាពនៃការដកពាក្យបណ្តឹងសាទុក្ខ

ពាក្យបណ្តឹងសាទុក្ខ អាចដកតែមួយផ្នែក ឬទាំងមូលនៅពេលដែលមានការដកពាក្យបណ្តឹងនោះត្រូវបានធ្វើឡើង ផ្នែកដែលត្រូវបានដក ឬបណ្តឹងទាំងមូលត្រូវបានចាត់ទុកថាមិនបានចាត់ការតាំងពីដំបូង ហើយរឿងក្តីត្រូវរលត់ដោយអានុភាពប្រតិសកម្ម ។ ពោលគឺត្រូវចាត់ទុកថា តុលាការមិនបានចាត់ការបណ្តឹងនោះតាំងពីដំបូងមកម្ល៉េះ ចំណែកឯសកម្មភាពរបស់តុលាការ និងភាគីដែលបានធ្វើកន្លងមករហូតដល់ពេលដកពាក្យបណ្តឹងសាទុក្ខនោះក៏ត្រូវបាត់បង់អានុភាពដែរ[108] ។ ប្រសិនបើមានការដកពាក្យបណ្តឹងសាទុក្ខនាំឱ្យអានុភាពនៃសាលដីកាដើម ឬសាលក្រមដើមត្រូវចូលជាស្ថាពរ(ក្នុងករណីអំឡុងពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខបានកន្លងផុត) ក៏ប៉ុន្តែ ដើមបណ្តឹងសាទុក្ខមិនអាចធ្វើការដកពាក្យបណ្តឹងសាទុក្ខបានឡើយបើតុលាការនៃបណ្តឹងសាទុក្ខបានប្រកាសសាលដីកា ។

### គ. ការសងពន្ធដាក់ពាក្យបណ្តឹង

នៅពេលដែលដើមបណ្តឹងសាទុក្ខបានធ្វើការដកពាក្យបណ្តឹងសាទុក្ខ នៅមុនពេលចប់កាល

---

104 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២១៩

105 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី៣

106 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣ កថាខណ្ឌទី២

107 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤ កថាខណ្ឌទី៣

108 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២១៨

បរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើមបណ្តឹងសាទុក្ខអាចដាក់ពាក្យសុំឱ្យតុលាការនៃបណ្តឹងសាទុក្ខសងមកវិញនូវចំនួនពាក់កណ្តាលនៃពន្ធដាក់ពាក្យបណ្តឹងដែលខ្លួនបានបង់ទៅតុលាការរួចមកហើយ[109] ។

### ១.២.២. ការលះបង់ ឬការទទួលស្គាល់នូវការទាមទារ

#### ក. និយមន័យ

ការលះបង់ការទាមទារ ឬការទទួលស្គាល់នូវការទាមទារ គឺជាសេចក្តីថ្លែងការណ៍របស់ភាគីដែលធ្វើឱ្យមានការខូចផលប្រយោជន៍របស់ខ្លួន(ទទួលស្គាល់ថា ការទាមទាររបស់ខ្លួនពុំមានមូលហេតុត្រឹមត្រូវ ឬទទួលស្គាល់ថាការទាមទាររបស់ភាគីម្ខាងទៀតមានមូលហេតុត្រឹមត្រូវ) ចំពោះការទាមទារ[110] ។ ដោយការលះបង់ ឬការទទួលស្គាល់នូវការទាមទារជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងដែលភាគីម្ខាងទទួលស្គាល់ពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទារ ហើយវិវាទរវាងភាគីទាំងសងខាងត្រូវបានដោះស្រាយដោយសេចក្តីថ្លែងការណ៍នេះ សកម្មភាពទាំងនេះនាំឱ្យបណ្តឹងត្រូវបានបញ្ចប់ដោយមិនចាំបាច់រងចាំសាលដីកាទេ ។

#### ខ. ល័ក្ខខ័ណ្ឌចាំបាច់នៃការលះបង់ ឬការទទួលស្គាល់នូវការទាមទារ

ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ គឺជាសកម្មភាពបណ្តឹងមួយយ៉ាងសំខាន់ក្នុងការបញ្ចប់នីតិវិធីនៃបណ្តឹងសាទុក្ខ ដូច្នេះហើយភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹង ។ ចំពោះអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើការលះបង់ ឬទទួលស្គាល់នូវការទាមទារមានសុពលភាពបាន លុះត្រាតែត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់ លើកលែងតែអនីតិជនដែលអាចធ្វើសកម្មភាពដោយឯករាជ្យ[111] ។ រីឯជននៅក្រោមហិត្ថបត្ថម្ភ ឬអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវមានការប្រគល់សិទ្ធិពិសេសដើម្បីធ្វើសកម្មភាពក្នុងការលះបង់ការទាមទារ ឬទទួលស្គាល់នូវការទាមទារនេះ[112] ។ ចំណែកឯអ្នកតំណាងដោយអាណត្តិក្រោយពីបានទទួលការប្រគល់សិទ្ធិអាចធ្វើការលះបង់ ឬទទួលស្គាល់នូវការទាមទារបានចំពោះរឿងក្តីដែលខ្លួនធ្វើជាអ្នកតំណាងនោះ គឺអាស្រ័យទៅលើកិច្ចសន្យាអាណត្តិនោះ[113] ។

#### គ. អានុភាពនៃការលះបង់ ឬការទទួលស្គាល់នូវការទាមទារ

ក្នុងករណីដែលមានការលះបង់ ឬមានការទទួលស្គាល់នូវការទាមទារតុលាការនៃបណ្តឹង

---

[109] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១ កថាខណ្ឌទី៨ ចំណុច ខ

[110] មេធាវី អ៊ីវ ប៉ូលី, *មេរៀនសង្ខេបនីតិវិធីរដ្ឋប្បវេណី* (បោះពុម្ពលើកទី១ ឆ្នាំ២០១០), ទំព័រ៩២

[111] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី៣

[112] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣ កថាខណ្ឌទី២

[113] ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់ អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្តឹង* (ភ្នំពេញ ឆ្នាំ២០០៨) ទំព័រ១៦២

សាទុក្ខ ត្រូវពិនិត្យអំពីល័ក្ខខ័ណ្ឌនៃបណ្ដឹង និងល័ក្ខខ័ណ្ឌសមត្ថភាពរបស់ភាគីនោះ បើពិនិត្យទៅឃើញថាភាគីមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ក្នុងការលះបង់ ឬទទួលស្គាល់នូវការទាមទារក្រឡាបញ្ជីត្រូវចុះក្នុងកំណត់ហេតុនាំឱ្យបណ្ដឹងត្រូវបានបញ្ចប់ ហើយកំណត់ហេតុនោះមានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរដែរ ។ ម្យ៉ាងវិញទៀត កំណត់ហេតុដែលបានចុះអំពីការលះបង់នូវការទាមទាររបស់ដើមបណ្ដឹងសាទុក្ខមានអានុភាពដូចគ្នានឹងសាលដីកាដែលច្រានចោលនូវការទាមទាររបស់ដើមបណ្ដឹងសាទុក្ខដែរ ។ ចំណែកឯ កំណត់ហេតុដែលចុះអំពីការទទួលស្គាល់នូវការទាមទាររបស់ចុងបណ្ដឹងសាទុក្ខ មានអានុភាពដូចគ្នានឹងសាលដីកាដែលទទួលស្គាល់នូវការទាមទាររបស់ដើមបណ្ដឹងសាទុក្ខដែរ[114] ។

### ១.២.៣. ការសះជាតាមផ្លូវបណ្ដឹង

#### ក. និយមន័យ

ការសះជាតាមផ្លូវបណ្ដឹង គឺជាសកម្មភាពមួយដែលដើមបណ្ដឹងសាទុក្ខ និងចុងបណ្ដឹងសាទុក្ខធ្វើសម្បទានឱ្យគ្នាទៅវិញទៅមកនូវការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង ហើយព្រមព្រៀងគ្នាបញ្ចប់វិវាទនៅក្នុងនីតិវិធីបណ្ដឹង នៅចំពោះមុខតុលាការនៃបណ្ដឹងសាទុក្ខ[115] ។

#### ខ. ល័ក្ខខ័ណ្ឌចាំបាច់នៃការសះជាតាមផ្លូវបណ្ដឹង

ការសះជាតាមផ្លូវបណ្ដឹងក៏ជាសកម្មភាពបណ្ដឹងដែរ ដូច្នេះដើម្បីធ្វើការសះជាបានភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹងសាទុក្ខ ដូច្នេះបើមានភាគីណាមួយជាបុគ្គលដែលត្រូវបានកម្រិតសមត្ថភាពបានធ្វើការសះជានោះពុំមានអានុភាពឡើយ ។ ចំពោះការតំណាងដោយអាណត្តិសម្រាប់ភាគី អ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ មានលក្ខណៈដូចគ្នានឹងការលះបង់ ឬការទទួលស្គាល់នូវកាទាមទារដែរ ។

ក្រៅពីល័ក្ខខ័ណ្ឌសមត្ថភាពរបស់ភាគី នៅមានល័ក្ខខ័ណ្ឌអំពីការទាមទារ ដោយសារការសះជានាំឱ្យមានការចាត់ចែងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង ដូច្នេះហើយច្បាប់អនុញ្ញាតឱ្យសះជាបានចំពោះតែបណ្ដឹងណាដែលយកគោលការណ៍នៃសិទ្ធិចាត់ចែងមកធ្វើជាមូលដ្ឋានប៉ុណ្ណោះ ម្យ៉ាងវិញទៀត ដោយការសះជានាំឱ្យមានការព្រមព្រៀងបញ្ចប់វិវាទដោយភាគីធ្វើសម្បទានឱ្យគ្នាទៅវិញទៅមក ដូច្នេះ ពុំមានការកម្រិតនៃការធ្វើសម្បទាននោះទេ ប៉ុន្តែទោះបីជាយ៉ាងណាក៏

---

114 ក្រសួងយុត្តិធម៌, *សេចក្ដីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្ដឹង* (ភ្នំពេញ ឆ្នាំ២០០៨) ទំព័រ១៦៣

115 មេធាវី អ៊ីវ ប៉ូលី, *មេរៀនសង្ខេបនីតិវិធីរដ្ឋប្បវេណី* (បោះពុម្ពលើកទី១ ឆ្នាំ២០១០), ទំព័រ៩៣

ដោយក៏សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលកំណត់នៅក្នុងការសះជាចាំបាច់ត្រូវតែធ្វើឡើងស្របតាមច្បាប់ ដែលមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទំលាប់ល្អរបស់សង្គម[116] ។

### គ. វិធីសះជាតាមផ្លូវបណ្តឹង

ភាគីអាចបញ្ចប់នីតិវិធីបណ្តឹង តាមរយៈការសម្រុះសម្រួលគ្នាចំពោះទំនាក់ទំនងនៃសិទ្ធិដែលជាចំណុចវិវាទ ដោយភាគីទាំងសងខាងចាំបាច់ត្រូវបង្ហាញខ្លួននៅចំពោះមុខតុលាការនៃបណ្តឹងសាទុក្ខនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយព្រមព្រៀងគ្នាដោយផ្ទាល់មាត់ស្តីពីការបញ្ចប់វិវាទនោះ[117] ។

### ឃ. អានុភាពនៃការសះជា

#### ឃ.១. អានុភាពបញ្ចប់បណ្តឹង

ដោយការសះជា គឺជាការព្រមព្រៀងបញ្ចប់វិវាទរបស់ភាគីនៃបណ្តឹងសាទុក្ខដែលបានកត់ត្រានៅក្នុងកំណត់ហេតុ ហេតុនេះហើយលទ្ធផលនៃការសះជាតាមផ្លូវបណ្តឹងនេះ នាំឱ្យនីតិវិធីនៃបណ្តឹងសាទុក្ខត្រូវបានបញ្ចប់ផងដែរ ។

#### ឃ.២. អានុភាពអនុវត្ត

កំណត់ហេតុនៃការសះជា មានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរដែរ ដូច្នេះហើយកំណត់ហេតុសះជាត្រូវមានអានុភាពអនុវត្ត ប្រសិនបើក្នុងណត់ហេតុនេះមានចុះអំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកជាក់ស្តែងដោយមានការកំណត់ពេលអនុវត្ត និងបែបផែននៃការអនុវត្ត ហើយកំណត់ហេតុនេះក្លាយទៅជាលិខិតអនុវត្តដែលភាគីអាចសម្រេចនូវសិទ្ធិទាមទារតាមរយៈការអនុវត្តដោយបង្ខំបាន[118] ។

#### ឃ.៣. អានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ

បើទោះបីជាកំណត់ហេតុសះជា មានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរក៏ដោយ កំណត់ហេតុនេះមិនមានអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុឡើយ ដោយសារតែការសះជាតាមផ្លូវបណ្តឹង គឺជាការបញ្ចប់វិវាទដែលមានខ្លឹមសារនៃទំនាក់ទំនងគតិយុត្តផ្អែកលើការព្រមព្រៀងរបស់ភាគីជាមូលដ្ឋានវាមានលក្ខណៈខុសពីសាលដីកាដែលធ្វើការសម្រេចសេចក្តីដោយផ្អែកលើភស្តុតាង ដែលអនុវត្តច្បាប់ចំពោះអង្គហេតុនោះ ។ បើការសះជាតាមផ្លូវបណ្តឹងមានវិការៈភាគីអាចអះអាងអំពីមោឃភាព ឬការលុបចោលការសះជានោះដោយយកវិការៈក្នុងការបង្ហាញឆន្ទៈមកធ្វើជាមូលហេតុនៅពេលក្រោយបាន ។ ករណីមានជម្លោះអំពីអានុភាពនៃការសះជានេះ នោះនីតិវិធីនៃការដោះ

---

116 មេធាវី អ៊ីវ ប៉ូលី, *មេរៀនសង្ខេបនីតិវិធីរដ្ឋប្បវេណី* (បោះពុម្ពលើកទី១ ឆ្នាំ២០១០), ទំព័រ៨៤

117 ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្តឹង* (ភ្នំពេញ ឆ្នាំ២០០៨) ទំព័រ១៦៣

118 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២២២ និងមាត្រា៣៥០ កថាខណ្ឌទី២ ចំណុច ឈ

ស្រាយជម្លោះនេះមិនមែនជាការសុំជំនុំជម្រះសាជាថ្មីដូចករណីសាលដីកាទេ គឺគ្រាន់តែជាការស្នើសុំឱ្យតុលាការនៃបណ្ដឹងសាទុក្ខកំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីតែប៉ុណ្ណោះ[119] ។

ការស្នើសុំឱ្យតុលាការនៃបណ្ដឹងសាទុក្ខ កំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មី គឺដើម្បីបន្តនីតិវិធីនៃបណ្ដឹងដោយហេតុថា បណ្ដឹងមិនទាន់បានបញ្ចប់នៅឡើយដោយសារតែមោឃភាពនៃការសះជា ។ បើសិនជាមានពាក្យសុំឱ្យតុលាការនៃបណ្ដឹងសាទុក្ខកំណត់នូវកាលបរិច្ឆេទជាថ្មីម្ដងទៀតដោយមានមូលហេតុមានវិការៈក្នុងការសះជា តុលាការនៃបណ្ដឹងសាទុក្ខចាំបាច់ត្រូវកំណត់ នូវកាលបរិច្ឆេទនោះម្ដងទៀតតាមពាក្យសុំរបស់ភាគី ហើយនៅកាលបរិច្ឆេទជាថ្មីនេះ តុលាការនៃបណ្ដឹងសាទុក្ខត្រូវវិនិច្ឆ័យជាមុនថា ការសះជាដែលបានធ្វើពីមុននោះមានសុពលភាព ឬគ្មានសុពលភាព ។ បើការវិនិច្ឆ័យឃើញថា ការសះជានោះមានវិការៈ តុលាការនៃបណ្ដឹងសាទុក្ខត្រូវធ្វើការបញ្ជាក់ថា បណ្ដឹងនោះមិនទាន់ត្រូវបានបញ្ចប់ទេ ហើយត្រូវបន្តការវិនិច្ឆ័យលើបណ្ដឹងនោះ ។ ប៉ុន្តែ បើវិនិច្ឆ័យឃើញថា ការសះជាដែលបានធ្វើពីមុននោះមានសុពលភាព តុលាការនៃបណ្ដឹងសាទុក្ខត្រូវចេញសាលដីកាដែលប្រកាសអំពីការបញ្ចប់បណ្ដឹងដោយ ការសះជានោះ[120] ។

### ង. បន្ទុកនៃប្រាក់ប្រដាប់ក្ដី

បើបណ្ដឹងត្រូវបានបញ្ចប់ដោយការសះជា ភាគីដែលត្រូវទទួលបន្ទុកនៃប្រាក់ប្រដាប់ក្ដី គឺអាស្រ័យទៅលើការព្រមព្រៀងរបស់ភាគីនោះ ប៉ុន្តែប្រសិនបើភាគីគ្មានការព្រមព្រៀងគ្នាអំពីប្រាក់ប្រដាប់ក្ដីទេ ភាគីនីមួយៗត្រូវទទួលបន្ទុកក្នុងការបង់រៀងៗខ្លួន ។ បើការសះជា បានសម្រេចលទ្ធផលមុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដើមបណ្ដឹងសាទុក្ខ ទទួលបានការសងមកវិញនូវចំនួនពាក់កណ្ដាលនៃពន្ធដែលបានបង់រួចមកហើយ[121] ។

## ២. ការបញ្ចប់បណ្ដឹងដោយសេចក្ដីសម្រេចរបស់តុលាការ

### ២.១. ដីកាលើកចោលបណ្ដឹងសាទុក្ខ

បណ្ដឹងសាទុក្ខនឹងត្រូវតុលាការលើកចោល ប្រសិនបើបណ្ដឹងសាទុក្ខដែលធ្វើនោះមិនស្របច្បាប់ និងមិនអាចកែតម្រូវបានដូចជា ភាគីខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬបណ្ដឹងធ្វើឡើងហួស

119 មេធាវី អ៊ីវ ប៉ូលី, *មេរៀនសង្ខេបនីតិវិធីរដ្ឋប្បវេណី* (បោះពុម្ពលើកទី១ ឆ្នាំ២០១០), ទំព័រ៩៩

120 ក្រសួងយុត្តិធម៌, *សេចក្ដីពន្យល់ អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្ដឹង* (ភ្នំពេញ ឆ្នាំ២០០៨) ទំព័រ៦៦

121 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ និង មាត្រា ៦១ កថាខណ្ឌទី៨ ចំណុច ខ

អំឡុងពេលដែលច្បាប់បានកំណត់ ឬដើមបណ្តឹងសាទុក្ខមិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឬបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរួចហើយ តែមិនបានធ្វើការកែតម្រូវនូវចំណុចខ្វះខាតក្នុងអំឡុងពេលដែលតុលាការនៃបណ្តឹងសាទុក្ខបានកំណត់ទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវលើកបណ្តឹងសាទុក្ខនោះចោលដោយដីការសម្រេច[122] ។

### ២.២. សាលដីកាចុងក្រោយ

#### ២.២.១.សាលដីកាច្រានចោលបណ្តឹងសាទុក្ខ

ការជំនុំជម្រះបណ្តឹងសាទុក្ខគឺតុលាការធ្វើការវិនិច្ឆ័យតែទៅលើអង្គច្បាប់តែប៉ុណ្ណោះ ហេតុនេះហើយតុលាការអាចសម្រេចច្រានចោលបណ្តឹងសាទុក្ខបាន ដោយគ្រាន់តែពិនិត្យមើលឯកសារជាលាយល័ក្ខណ៍អក្សរក៏ជាការគ្រប់គ្រាន់ ។ ប្រសិនបើក្រោយពីបានពិនិត្យពាក្យបណ្តឹងសាទុក្ខ ឬលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឬមួយឯកសារត្រៀមដែលចុងបណ្តឹងសាទុក្ខបានដាក់លើកដំបូង ឬឯកសាផ្សេងទៀត ហើយពិនិត្យឃើញថា បណ្តឹងសាទុក្ខនោះធ្វើឡើងដោយមិនសំអាងលើមូលហេតុទូទៅនៃបណ្តឹងសាទុក្ខ ឬមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ ដើម្បីធ្វើបណ្តឹងសាទុក្ខទេ តុលាការអាចច្រានចោលបណ្តឹងនោះដោយសាលដីកា ដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ក៏បាន[123] ។ ប៉ុន្តែ ប្រសិនបើតុលាការនៃបណ្តឹងសាទុក្ខបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយពិនិត្យឃើញថា បណ្តឹងនោះមិនមានមូលហេតុទូទៅ ឬមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ ឬមួយពិនិត្យឃើញថាសំអាងហេតុនៅក្នុងសាលក្រម ឬសាលដីការបស់តុលាការដើមមិនត្រឹមត្រូវក៏ដោយក៏តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលនូវបណ្តឹងសាទុក្ខនោះដែរបើយល់ឃើញថា សេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬសាលដីកានោះត្រឹមត្រូវដោយផ្អែកលើសំអាងហេតុផ្សេងទៀត[124] ។

#### ២.២.២ សាលដីកាទទួលស្គាល់បណ្តឹងសាទុក្ខ

ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់បណ្តឹងសាទុក្ខថាមានភាពត្រឹមត្រូវនោះតុលាការត្រូវបដិសេធចោលនូវសាលក្រម ឬសាលដីការបស់តុលាការដើម ។ ហើយតុលាការត្រូវសម្រេចបញ្ជូនរឿងក្តីនោះត្រឡប់ទៅតុលាការដើមវិញ ឬផ្ទេររឿងក្តីនោះទៅតុលាការផ្សេងទៀតដែលមានថ្នាក់ដូចគ្នា ឬក៏យកមកធ្វើការវិនិច្ឆ័យដោយខ្លួនឯង[125] ។

[122] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៩០

[123] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា២៩៤

[124] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៦, ២៧៧

[125] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៩៩ កថាខណ្ឌទី១

### ក. ការបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញ

ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់ថា ពាក្យបណ្តឹងសាទុក្ខនោះមានមូលហេតុត្រឹមត្រូវ(មូលហេតុទូទៅ ឬមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ) តុលាការនៃបណ្តឹងសាទុក្ខត្រូវបដិសេធចោលនូវសាលដីកា ឬសាលក្រមដើម ហើយត្រូវបញ្ជូនរឿងក្តីនោះត្រឡប់ទៅតុលាការដើមវិញ ។ តុលាការដែលបានទទួលរឿងក្តីដោយការបញ្ជូនត្រឡប់មកវិញ ត្រូវធ្វើការសម្រេចសេចក្តីដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីម្តងទៀត ។ ចំនួនចៅក្រម និងសមាសភាពចៅក្រមនៃតុលាការដែលទទួលការបញ្ជូនត្រឡប់មកវិញត្រូវមានការផ្លាស់ប្តូរ ។ ករណីដែលបញ្ជូនសាលដីកា របស់សាលាឧទ្ធរណ៍ត្រឡប់មកវិញ ការជំនុំជម្រះលើកទី២ របស់សាលាឧទ្ធរណ៍នេះ ត្រូវធ្វើឡើងដោយមានចៅក្រម ០៥(ប្រាំ) រូប ហើយត្រូវតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះលើកមុន[126] ។ ករណីការបញ្ជូនសាលក្រមត្រឡប់មកសាលដំបូងវិញ ទោះបីជាការជំនុំជម្រះលើកមុនត្រូវបានធ្វើឡើងដោយចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមក្តី ក៏ចំនួនចៅក្រមនៃការជំនុំជម្រះលើកទី២ មិនមានការផ្លាស់ប្តូរដែរ ប៉ុន្តែ មិនមែនជាចៅក្រមដែលបានចូលរួមជំនុំជម្រះលើកមុនឡើយ ។ ចំពោះសេចក្តីវិនិច្ឆ័យលើអង្គហេតុ និងអង្គច្បាប់ដែលតុលាការនៃបណ្តឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធចោលសាលក្រម ឬសាលដីការបស់តុលាការដើមត្រូវមានចំណងទៅលើតុលាការដែលបានទទួលការបញ្ជូន ឬការផ្ទេរ[127] ។ អានុភាពចងនៃសេចក្តីវិនិច្ឆ័យលើអង្គច្បាប់ គឺតុលាការដែលបានទទួលការបញ្ជូន ឬការផ្ទេរនោះមិនអាចធ្វើសេចក្តីវិនិច្ឆ័យអំពីចំណុចដែលពាក់ព័ន្ធនឹងអង្គច្បាប់ ដែលមាននៅក្នុងសាលដីកាដើម ឬសាលក្រមដើមបានទេដោយសារវាបានក្លាយទៅជាមូលហេតុនៃការបដិសេធចោលរបស់តុលាការនៃបណ្តឹងសាទុក្ខ ។ រីឯអានុភាពចងនៃសេចក្តីវិនិច្ឆ័យលើអង្គហេតុ ត្រូវបានកម្រិតតែសេចក្តីវិនិច្ឆ័យអំពីអង្គហេតុដែលតុលាការនៃបណ្តឹងសាទុក្ខអាចវិនិច្ឆ័យបាន[128] ។

### ខ. ការផ្ទេររឿងក្តីទៅតុលាការផ្សេង

ជាគោលការណ៍ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬសាលក្រមដើម តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីនោះត្រឡប់ទៅតុលាការដើមវិញ ក៏ប៉ុន្តែ ក្នុងករណីដូចជា តុលាការដើមមិនអាចរកចៅក្រមផ្សេងមកជំនួសចៅក្រមដែលមានការទាក់ទងនឹងការចេញសាលដីកាដើម ឬសាលក្រមដើមដែលត្រូវបានតុលាការនៃបណ្តឹងសាទុក្ខបដិសេធ

[126] ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៣៩ កថាខណ្ឌទី២

[127] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៩៩

[128] ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់ អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្តឹង* (ភ្នំពេញ ឆ្នាំ២០០៨) ទំព័រ២២២

ចោលនោះដោយសារតែចំនួនចៅក្រមនៅក្នុងតុលាការដើមនោះមិនគ្រប់គ្រាន់ តុលាការនៃបណ្តឹងសាទុក្ខត្រូវផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា ។ ការកំណត់បែបនេះក្នុងគោលបំណងជៀសវាងការយឺតយ៉ាវ ឬការរាំងស្ទះដល់ដំណើការនៃនីតិវិធីបណ្តឹង[129] ។ ចំពោះតុលាការដែលទទួលការផ្ទេររឿងក្តីនេះ ត្រូវធ្វើការសម្រេចសេចក្តីដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់សារជាថ្មី ហើយចំនួនចៅក្រមត្រូវអនុវត្តដូចគ្នានឹងករណីបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញដែរ ។ ចំណែកឯភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក ។

### គ.ការបដិសេធចោល ហើយធ្វើការវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបដិសេធសាលក្រមដើម ឬសាលដីកាដើម ហើយយករឿងក្តីនោះមកធ្វើការសម្រេចសេចក្តីដោយខ្លួនឯងវិញ ប្រសិនបើក្រោយពីបានពិនិត្យទៅឃើញថា ៖

- ការជំនុំជម្រះរបស់តុលាការដើមមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្តចំពោះអង្គហេតុ ដែលបានចូលជាស្ថាពរ ហើយតុលាការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តី អំពីរឿងក្តីនោះដោយផ្អែកលើអង្គហេតុនេះបាន ។ មានន័យថាតុលាការនៃបណ្តឹងសាទុក្ខអាចធ្វើការវិនិច្ឆ័យដោយខ្លួនឯងជំនួសសាលក្រម ឬសាលដីកាដើមនោះបានក្នុងករណីដែលសាលក្រម ឬសាលដីកានោះធ្វើឡើងដោយមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តលើអង្គហេតុដែលបានកំណត់ជាស្ថាពរនៅក្នុងសាលក្រម ឬសាលដីកាដើមនោះប៉ុណ្ណោះ ។
- ការជំនុំជម្រះរឿងក្តីរបស់តុលាការដើមមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ ។ មានន័យថា តុលាការដើមបានធ្វើការជំនុំជម្រះលើរឿងក្តីដែលខ្លួនគ្មានសិទ្ធិដើម្បីធ្វើការជំនុំជម្រះលើរឿងក្តីនោះ ជាឧទាហរណ៍មានដូចជា ករណីដែលមានអភ័យឯកសិទ្ធិជម្រះក្តីរបស់តុលាការបរទេស និងករណីដែលគ្មានសមត្ថកិច្ចជម្រះក្តីអន្តរជាតិ ជាដើម[130] ។

---

[129] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា២៩៩

[130] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ ឆ្នាំ២០០៧) កំណត់មាត្រា៣០០ កថាខណ្ឌទី៤

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

បណ្តឹងសាទុក្ខនៃរឿងក្តីរដ្ឋប្បវេណីគឺជាប្រភេទមួយនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។ បណ្តឹងសាទុក្ខក្នុងរឿងក្តីរដ្ឋប្បវេណីមានលក្ខណៈពិសេសខុសពីបណ្តឹងផ្សេងៗទៀតត្រង់ថាបណ្តឹងនេះធ្វើបានចំពោះតែសាលក្រម ឬសាលដីកាចុងក្រោយដែលមិនទាន់ចូលជាស្ថាពរ ហើយការធ្វើបណ្តឹងនេះ គឺធ្វើទៅតុលាការកំពូលដែលជាអង្គកំពូលនៃស្ថាប័នយុត្តាធិការ ។ ជាងនេះទៅទៀតដើម្បីធ្វើបណ្តឹងនេះបានត្រឹមត្រូវតាមច្បាប់ និងទទួលបានការវិនិច្ឆ័យពីសំណាក់តុលាការតាមការធ្វើឧបាស្រ័យរបស់ភាគី លុះណាតែបណ្តឹងនោះបានធ្វើឡើងដោយផ្អែកលើមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តិដែលមានឥទ្ធិពលលើសាលក្រម ឬសាលដីកា ឬការចេញសាលក្រម ឬសាលដីការបស់តុលាការដើមផ្ទុយនឹងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីមានដូចជាតុលាការដែលបានចេញសាលក្រម ឬសាលដីកាមិនត្រូវបានចាត់តាំងទៅតាមច្បាប់ ឬចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចេញសាលក្រម ឬសាលដីកាបានចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាភាពផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខ ការខ្វះសិទ្ធិតំណាងដើម្បីធ្វើសកម្មភាពបណ្តឹង ភាពផ្ទុយនឹងបញ្ញត្តិស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ និងករណីដែលសាលក្រម ឬសាលដីកានោះគ្មានសំអាងហេតុ ឬសំអាងហេតុនោះផ្ទុយគ្នា ។ លើសពីនេះទៅទៀតចំពោះសមាសភាពនៃចៅក្រមដែលធ្វើការវិនិច្ឆ័យបណ្តឹងនេះ មានការប្រែប្រួលទៅតាមនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងនោះ ពោលគឺជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដែលមានចៅក្រម ០៥ រូប ប៉ុន្តែនៅពេលដែលធ្វើការជំនុំជម្រះបណ្តឹងសាទុក្ខលើរឿងក្តីដដែលជាលើកទី២ ត្រូវមានចៅក្រមចំនួន ០៩ រូប ។ ដោយហេតុថាការសម្រេចសេចក្តីរបស់តុលាការកំពូលជាសេចក្តីសម្រេចចុងក្រោយ នោះភាគីមិនអាចធ្វើឧបាស្រ័យទៅតុលាការណាផ្សេងទៀតបានឡើយ ហេតុនេះ សាលដីការបស់តុលាការកំពូលនឹងចូលជាស្ថាពរភ្លាមនៅក្រោយពេលដែលតុលាការកំពូលប្រកាសសាលដីកានោះ ។ ហើយសាលដីកានោះក៏ជាយុត្តិសាស្ត្រសម្រាប់តុលាការថ្នាក់ក្រោមធ្វើការអនុវត្តតាមផងដែរ វាជាយន្តការមួយសម្រាប់ធ្វើឱ្យមានការឯកភាពគ្នានូវចំណុចដែលខ្វែងគំនិតគ្នាក្នុងការអនុវត្តច្បាប់នៃតុលាការថ្នាក់ក្រោមជាច្រើនផ្សេងៗគ្នា ។ ជាគោលការណ៍ក្នុងរឿងក្តីរដ្ឋប្បវេណីការធ្វើបណ្តឹងត្រូវធ្វើតាមដំណាក់កាលនៃឋានានុក្រមរដ្ឋបាលរបស់តុលាការ ពោលគឺការដាក់ពាក្យបណ្តឹងត្រូវចាប់ផ្តើមដំបូងបង្អស់នៅតុលាការសាលាដំបូង ក្រោយពេលដែលសាលាដំបូងបានចេញសាលក្រមចុងក្រោយ ហើយភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ នោះគេអាចធ្វើឧបាស្រ័យទៅសាលាឧទ្ធរណ៍ (បណ្តឹង

ឧទ្ធរណ៍) ដើម្បីឱ្យសាលាឧទ្ធរណ៍ធ្វើការវិនិច្ឆ័យឡើងវិញលើសេចក្តីសម្រេចរបស់សាលាដំបូង នូវចំណុចដែលអ្នកប្តឹងនោះមិនសុខចិត្ត ។ នៅក្រោយពេលដែលសាលាឧទ្ធរណ៍បានចេញសេចក្តីសម្រេចហើយនៅតែមានភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចនោះទៀត ភាគីនោះអាចធ្វើបណ្តឹងសាទុក្ខទៅតុលាការកំពូល ដើម្បីឱ្យតុលាការកំពូលធ្វើការកែប្រែ ឬលុបចោលសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមទាំងនោះ ។ ប៉ុន្តែ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺក្នុងករណីដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃគិតជាប្រាក់មានចំនួនមិនលើសពី ៥.០០០.០០០(ប្រាំលាន) រៀលទេ ភាគីអាចធ្វើការព្រមព្រៀងគ្នាជាលាយលក្ខអក្សរថានៅក្រោយពេលដែលសាលាដំបូងបានចេញសាលក្រមចុងក្រោយភាគីនឹងមិនធ្វើការប្តឹងឧទ្ធរណ៍ឡើយ តែរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ ។ នោះនៅក្រោយពេលដែលសាលាដំបូងចេញសាលក្រមចុងក្រោយមក បើភាគីណាមិនសុខចិត្តនឹងសេចក្តីសម្រេចនោះគេអាចប្តឹងដោយផ្ទាល់ទៅតុលាការកំពូល ដោយមិនចាំបាច់ឆ្លងកាត់សាលាឧទ្ធរណ៍ឡើយ ។ នេះគឺជាគោលការសិទ្ធិចាត់ចែងរបស់ភាគី ហើយក៏ដើម្បីគោរពទៅតាមគោលការណ៍លឿន និងឆាប់រហ័សនៃនីតិវិធីបណ្តឹង ហើយក៏ដើម្បីកាត់បន្ថយនូវការចំណាយរបស់ភាគីផងដែរ ។

ការធ្វើបណ្តឹងសាទុក្ខត្រូវធ្វើក្នុងអំឡុងពេល១ខែ បន្ទាប់ពីបានទទួលនូវការបញ្ជូនលិខិតសាលក្រម ឬសាលដីកា ។ បណ្តឹងត្រូវធ្វើឡើងតាមរយៈការដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការដើម ពោលគឺត្រូវដាក់ពាក្យបណ្តឹងទៅតុលាការដែលបានចេញសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខនោះ ។ នៅពេលដែលដាក់ពាក្យបណ្តឹងនោះ ដើមបណ្តឹងសាទុក្ខក៏ត្រូវបង់ជាមុននូវពន្ធដាក់ពាក្យសុំនៅតុលាការដើមនោះផងដែរ ។ ក្នុងករណីនេះ តុលាការដើមត្រូវធ្វើឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងនោះ និងសំណុំរឿងទៅតុលាការនៃបណ្តឹងសាទុក្ខនោះ ។ នៅពេលដែលពាក្យបណ្តឹងសាទុក្ខ និងសំណុំរឿងត្រូវបានបញ្ជូនមកដល់តុលាការនៃបណ្តឹងសាទុក្ខប្រធានតុលាការត្រូវចេញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមចំនួន ០៥រូប ដែលមានចៅក្រម ០១រូប ធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។ ក្រោយពីទទួលការចាត់តាំងប្រធានក្រុមប្រឹក្សាចេញដីកាចាត់តាំងចៅក្រមណាម្នាក់ក្នុងក្រុមប្រឹក្សានោះឲ្យធ្វើជាចៅក្រមទទួលបញ្ជា ដើម្បីទទួលបន្ទុកចាត់ការសំណុំរឿងនោះ ហើយធ្វើរបាយការណ៍វាយតម្លៃលើអង្គច្បាប់ អំពីសេចក្តីសម្រេចក្នុងសាលក្រម ឬសាលដីកាដែលតុលាការដើមបានចេញ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។ តែទោះជាយ៉ាងនេះក៏ដោយការវាយតម្លៃនេះ មិនចាប់បង្ខំឱ្យក្រុមប្រឹក្សានៃចៅក្រមត្រូវតែសម្រេចតាមការវាយតម្លៃនោះទេ វាគ្រាន់តែជាព័ត៌មាន ឬយោបល់មួយជូនក្រុមប្រឹក្សានៃចៅក្រមប៉ុណ្ណោះ ។ នៅក្រោយពេលដែលបាទទួលសំណុំរឿងចៅក្រមទទួលបញ្ជាត្រូវធ្វើការពិនិត្យពាក្យបណ្តឹងនោះ ហើយចេញដីការបង្គាប់ឱ្យដើមបណ្តឹងសាទុក្ខដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹង

សាទុក្ខនោះ ។ ក្រោយពេលដើមបណ្តឹងសាទុក្ខបានដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ ហើយត្រូវចេញដីកាបង្គាប់ឱ្យចុងបណ្តឹងសាទុក្ខដាក់ឯកសារត្រៀម ឬសារណាតប ហើយធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាជំនុំជម្រះនៃថៅក្រម ដើម្បីកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃថៅក្រមកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និងចេញដីកាកោះហៅភាគី និងលិខិតអញ្ជើញមេធាវីដើម្បីចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ នីតិវិធីជំនុំជម្រះក្តីនៃបណ្តឹងសាទុក្ខមិនមាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ទេ ។ នៅក្រោយពេលបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវប្រកាសសំរាកដើម្បីថយទៅពិចារណា មុនពេលប្រកាសសាលដីកា ឬមួយតុលាការអាចលើកពេលប្រកាសសាលដីកានៅពេលក្រោយក៏បាន សាលដីការបស់តុលាការកំពូលត្រូវចូលជាស្ថាពរភ្លាមក្រោយពេលប្រកាស ។

# អនុសាសន៍

ដោយសង្កេតឃើញស្ថានភាពជាក់ស្តែងប្រទេសជាតិយើងមានការរីកចម្រើនលើគ្រប់វិស័យ ពិសេសវិស័យច្បាប់ គឺជាវិស័យមួយដែលដើរតួនាទីយ៉ាងសំខាន់សំរាប់រក្សាស្ថិរភាព និងការអភិវឌ្ឍន៍សង្គមជាតិ ហើយវាក៏ជាឧបករណ៍មួយដ៏សំខាន់សម្រាប់ការដឹកនាំក៏ដូចជាការគ្រប់គ្រងប្រទេសជាតិឱ្យមានសុខសន្តិភាព សណ្តាប់ធ្នាប់ របៀបរៀបរយល្អ ។ ហេតុនេះ ដើម្បីធានាឱ្យប្រជាជនគ្រប់រូបទោះបីជា កម្មករ និយោជិត និយោជក ជាអ្នកបំរើការនៅក្នុងស្ថាន័បឯកជន ឬមួយក៏ជាមន្ត្រីរាជការសាធារណៈ ត្រូវតែគោរពច្បាប់ទាំងអស់គ្នា ។ ជាពិសេសស្ថាប័ន ឬអង្គភាពដែលមានសមត្ថកិច្ចពាក់ព័ន្ធ ពិសេសតុលាការ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃត្រូវធ្វើយ៉ាងណាដើម្បីឱ្យការអនុវត្តច្បាប់បានត្រឹមត្រូវ និងមានប្រសិទ្ធភាព ។ ជាពិសេសនោះគឺចៅក្រមដែលជាអ្នកកាត់សេចក្តី តំណាងឱ្យស្ថាប័នតុលាការត្រូវជៀសឱ្យឆ្ងាយអំពី អគតិទាំង៤ នៅក្នុងពេលដែលខ្លួនធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តី ។ អគតិទាំងនោះរួមមាន **ឆន្ទាគតិ** សេចក្តីលំអៀងព្រោះស្រលាញ់ **ទោសាគតិ** សេចក្តីលំអៀងព្រោះស្អប់ **មោហាគតិ** សេចក្តីលំអៀងព្រោះល្ងង់ **ភយាគតិ** សេចក្តីលំអៀងព្រោះខ្លាចបុណ្យខ្លាចអំណាច ឬខ្លាចគតិ ។ ចំពោះក្រសួងមហាផ្ទៃនៅពេលដែល តុលាការបានចេញសាលក្រម ឬសាលដីការស្ថាពរហើយ គឺត្រូវខិតខំធ្វើយ៉ាណាដើម្បីធានាថាការ អនុវត្តន៍សាលក្រម ឬសាលដីកាឱ្យបានត្រឹមត្រូវទៅតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ។ ចំពោះប្រព័ន្ធតុលាការក៏គួរតែ ខិតខំធ្វើយ៉ាងណាបង្កើតឱ្យមានចៅក្រមដែលទទួលបន្ទុកជំនុំជម្រះលើរឿងក្តីតែមួយជំនាញបានហើយ ដូចជាចៅក្រម ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ ផ្នែកពាណិជ្ជកម្ម ផ្នែកការងារផ្សេងគ្នា មិនគួរឱ្យចៅក្រមតែម្នាក់ធ្វើការវិនិច្ឆ័យគ្រប់ជំនាញ ដែលនាំឱ្យការសម្រេចសេចក្តីពុំសូវទទួលបាននូវលទ្ធផលល្អ ។ ការបែងចែកបែបនេះ គឺក្នុងគោលបំណងដើម្បីធានាថា ការវិនិច្ឆ័យរឿងក្តីនឹងកាន់តែមានសុក្រឹតភាពដែលភាគីទាំងសងខាងអាចទទួលយកបាន និងមានការស្ងប់ចិត្តនឹងសេចក្តីសម្រេចនោះ ។ ចំណែកឯសាលាជម្រះក្តីជាន់ខ្ពស់ គឺសាលឧទ្ធរណ៍ក៏គួរតែបង្កើតឱ្យមានបន្ថែមទៀតនៅតាមបណ្តាតំបន់នានាដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និងកាត់បន្ថយការចំណាយ និងពេលវេលាក្នុងការស្វែងរកយុត្តិធម៌ ។ ព្រោះថាសព្វថ្ងៃនេះសាលាឧទ្ធរណ៍គឺមាននៅរាជធានីភ្នំពេញតែមួយប៉ុណ្ណោះ ដូច្នេះនៅពេលភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាជម្រះក្តីជាន់ទាប គឺពិតជាមានការលំបាកក្នុងការប្តឹងមកសាលាឧទ្ធរណ៍ណាស់ ជាពិសេសប្រជាជនក្រីក្រដែលរស់នៅតំបន់ដាច់ស្រយាល ។ កត្តាទាំងនេះរួមផ្សំនឹងការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិតផងនោះ ធ្វើឱ្យពួកគាត់ទទួលបាននូវភាពយុត្តិធម៌មិនដូចគ្នាទេ ។ ប្រសិនបើធ្វើការពង្រីកបន្ថែមនូវសាលាឧទ្ធរណ៍ទៅតាមបណ្តាតំបន់នានា គឺមានន័យថាជាការធ្វើឱ្យមានសមភាពផ្នែកយុត្តិធម៌សម្រាប់ប្រជាជននៅទីក្រុង និងជនបទ ។

# ឧបសម្ព័ន្ធ

# រចនាសម្ព័ន្ធតុលាការខ្មែរ
# ឆ្នាំ ១៩៣៧



# រចនាសម្ព័ន្ធតុលាការខ្មែរ
## ឆ្នាំ ១៩៥៩



# រចនាសម្ព័ន្ធក្រុមអយ្យការ
# ព្រះរាជក្រម លេខ ១០៤ ឆ្នាំ ១៩៦២






សាលាឧទ្ធរណ៍
ផ្នែករដ្ឋប្បវេណី
លេខ 903 ម៉ោង 16h
មកដល់ថ្ងៃទី ... 2016

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹងសាទុក

ខ្ញុំបាទឈ្មោះ ៖ អាយុ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅផ្ទះលេខ ផ្លូវលំ ក្រុមទី ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

## សូមគោរពចូលមក
## ឯកឧត្តម ប្រធានសាលាឧទ្ធរណ៍

**កម្មវត្ថុ៖** សុំប្តឹងសាទុកសាលដីកាលេខ ០១ ក្រ VI រ.ន ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៦ របស់សាលាឧទ្ធរណ៍។

**យោង៖**
- សំណុំរឿងរដ្ឋប្បវេណីលេខ ៤១៧ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៥ របស់សាលាឧទ្ធរណ៍
- សាលដីកាលេខ ០១ ក្រ VI រ.ន ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៦ របស់សាលាឧទ្ធរណ៍។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៦ លោកចៅក្រម , , បានសម្រេចសេចក្តីឲ្យ ខ្ញុំដោយអយុត្តិធម៌ ដោយពេលនោះខ្ញុំបាទបានខ្ចីប្រាក់ពីឈ្មោះ ចំនួន ហើយគម្រូឲ្យធ្វើជាកិច្ចសន្យាលក់ទិញទើបគេឲ្យខ្ចីតែមិនធ្វើលិខិតផ្ទេរសិទ្ធិ ឬ ប្រគល់បង្កាន់ដៃអោយទៅគេឡើយ ហើយកាលនោះនៅឆ្នាំ ២០០១ គឺការលក់ទិញដីគឺគេធ្វើលិខិតបែបបទនៃការទិញលក់ដីត្រឹមត្រូវមិនធ្វើតែកិច្ចសន្យាមួយ ហើយចុះហត្ថលេខាត្រឹមភូមិទេ សូមលោកប្រធានពិចារណា! បើសិនជាខ្ញុំលក់ដីនេះឲ្យទៅឈ្មោះ មែន ខ្ញុំប្រាកដជាប្រគល់បង្កាន់ដៃទទួលពាក្យ និងធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីឲ្យហើយ ខ្ញុំមិនដឹងទុកធ្វើអីទេ រួចក៏ត្រូវមានលិខិតប្រគល់ទទួលប្រាក់គ្រប់ចំនួនផងដែរ។

នេះបញ្ជាក់ឲ្យឃើញលោកចៅក្រមទាំងបីនាក់ មិនបានពិចារណាវែងឆ្ងាយឡើយ ហើយលោកចៅក្រមទាំងបីនោះក៏សុទ្ធតែធ្លាប់ទិញដីដែរ តើគាត់ធ្វើបែបនេះ ឬ ?

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលពាក្យបណ្តឹងសាទុករបស់ខ្ញុំបាទដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម ប្រធាន** មេត្តាទទួលនូវការគោរពដ៏ស្មោះអំពីខ្ញុំបាទ។

ធ្វើនៅ, ថ្ងៃទី...០៤.......ខែ...មេសា.......ឆ្នាំ ២០១៦

**ស្នាមមេដៃស្តាំ**

ខាងមេដៃ...
04-04-2016

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA
មេធាវី.៩

ចំណាំ : រាល់ឯកសារក្នុងឧបសម្ព័ន្ធនេះមិនមែនសុទ្ធតែស្ថិតនៅក្នុងសំណុំរឿងតែមួយទេ !

សាលាឧទ្ធរណ៍
លេខៈ 163 ចុះថ្ងៃទី 01
ខែ តុលា ឆ្នាំ ២០14
រឿង 1/១៥
លេខៈ ២២9 ចុះថ្ងៃទី 02
ខែ 05 ឆ្នាំ ២០14

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****************

# សេចក្ដីសុំប្ដឹងសា ទុក្ខ

ឆ្នាំពីរពាន់ ដប់បួន ខែ តុលា ថ្ងៃទី មួយ វេលាម៉ោង ដប់ ព្រឹក
យើង............................................ក្រឡាបញ្ជីសាលាឧទ្ធរណ៍ ។

បានឃើញ......................................................................

ចូលមកចំពោះមុខយើងនៅសាលាឧទ្ធរណ៍ ។ ហើយសុំប្ដឹងសាទុក្ខនឹងសាលដីកា
លេខ 04 ក្រIV តត ចុះថ្ងៃទី 15 ខែ 09 ឆ្នាំ ២០14 ត្រង់ចំណុច ០ស [illegible] ០1 ត
តាំងពីដើម .....................................................................

........................................................................................

........................................................................................

ត្រែងពុំប្រាកដ យើងបានសូត្រសេចក្ដីនេះជូន.........................
ស្ដាប់ ហើយឲ្យចុះហត្ថលេខា ឬ ផ្ដិតមេដៃជាមួយយើង ។

អ្នកប្ដឹង
ស្នាមមេដៃស្ដាំ

ក្រឡាបញ្ជីសាលាឧទ្ធរណ៍
ហត្ថលេខា

........................................................................................

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជំរះ

បានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម
សាលាឧទ្ធរណ៍ ថ្ងៃទី 01 ខែ តុលា ឆ្នាំ ២០14
ក្រឡាបញ្ជី

១០០ រៀល TIMBRE FISCAL

១០០ រៀល TIMBRE FISCAL

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
លេខ 962 ... 01/h
ថ្ងៃទី 03 ... 6 ... 2014

## ពាក្យបណ្តឹងសារទុក្ខ បន្ទាប់បន្សំ

ខ្ញុំបាទឈ្មោះ                    ហៅ                    អាយុ ៧៣ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ
ទីលំនៅសព្វថ្ងៃ ភូមិឬស្សីចារ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ ។

**សូមគោរពចូលមក**

**ឯកឧត្តម ប្រធានសាលាឧទ្ធរណ៍**

**កម្មវត្ថុ:** សំណើសុំប្តឹងសារទុក្ខបន្ទាប់បន្សំលើ សាលដីការដ្ឋប្បវេណីលេខ ១០ក្រIV(ច) ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី ៣ នៃសេចក្តីសម្រេចបញ្ចប់ ។

**យោង:** -មាត្រា ២៧០ , ២៨៦ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-សំណុំរឿងរដ្ឋប្បវេណីលេខ ៤៣៣ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ៖ សាលដីការដ្ឋប្បវេណីលេខ ១០ក្រIV(ច) ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ បានយល់ឃើញថា បណ្តឹងតប ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១១ របស់ខ្ញុំបាទ មានលក្ខណៈត្រឹមត្រូវ អាចឱ្យក្រុមប្រឹក្សាពិចារណាបាន ព្រោះភាគីដើមចោទ                    មិនបានតវ៉ាអំពីបណ្តឹងតបនេះនៅចំពោះមុខសាលាឧទ្ធរណ៍ទេ ដូចមានកំណត់ហេតុទាញហេតុផលផ្ទាល់មាត់ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ និងកំណត់ហេតុទាញ ហេតុផលផ្ទាល់មាត់ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៣ របស់តុលាការកំពូល ស្រាប់ ។

ប៉ុន្តែ សាលាឧទ្ធរណ៍បែរជា មិនសម្រេចអំពីដំណឹងចិត្តរបស់ខ្ញុំបាទទៅវិញ ដោយយល់ឃើញថា ឈ្មោះ                    និងឈ្មោះ                    ជាឪពុក និងកូនបង្កើត មិនបានបង្កការខូចខាតធ្ងន់ធ្ងរទៅវិញ។ ការយល់ឃើញដូច្នេះ មិនត្រឹមត្រូវទេ ព្រោះទោះជាឪពុកនឹងកូនក៏មានការខូចខាតដែរ ពិសេសចំពោះកូនដែលមកប្តឹងយកកេរ្តិ៍មត៌ករបស់ឪពុកដែលកំពុងនៅមានជីវិតនេះ បញ្ជាក់អំពីភាពអកតញ្ញូ និងភាពឃោរឃៅរបស់កូន ដែលធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់ខ្ញុំបាទយ៉ាងធ្ងន់ធ្ងរណាស់ គឺធ្ងន់ធ្ងរជាងអ្នកដទៃទៅទៀតផង ។

ហេតុដូច្នេះ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ និងក្នុងគោលបំណងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ផង សូមឯកឧត្តម មេត្តាចាត់បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៤៣៣ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ទៅតុលាការកំពូល ដើម្បីចាត់ការជាសមត្ថកិច្ចតាមច្បាប់ ។

សូមឯកឧត្តម ទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី ..០៣.. ខែ..មិថុនា.. ឆ្នាំ ..២០១៤..

**ស្នាមមេដៃ**

**បានឃើញ**

លោក                    ស្តីតមេធាវីចំពោះមុខមេធាវី ។

ភ្នំពេញ,ថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៤

ហត្ថលេខា និង ត្រា

មេធាវី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

លេខ:242

# បង្កាន់ដៃបង់ប្រាក់ប្រដាប់ក្ដីតុលាការ
# សម្រាប់តុលាការកំពូល

(យោងលិខិតលេខ:១៩១/១២តកក ចុះថ្ងៃទី២៩-៦-១២ របស់តុលាការកំពូល)

-សំណុំរឿងរដ្ឋប្បវេណីលេខ 229 ចុះថ្ងៃទី02-5-14 របស់សាលាឧទ្ធរណ៍

-សាលដីការដ្ឋប្បវេណីលេខ 04 ក្ត IV ចុះថ្ងៃទី 15-09-14 របស់សាលាឧទ្ធរណ៍

-ឈ្មោះអ្នកបង់ប្រាក់......

ទីលំនៅ......

ចំនួនទឹកប្រាក់ ១០០.០០០៛០០ (ដប់ម៉ឺនរៀល)

ក្នុងរឿងប្ដឹង......

......។

រាជធានីភ្នំពេញ ថ្ងៃទី 02 ខែ 10 ឆ្នាំ២០14

នាយកក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

.........................

លេខ: 95 .....រ.ប.ឧ ២០១៥

# ដីកាបញ្ជូន

ជម្រាបមក: ឯកឧត្តមប្រធានតុលាការកំពូល

| រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|
| 1_ [illegible] 229/12-05-2014 | ០១ ច្បាប់ | [illegible] |
| 2_ 296/15-08-2013 [illegible] | 12 ច្បាប់ | |
| 3 [illegible] | | |
| សរុប | ០២ ច្បាប់ | |

ភ្នំពេញ, ថ្ងៃទី 22 ខែមករា ឆ្នាំ២០១៥

ជ.ប្រធាន

សេង_ស៊ីវុត្ថា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខៈ ២៧៤ ច.ក

# ដីកាចាត់តាំងសមាសភាពជំនុំជំរះ

************

## ប្រធានតុលាការកំពូល

-បានឃើញច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសអោយប្រើ ដោយក្រឹត្យ លេខ ០៦ក្រ. ចុះថ្ងៃទី ០៨-០២-៩៣។

-បានឃើញច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ២១ក្រ ចុះថ្ងៃទី ០៨-៣-៩៣។

## សំរេចចាត់តាំង

| | | | |
|---|---|---|---|
| ១-ឯកឧត្តម ឃឹម. ប៉ុន | ប្រធាន | | |
| ២-លោក ចេត. សំណាង | ចៅក្រម | ៦-លោក | ចៅក្រម |
| ៣-លោក [illegible] | ចៅក្រម | ៧-លោក | ចៅក្រម |
| ៤-លោក [illegible] | ចៅក្រម | ៨-លោក | ចៅក្រម |
| ៥-លោក [illegible] | ចៅក្រម | ៩-លោក | ចៅក្រម |

ក្រឡាបញ្ជី........................................

អោយចូលរួមជំនុំជំរះរឿង រដ្ឋប្បវេណី :

១-លេខ......135......ចុះថ្ងៃទី..20..ខែ.......08.......ឆ្នាំ ២០13

២-លេខ......166......ចុះថ្ងៃទី..28..ខែ.......10.......ឆ្នាំ ២០13

៣-លេខ......235......ចុះថ្ងៃទី..28..ខែ.......11.......ឆ្នាំ ២០14

៤- លេខ......251......ចុះថ្ងៃទី..15..ខែ.......12.......ឆ្នាំ ២០14

៥- លេខ........................ចុះថ្ងៃទី.............ខែ.....................ឆ្នាំ ២០០.....

នាសវនាការជាសាធារណៈ នៅថ្ងៃទី .....18.....ខែ..ឧសភា......ឆ្នាំ ២០១៥

រាជធានីភ្នំពេញ, ថ្ងៃទី .....11....ខែ ..ឧសភា.. ឆ្នាំ ២០១៥

[signature]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខ: ៤៩៧ ច.ក

# ដីកាចាត់តាំង

## ប្រធានតុលាការកំពូល

សំរេចចាត់តាំងលោក ឌី.ណាស ជាចៅក្រមទទួលបញ្ជា

ឱ្យពិនិត្យអំពីទំរង់ និង គតិច្បាប់ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ២៣៥ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ របស់តុលាការកំពូល និងសាលដីកាលេខ ២៦៤/៣ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ របស់សាលាឧទ្ធរណ៍ ហើយធ្វើរបាយការណ៍សន្និដ្ឋានវាយតំលៃលើអង្គច្បាប់ និង ចង្អុលប្រាប់នូវវិធានការដោះស្រាយផ្សេងៗ ដើម្បីដាក់ជូនតុលាការកំពូល ជំនុំជំរះ ។

ភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

## ដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តី

សំណុំរឿងរដ្ឋប្បវេណី

លេខ ...០៧...........

ចុះថ្ងៃទី ..២៣...០១...២០១២

យើង ............................ចៅក្រមទទួលបញ្ជារបស់ក្រុមប្រឹក្សាជំនុំជំរះ នៃតុលាការកំពូល
បង្គាប់មកឈ្មោះ ...... ...............ភេទ ...........អាយុ ...........ឆ្នាំ
អាសយដ្ឋានៈ ផ្ទះលេខ.............ក្រុម/ផ្លូវ.................ភូមិ......................សង្កាត់/ឃុំ....................
ខណ្ឌ/ ស្រុក.........................រាជធានី/ខេត្ត ...................... មុខរបរ..................................
ឱ្យមកបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធចំនួន ១០០.០០០ (ដប់ម៉ឺន)រៀល ក្នុងអំឡុងពេល.....៣០.....ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូនដីកានេះពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ..........ចុះថ្ងៃទី. ...៣០..ខែ.....៤.....ឆ្នាំ..២០១១.........របស់សាលាឧទ្ធរណ៍ នៅសការដ្ឋប្បវេណីនៃតុលាការកំពូល ។

<u>**សំគាល់**</u>:"បើម្ចាស់បណ្តឹងសាទុក្ខមិនយកប្រាក់មកបង់តាមដីកានេះទេ តុលាការកំពូលនឹងលើកបណ្តឹងសាទុក្ខចោល តាមចំណុច ក មាត្រា ២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី" ។

ភ្នំពេញ, ថ្ងៃទី ..០១... ខែ ........... ឆ្នាំ ២០១២

ចៅក្រម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សភារដ្ឋប្បវេណី**

# លិខិតជូនដំណឹង
# អំពីការទទួលពាក្យបណ្តឹងជំទាស់ និង
# ឱ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់

យើង............................ ចៅក្រមទទួលបញ្ហានៃក្រុមប្រឹក្សាជំនុំជម្រះតុលាការកំពូល

## ជូនដំណឹង

ម្ចាស់បណ្តឹងជំទាស់ឈ្មោះ .................... ភេទ ..... កើតនៅថ្ងៃទី ... ខែ ...... ឆ្នាំ ....... អាយុ .... ឆ្នាំ សញ្ជាតិ ..... អាសយដ្ឋានផ្ទះលេខ ........... ផ្លូវលេខ ......... ភូមិ ................... ឃុំ/សង្កាត់ ....................... ស្រុក/ខណ្ឌ ................................. រាជធានីភ្នំពេញ/ខេត្ត ............................... ដូចខាងក្រោម :

១. តុលាការកំពូលបានទទួលពាក្យបណ្តឹងជំទាស់ របស់ម្ចាស់បណ្តឹងជំទាស់ ដោយចុះក្នុងបញ្ជីសំណុំរឿងរដ្ឋប្បវេណីលេខ .............. ចុះថ្ងៃទី ....... ខែ ........... ឆ្នាំ ................... ។

២. ម្ចាស់បណ្តឹងជំទាស់ត្រូវដាក់លិខិតបញ្ជាក់ អំពីមូលហេតុនៃបណ្តឹងជំទាស់ ក្នុងអំឡុងពេល **២ សប្តាហ៍** គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតជូនដំណឹងនេះ ។

បើម្ចាស់បណ្តឹងជំទាស់ មិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់ តាមការកំណត់ខាងលើ តុលាការកំពូលត្រូវលើកពាក្យបណ្តឹងជំទាស់ចោល តាមមាត្រា ៣០៨ និងមាត្រា ២៩០ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ............. ឆ្នាំ ២០១........

ចម្លងជូន :
ចុងបណ្តឹងជំទាស់ឈ្មោះ : .......................
ដោយភ្ជាប់ជាមួយនឹងពាក្យបណ្តឹងជំទាស់
ចុះថ្ងៃទី ......... ខែ ............ ឆ្នាំ .............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ ..........................
ចុះថ្ងៃទី.........ខែ..........ឆ្នាំ២០...

## ដីកាបង្គាប់ឱ្យដាក់លិខិតបញ្ជាក់
## អំពីមូលហេតុ នៃបណ្តឹងសាទុក្ខ

យើង ..................................ចៅក្រមទទួលបញ្ជារបស់ក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល បង្គាប់មកលោក-លោកស្រី...................................អាយុ..........ឆ្នាំ មានមុខរបរ.................... អាសយដ្ឋាន: ផ្ទះលេខ..........ក្រុម/ផ្លូវ.............ភូមិ........................សង្កាត់/ឃុំ .................. ខណ្ឌ/ស្រុក.................................រាជធានី/ខេត្ត........................................................ ជាដើមបណ្តឹងសាទុក្ខ ឱ្យធ្វើលិខិតបញ្ជាក់អំពីមូលហេតុនៃ បណ្តឹងសាទុក្ខ ដែលបានប្តឹងពីសាលដីការដ្ឋប្បវេណី លេខ..................ចុះថ្ងៃទី...............ខែ...............ឆ្នាំ...............របស់សាលាឧទ្ធរណ៍ ដាក់ជូនតុលាការកំពូល ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូនដីកានេះ ។

**សំគាល់:** "បើដើមបណ្តឹងសាទុក្ខមិនដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ តាមដីកានេះទេ តុលាការកំពូលនឹងលើកបណ្តឹងសាទុក្ខចោល តាមចំណុចខ មាត្រា ២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី" ។

ភ្នំពេញ ថ្ងៃទី.........ខែ............ឆ្នាំ.........
ចៅក្រម

សេម សក្តិកុម្ភា

10/3/2015

មហាវិថីសម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, កម្ពុជា
Samdech Sothearos Blvd, Sangkat Chatomouk, Khan Daun Penh, Phnom Penh, Cambodia.
ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣-) ២១២៨២៦
Phone/fax: (855-23) 212 826

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមមេធាវី ជាតិ និង អន្តរជាតិ
NATIONAL AND INTERNATIONAL LAW FIRM
មេធាវី ខៀវ សុផល
KHIEV SOPHAL Avocat , Attorney-At-Law

# ពាក្យសុំពឹងពាក់មេធាវីតំណាងដោយអាណត្តិ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................... ភេទ......... អាយុ.......ឆ្នាំ ជាតិ.........
សញ្ជាតិ.............. អាស័យដ្ឋាន ផ្ទះលេខ ............ ផ្លូវលេខ............ ក្រុម.......... ភូមិ..............
ឃុំ/សង្កាត់...................... ស្រុក/ខណ្ឌ/ក្រុង..................... ខេត្ត/រាជធានី.........................
ត្រូវជា...............................................។

## ស្នើសុំពឹងពាក់ និងប្រគល់សិទ្ធិជូន

លោក ជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមមេធាវីជាតិ និង អន្តរជាតិ និងលោកមេធាវី អត្តលេខ មានទីស្នាក់ការ ផ្ទះលេខ ផ្លូវលេខ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ។

ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ........ ចុះថ្ងៃទី 23 ខែ 01 ឆ្នាំ 2012 របស់.......................... ស្របតាមនីតិវិធីច្បាប់ នៅ ........................................................។

ខ្ញុំបាទ/នាងខ្ញុំទទួលស្គាល់មេធាវីទាំងពីររូប ឬមេធាវីណាមួយក្នុងចំណោមទាំងពីររូប ដើម្បីធ្វើសកម្មភាពបណ្តឹងក្នុងនាមខ្ញុំបាទ/នាងខ្ញុំ នៅចំពោះមុខស្ថាប័នមានសមត្ថកិច្ចខាងលើនេះ។

*ចំពោះសោហ៊ុយចំណាយលើការប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ខ្ញុំបាទ/នាងខ្ញុំជាអាណត្តិទាយក ក្នុងករណីមិនបានគោរពកាតព្វកិច្ចបង់ប្រាក់ប្រដាប់ក្តី ខ្ញុំបាទ/នាងខ្ញុំសុខចិត្តទទួលខុសត្រូវរាល់ការខាតបង់ផលប្រយោជន៍ដោយខ្លួនឯងផ្ទាល់។

លោកមេធាវីតំណាងដោយអាណត្តិ មានសិទ្ធិអនុវត្តនូវកិច្ចការជាអាណត្តិ ដែលខ្ញុំបាទ/នាងខ្ញុំបានប្រគល់ជូន ដូចខាងលើ ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ។

ធ្វើនៅ ..........., ថ្ងៃទី 09 ខែ 08 ឆ្នាំ 2012

**អាណត្តិទាយក**

**បានឃើញ និងយល់ព្រម**

តាមសំណើរបស់អាណត្តិទាយកប្រាកដមែន។

ថ្ងៃទី 09 ខែ 08 ឆ្នាំ 2012

**អាណត្តិគាហក**

មេធាវី AVOCAT ATTORNEY AT LAW

មេធាវី.

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំអាណត្តិទាយកឈ្មោះ............ ភេទ ស្រី អាយុ.......... ឆ្នាំ ជនជាតិ ខ្មែរ
សញ្ជាតិ ខ្មែរ មុខរបរ.................. ទីលំនៅផ្ទះលេខ.............. ផ្លូវលេខ..............
ភូមិ/មណ្ឌល [illegible] ក្រុម.............. ឃុំ/សង្កាត់ [illegible] ក្រុង/ស្រុក/ខណ្ឌ
[illegible] រាជធានី/ខេត្ត [illegible] ។

## សូមប្រគល់សិទ្ធិជូន

លោកមេធាវី.................. អត្តលេខ.............. អាសយដ្ឋានផ្ទះលេខ..............
ផ្លូវលេខ.............. ភូមិ.............. សង្កាត់ [illegible] ខណ្ឌ [illegible] រាជធានីភ្នំពេញ ។

ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិរបស់ខ្ញុំ និង ធ្វើការអាណត្តិនូវកិច្ចការដូចខាងក្រោម:

☑ ធ្វើសកម្មភាពតំណាង ☑ ដាក់ពាក្យបណ្តឹង ឬ បណ្តឹងតប ☑ ផ្សះផ្សា
☑ លះបង់ការទាមទារ ☑ ទទួលស្គាល់ការទាមទារ ☑ ដកពាក្យបណ្តឹង
☑ ដកខ្លួនចេញពីពាក្យបណ្តឹង ☑ ដាក់ពាក្យបណ្តឹងទាស់ ☑ ដាក់បណ្តឹងឧទ្ធរណ៍
☑ ដាក់ពាក្យបណ្តឹងជំទាស់ ☑ ដាក់ពាក្យបណ្តឹងសាទុក្ខ

ក្នុងសំណុំរឿង [illegible] លេខ 07 ចុះថ្ងៃទី 23 ខែ មករា ឆ្នាំ 2012
របស់ [illegible] ។

<u>បញ្ជាក់:</u> សោហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗ នៅក្នុងបណ្តឹងនេះជាបន្ទុករបស់ខ្ញុំ(អាណត្តិទាយក) ។ ក្នុងករណីមិនបានគោរពនូវកាតព្វកិច្ចនេះ ខ្ញុំ(អាណត្តិទាយក)សុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់ ។

លោកមេធាវីតំណាងដោយអាណត្តិមានសិទ្ធិអនុវត្តកិច្ចការអាណត្តិតាមច្បាប់ ដែលអាណត្តិទាយកបានប្រគល់ជូនដូចខាងលើ ចាប់ពីថ្ងៃផ្តិតមេដៃ ឬ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី 04 ខែ កញ្ញា ឆ្នាំ ២០១២
អាណត្តិទាយក

បានឃើញ និង យល់ព្រម
ធ្វើជាមេធាវីតំណាងដោយអាណត្តិទាយកឲ្យឈ្មោះ
..........

ភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ 2012
មេធាវី

☑ យល់ព្រម
☒ មិនយល់ព្រម

**មេធាវី.**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមមេធាវី ជាតិ និង អន្តរជាតិ**
**NATIONAL AND INTERNATIONAL LAW FIRM**
**មេធាវី ខៀវ សុផល**
**KHIEV SOPHAL Avocat , Attorney-At-Law**

តុលាការកំពូល
1001
21 8 2012

## ពាក្យសុំធ្វើជាមេធាវីតំណាងដោយអាណត្តិ

ខ្ញុំបាទឈ្មោះ មេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៅក្រុមមេធាវីជាតិ និង អន្តរជាតិ ទូរស័ព្ទលេខ (០១១/០១២/០១៦/០៩៧៧) ៥៧ ៦៧ ៣៦ អ៊ីម៉ែល: sn@lawyer.com ។

**សូមគោរពចូលមក**

**ឯកឧត្តម តុលាការកំពូល ជាទីគោរព !**

**កម្មវត្ថុ**: សំណើសុំធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ ហៅ ( នៅក្នុង សំណុំរឿងរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១២ របស់តុលាការកំពូល។

**យោង**: -ច្បាប់ស្តីពីសក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

-ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

-ពាក្យសុំពឹងពាក់មេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១២ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា: លោក កៅ ឈឿន បានស្នើសុំពឹងពាក់ និងប្រគល់សិទ្ធិជូនខ្ញុំបាទជាមេធាវី ដើម្បីឱ្យខ្ញុំបាទធ្វើជាមេធាវីតំណាងដោយអាណត្តិ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១២ របស់តុលាការកំពូល ស្របតាមនីតិវិធីច្បាប់នៅ តុលាការកំពូល ។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូមឯកឧត្តម មេត្តាទទួលស្គាល់ តាមច្បាប់ ដោយអនុគ្រោះ។

សូមឯកឧត្តម ទទួលនូវការគោរព ដ៏ស្មោះស្ម័គ្រអំពីខ្ញុំបាទ។

ធ្វើនៅ...ភ្នំពេញ....., ថ្ងៃទី ០៧ ខែ ០៨ ឆ្នាំ ២០១២

**ហត្ថលេខា និង ត្រា**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី.

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមមេធាវី ជាតិ និង អន្តរជាតិ**

**NATIONAL AND INTERNATIONAL LAW FIRM**

**មេធាវី ខៀវ សុផល**

**KHIEV SOPHAL Avocat , Attorney-At-Law**

## លិខិតផ្ទេរសិទ្ធិ

ខ្ញុំបាទឈ្មោះ                ជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ        ជាមេធាវីតំណាងដោយអាណត្តិឱ្យលោក                 ហៅ            ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ២៣-០១-២០១២ របស់តុលាការកំពូល ។

603
20 5 13

**សូមគោរពជូន**

**ឯកឧត្តម ប្រធានតុលាការកំពូល ជាទីគោរព !**

**កម្មវត្ថុ** : សំណើផ្ទេរសិទ្ធិជូនលោកមេធាវី               ដើម្បីធ្វើសកម្មភាពជំនួសខ្ញុំបាទ ក្នុងនាមជាអ្នកតំណាងឱ្យ លោក              ហៅ            ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ២៣-០១-២០១២ របស់តុលាការកំពូល ។

**យោង** : ពាក្យសុំធ្វើជាមេធាវីតំណាងដោយអាណត្តិ របស់ខ្ញុំបាទ នៅក្នុងសំណុំរឿង ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា: ដោយហេតុថា នៅថ្ងៃទី ២១ និង ២២ ខែឧសភា ឆ្នាំ២០១៣ ខ្ញុំបាទជាប់រវល់ចាំបាច់មិនអាចខកខានបាន ក្នុងការចូលរួមកម្មវិធីសិក្សានៅសាលាភូមិន្ទសារការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។ មិនអាចមកចូលរួមសវនាការនៅតុលាការកំពូលបាន ។

ហេតុដូច្នេះ ដើម្បីកុំឱ្យមានការពន្យាពេលនាំឱ្យមានការកកស្ទះសំណុំរឿង ខ្ញុំសូមផ្ទេរសិទ្ធិទៅឱ្យលោកមេធាវី              ដើម្បីធ្វើសកម្មភាពជំនួសខ្ញុំបាទ ក្នុងនាមជាអ្នកតំណាងឱ្យលោក គី ឈុនឆាយ ហៅ              ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ២៣-០១-២០១២ របស់តុលាការកំពូល ពីថ្ងៃនេះ តទៅ ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើនេះ សូមឯកឧត្តមមេត្តាអនុញ្ញាត និងទទួលស្គាល់លោកមេធាវី              ដោយក្តីអនុគ្រោះ ។

សូមឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ធ្វើនៅ ភ្នំពេញ ថ្ងៃទី 20 ខែ ឧសភា ឆ្នាំ 2013

**មេធាវីផ្ទេរសិទ្ធិ**

មេធាវី

**បានឃើញ និងយល់ព្រម**

ទទួលសិទ្ធិធ្វើជាមេធាវីតំណាងដោយអាណត្តិ

ឱ្យឈ្មោះ គី ឈុនឆាយ ពិតប្រាកដមែន។

ថ្ងៃទី 20 ខែ ឧសភា ឆ្នាំ 2013

**មេធាវីទទួលសិទ្ធិ**

មេធាវី.

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>លិខិតផ្ទេរសិទ្ធិ</u>

នាងខ្ញុំឈ្មោះ ។ អាយុ ៥៥ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ មានទីលំនៅ ភូមិព្រៃកឡុង ឃុំតាក្ដុល ស្រុកតាខ្មៅ ខេត្តកណ្ដាល ។

## <u>សូមផ្ទេរសិទ្ធិជូន</u>

លោក អាយុ ៥១ ឆ្នាំ ទីលំនៅភូមិព្រៃកឡុង ឃុំតាក្ដុល ស្រុកតាខ្មៅ ខេត្តកណ្ដាល ដែលត្រូវជាកូនប្រសារ ធ្វើជាគូភាគីតំណាងនាងខ្ញុំ ក្នុងសំណុំរឿងរដ្ឋប្បវេណី លេខ ២៥៥ ចុះថ្ងៃទី ១២-៥-២០០៤ នៅសាលាឧទ្ធរណ៍ ចាប់ពីថ្ងៃផ្ដិតស្នាមមេដៃនេះតទៅ ។

កណ្ដាល ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៤

**ស្នាមមេដៃអ្នកទទួលសិទ្ធិ** **ស្នាមមេដៃអ្នកប្រគល់សិទ្ធិ**

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខៈ 499

## បង្កាន់ដៃទទួលប្រាក់

បានទទួលពីឈ្មោះ [illegible]

នៅឃុំ [illegible] ស្រុក [illegible] ខេត្ត [illegible]

ចំនួនទឹកប្រាក់ 5.000៛00

ពីដំណើរ [illegible]

ថ្ងៃទី 07 ខែ 04 ឆ្នាំ 2015

ក្រឡាបញ្ជី

[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

~~~~~~~~~~

07/04/2015

# លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ

នាងខ្ញុំឈ្មោះ ជាមេធាវីតំណាងដោយអាណត្តិអោយឈ្មោះ អាយុ ២៨ ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅបច្ចុប្បន្នភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ក្នុងករណីៈ សុំទាមទារដី-ផ្ទះទិញ និងម៉ូតូ មានសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣ ចុះថ្ងៃទី ២៦-មករា-២០១៥ របស់តុលាការកំពូល ។

តុលាការកំពូល
ផ្នែករដ្ឋប្បវេណី
ចូល លេខ 840
ថ្ងៃទី 07 ខែ 04 ឆ្នាំ 2015

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានតុលាការកំពូល**

សូមទានជ្រាប ។

**កម្មវត្ថុ:** សុំធ្វើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសារទុក្ខដើម្បីការពារផលប្រយោជន៍របស់កូនក្ដីនាងខ្ញុំក្នុងសំណុំរឿង រដ្ឋប្បវេណីលេខ ៣៣ ចុះថ្ងៃទី ២៦-មករា-២០១៥ របស់តុលាការកំពូល ។

**យោង:** -ដីកាបង្គាប់អោយដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសារទុក្ខចុះថ្ងៃទី ០៣-កុម្ភៈ-២០១៥ របស់តុលាការកំពូល ។

-សំណុំរឿងរដ្ឋប្បវេណីលេខ ៣៣ ចុះថ្ងៃទី ២៦-មករា-២០១៥ របស់តុលាការកំពូល ។

-ពាក្យតំណាងដោយអាណត្តិចុះថ្ងៃទី ២៦-មិនា-២០១៥ ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជំរាបជូនឯកឧត្ដមប្រធានមេត្តាជ្រាបពីដំណើររឿងដូចខាងក្រោម:

## ១-អំពីអង្គហេតុ:

កូនក្ដីនាងខ្ញុំឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ នៅក្នុងឆ្នាំ ២០១០ ហើយបានរស់នៅជាមួយគ្នាបានកូនប្រុសម្នាក់ឈ្មោះ អាយុ ០៣ ឆ្នាំ ។ នៅក្នុងរយៈពេលរស់នៅជាមួយគ្នាជាប្ដីប្រពន្ធកូនក្ដីនាងខ្ញុំបានប្រឹងប្រែងរកស៊ីជាមួយគ្នាបានលុយចំនួន ១១000ដុល្លា ( មួយម៉ឺនមួយពាន់ដុល្លាអាមេរិក ) មកទិញផ្ទះ និងដី ពីបងថ្លៃឈ្មោះ គឺ ដីមានទំហំ ១៦ម គុណ ១១ម រីឯផ្ទះទំហំ ៨ម គុណ ៨.៤ម ស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ។ បន្ទាប់ពីកូនក្ដីនាងខ្ញុំបានប្រគល់ប្រាក់ថ្លៃទិញដី និងផ្ទះចំនួន ១១000ដុល្លា ( មួយម៉ឺនមួយពាន់ដុល្លាអាមេរិក) មកអោយបងថ្លៃឈ្មោះ គ្រប់ចំនួនហើយ ទើបនាំប្ដីប្រពន្ធចូលមករស់នៅលើដី និងផ្ទះនេះរួចកូនក្ដីនាងខ្ញុំក៏បានរៀបបន្ទប់ថ្មខាងក្រោមផ្ទះជុំវិញ និងបានតយ៉ាកពីមុខផ្ទះថែមទៀត ។ ការរស់នៅរបស់កូនក្ដីនាងខ្ញុំជាមួយប្រពន្ធកូនសុខសាន្តណាស់មិនមានបញ្ហាអ្វីកើតឡើង មិនតែប៉ុណ្ណោះកូនក្ដីនាងខ្ញុំនិងប្រពន្ធបានដកប្រាក់រកស៊ីរួមគ្នាយកមកទិញខ្សែកផ្លាកទីន-ចិញ្ចៀន-កងដៃអោយប្រពន្ធ និងទិញម៉ូតូមួយគ្រឿងម៉ាក C125 សេរី 2008 ពាក់ស្លាកលេខ សំរាប់ប្រើប្រាស់ក្នុងគ្រួសារទៀតផង ( ដូចមានឯកសារក្នុងសំណុំរឿងស្រាប់ ) ។
~~~~~~~~~~

រស់នៅ និងបានសាងសង់សំណង់ជាហូរហែរក៏ពុំដែលមានទំនាស់ ឬការជំទាស់ពីចុងចម្លើយម្តងណាដែរ ដូច្នេះកិរិយានៃការកាន់កាប់របស់ដើមចោទនេះ បានបង្ហាញអោយឃើញថា ដើមចោទបានបំពេញកាតព្វកិច្ចចប់សព្វគ្រប់ជាមួយចុងចម្លើយរួចហើយទើបមិនមានការរារាំងពីចុងចម្លើយ ។

+ចំពោះលិខិតផ្ទេរដីមួយកន្លែងចុះថ្ងៃទី ០៩-កញ្ញា-២០០៥ *( ឯកសារលេខ ៣/១ នៅក្នុងសំណុំរឿងស្រាប់ )* គឺដាក់ថា: ឈ្មោះ បានផ្ទេរដីមួយកន្លែងទៅអោយឈ្មោះ ។ ប៉ុន្តែនៅត្រង់កន្លែងស្នាមមេដៃអ្នកលក់បែរជាដាក់ឈ្មោះ ( ប្តី ) និង ( ប្រពន្ធ ) ហើយនៅត្រង់កន្លែងស្នាមមេដៃអ្នកទិញបែរជាដាក់ឈ្មោះ ។ ដូច្នេះឃើញថា ឈ្មោះអ្នកទិញនៅក្នុងលិខិតនេះ គឺឈ្មោះ មិនមែនជាឈ្មោះរបស់ចុងចម្លើយ ( ) និងប្តីរបស់ចុងចម្លើយ( )នោះឡើយ ។ ដូច្នេះឃើញថា ដី និងផ្ទះដែលកំពុងតែមានវិវាទនេះមិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ និងឈ្មោះ ទេ ។

+ចំណែកឯលិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ ត្រង់កន្លែងស្នាមមេដៃម្ចាស់កម្មសិទ្ធិមានឈ្មោះដល់ទៅចំនួន០៤នាក់ គឺ ឈ្មោះ -ឈ្មោះ -ឈ្មោះ និងឈ្មោះ ។ ប៉ុន្តែនៅផ្នែកអក្សរខាងលើបែរជាដាក់ថា: ម្ចាស់កម្មសិទ្ធិឈ្មោះ និងឈ្មោះ ទេវិញ ហើយថែមទាំងបញ្ជាក់ទៀតថា: ឈ្មោះ និងឈ្មោះ បានកាន់កាប់ប្រើប្រាស់តាំងពីឆ្នាំ ២០០៩ នៅលើដី និងផ្ទះកំពុងតែមានវិវាទនេះ ។ ចំនុចទាំងអស់នេះបានបង្ហាញអោយឃើញពីភាពមិនប្រក្រតីនៅលើ លិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ *( ឯកសារលេខ ៣/១ នៅក្នុងសំណុំរឿងស្រាប់ )* នូវចំនុចមួយចំនួនដូចខាងក្រោម:

- **ចំនុចទី១:** បើឈ្មោះ និងឈ្មោះ បានកាន់កាប់ប្រើប្រាស់តាំងពីឆ្នាំ ២០០៩ ចុះហេតុអ្វីបានជាមានលិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ ធ្វើតាំងពីឆ្នាំ ២០០៨ គឺមុនមានដីទៅទៀត ?
- **ចំនុចទី២:** នៅក្នុងឆ្នាំ ២០០៨ លោក គឺជាមេភូមិ មេលប់ ចុះហេតុអ្វីបានជាលោក ដែលខ្លួនមិនមែនជាមេភូមិមកចុះហត្ថលេខា ជំនួសលោក ទេវិញ ?

+តាមលិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ គឺមានដាក់ឈ្មោះ ជាម្ចាស់កម្មសិទ្ធិដែរ ។ ដូច្នេះចំនុចនេះជាភស្តុតាងស៊ីសង្វាក់ ទៅនិងអង្គហេតុដែលកូនក្តីនាងខ្ញុំបានអះអាងថា ខ្លួនទិញដី និង ផ្ទះ ដែលកំពុងតែមានវិវាទនេះពីឈ្មោះ ហើយក៏បានប្រគល់ប្រាក់គ្រប់ចំនួនអោយទៅឈ្មោះ រួចហើយ ។

+ម្យ៉ាងទៀតតាមរបាយការណ៍បំភ្លឺរបស់លោក មេឃុំរកា ចុះថ្ងៃទី ១២-១២-២០១៣ និង របាយការណ៍បំភ្លឺរបស់លោក មេភូមិមេលប់ចុះថ្ងៃទី ១២-១២-២០១៣ សុទ្ធតែបានបញ្ជាក់ដូចគ្នាថា: ឈ្មោះ និងឈ្មោះ បានទិញដីកំពុងមានវិវាទនេះពីឈ្មោះ និងឈ្មោះ កាលពីថ្ងៃទី ០៩ ខែ ០៩ ឆ្នាំ ២០០៥ ។ ប៉ុន្តែការបំភ្លឺនេះផ្ទុយពីលិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ *( ឯកសារលេខ ៣/១នៅក្នុងសំណុំរឿងស្រាប់)* ព្រោះថា តាមឯកសារនេះបានបញ្ជាក់ថា: ឈ្មោះ និងឈ្មោះ បានកាន់កាប់ប្រើប្រាស់តាំងពីឆ្នាំ ២០០៩ មិនបានកាន់កាប់ពីឆ្នាំ ២០០៥ នោះឡើយ ។ ដូច្នេះមានន័យថា: រាល់ឯកសារដែលឈ្មោះ និងឈ្មោះ ធ្វើឡើងនេះ គឺ ដើម្បីបំភ្លៃការពិតទាំងស្រុងធ្វើអោយតុលាការមានការភន្តច្រឡំថាខ្លួនជាម្ចាស់កម្មសិទ្ធិលើដី និងផ្ទះដែលកំពុងតែមានវិវាទនេះ ។ ប៉ុន្តែតាមរយៈឯកសារមិនប្រក្រតីនេះបានបង្ហាញអោយ

ស្រាប់តែនៅថ្ងៃទី ២៦-០៩-២០១៣ ប្រពន្ធរបស់កូនក្តីនាងខ្ញុំឈ្មោះ ក៏បានទទួលមរណៈភាព ។ កូនក្តីនាងខ្ញុំបានធ្វើបុណ្យសព០៧ថ្ងៃប្រពន្ធរួច ស្រាប់តែឪពុកម្តាយក្មេកបានមកដេញកូនក្តីនាងខ្ញុំចេញពីផ្ទះដែលកំពុងតែរស់នៅ ហើយបានយកម៉ូតូ ព្រមទាំងគ្រឿងអលង្ការដែលមានទំងន់ ៩ជី ១ហ៊ុនកន្លះ ជារបស់កូនក្តីនាងខ្ញុំទៅបាត់ ។

ដោយឃើញកូនក្តីនាងខ្ញុំឃើញសកម្មភាពរបស់ឪពុកម្តាយក្មេកចង់បានទ្រព្យសម្បត្តិរបស់ខ្លួនដូច្នេះ ទើបកូនក្តីនាងខ្ញុំបានដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីធ្វើការដោះស្រាយទៅតាមផ្លូវច្បាប់ ។

**២-<u>អំពីអង្គច្បាប់</u>៖**

**ក/**-ចំពោះការទាមទាររបស់កូនក្តីនាងខ្ញុំ៖ សុំសិទ្ធិគ្រប់ដីមានទំហំ ១៦ម x ១១ម និងផ្ទះទំហំ ៨ម x ៨.៤ម ស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ដោយហេតុថា៖ ដី និងផ្ទះនេះគឺកូនក្តីនាងខ្ញុំ និងប្រពន្ធ ពិតជាបានទិញពីឈ្មោះ ត្រូវជាបង និងជាបងថ្លៃ ហើយក៏បានប្រគល់ប្រាក់ថ្លៃទិញដីនិងផ្ទះនេះចំនួន ១១០០០ដុល្លា (មួយម៉ឺនមួយពាន់ដុល្លាអាមេរិក) អោយទៅឈ្មោះ គ្រប់ចំនួនរួចហើយ ទើបកូនក្តីនាងខ្ញុំនិងប្រពន្ធមានសិទ្ធិចូលទៅរស់នៅ និង ធ្វើការសាងសង់បន្ទប់ជុំវិញក្រោមផ្ទះទាំងអស់ និងតយ៉ាកខាងមុខផ្ទះ និងសងខាងផ្ទះ ។

+មួយវិញទៀតបន្ទាប់ពីឈ្មោះ បានទទួលប្រាក់ថ្លៃលក់ដី និងផ្ទះពីកូនក្តីនាងខ្ញុំរួចហើយ ក៏បានយកទៅទិញដីនៅឯផ្សារវិញ (ដូចមានចំលើយសាក្សីឈ្មោះ បញ្ជាក់ជូនស្រាប់នៅក្នុងសំណុំរឿង) ហើយចំនុចនេះ ឈ្មោះ ក៏បានទទួលស្គាល់ដែរថា ខ្លួនពិតជាទិញដីនៅផ្សារពិតមែន(ដូចមានចំលើយបញ្ជាក់ជូនស្រាប់នៅក្នុងសំណុំរឿង) ។

+តាមរបាយការណ៍របស់លោក ជាសមាជិកក្រុមប្រឹក្សាឃុំរកា បានបញ្ជាក់ថា៖ នៅឆ្នាំ ២០១១ ឈ្មោះ និងប្រពន្ធឈ្មោះ ពិតជាបានទិញផ្ទះ និងដី ព្រមទាំងបានរស់នៅលើផ្ទះនោះរហូតពុំដែលមានបញ្ហាអ្វីឡើយ ថែមទាំងបានធ្វើបន្ទប់គេង បន្ទប់ទឹកខាងក្រោមផ្ទះ នឹងតយ៉ាបចាប់ដែកនៅខាងមុខនិងសងខាងផ្ទះ ដោយពុំមានអ្នកណាមករាំងស្ទះឡើយ (*ដូចមានឯកសារលេខ ៧/១ នៅក្នុងសំណុំរឿងស្រាប់*) ។

+តាមរបាយការណ៍របស់លោក ជាអនុភូមិមេលប់ បានបញ្ជាក់ថា៖ នៅថ្ងៃទី ២០-០៧-២០១១ ឈ្មោះ បានលក់ដី និងផ្ទះអោយទៅឈ្មោះ និងប្រពន្ធឈ្មោះ ពិតមែន។ ហើយក្នុងចន្លោះឆ្នាំ ២០១១ រហូតដល់ឆ្នាំ ២០១៣ ឈ្មោះ និងប្រពន្ធឈ្មោះ បានកសាងបន្ទប់ក្រោមផ្ទះយ៉ាងធំ តម្លើងដោយដែកប្រក់សង្ក័សី នៅក្នុងភូមិប្រជាពលរដ្ឋជាទូទៅគេដឹងលឺថា ពិតជាបានលក់ទិញមែន (*ដូចមានឯកសារលេខ ៧/១ និងឯកសារលេខ ៦/១ ដល់ ៦/៨ នៅក្នុងសំណុំរឿងស្រាប់*) ។

+ចំពោះភស្តុតាងដើម្បីបញ្ជាក់អំពីការប្រគល់.ទទួលប្រាក់ ក្នុងការទិញ.លក់ដី និងផ្ទះ ដែលជាចំនុចវិវាទនេះ គឺមិនមានជាលាយលក្ខ័អក្សរមែន។ ប៉ុន្តែតាមអង្គហេតុចុងចម្លើយបានទទួលស្គាល់ថាពិតជាមានការទិញ.លក់មែន ហើយចុងចម្លើយក៏ទទួលស្គាល់ទៀតថា បានទទួលប្រាក់ចំនួន ១០០០ដុល្លា(មួយពាន់ដុល្លាអាមេរិក) ពីដើមចោទ ដោយគ្រាន់យកលេះថា ដើមចោទមិនទាន់អោយប្រាក់គ្រប់ចំនួន ។ ដូច្នេះបើភាគីចុងចម្លើយបានទទួលស្គាល់ថា មានការទិញ.លក់ មានការប្រគល់ប្រាក់ នេះជាអង្គហេតុពិត ហើយចំពោះចុងចម្លើយអះអាងថា មិនទាន់បានទទួលប្រាក់គ្រប់ចំនួន គឺមិនអាចអោយជឿបាន ព្រោះថា ដើមចោទមិនបានទទួលស្គាល់នូវអង្គហេតុនេះទេ ម្យ៉ាងផ្ទះ និងដីគឺដើមចោទបានចូលទៅ

ឃើញថា មានការឃុបឃិតគ្នារវាងឈ្មោះ និងឈ្មោះ ជាមួយអាជ្ញាធរ ដើម្បីកសាងឯកសារទាំងនេះឡើងទាញយកប្រយោជន៍ពីកូនក្តីនាងខ្ញុំតែប៉ុណ្ណោះ ។

**ខ/**- ចំពោះការទាមទាររបស់កូនក្តីនាងខ្ញុំៈ សុំយកម៉ូតូមួយគ្រឿងម៉ាកសេ ១២៥ សេរីឆ្នាំ ២០០៨ ពីភាគី ចុងចម្លើយវិញ នោះ គឺ ជាការត្រឹមត្រូវ ព្រោះថាៈ តាមលិខិតរបស់មន្ទីរសាធារណៈការ និង ដឹកជញ្ជូនខេត្តព្រៃវែងលេខ ១៣០/២០១៤ ស.ក.ពវ ចុះថ្ងៃទី ២០-មិនា-២០១៤ បានបញ្ជាក់យ៉ាងច្បាស់ថាៈ ម៉ូតូមួយគ្រឿងម៉ាក C125 សេរី 2008 ពាក់ស្លាកលេខ B1-6540 គឺ ជាកម្មសិទ្ធិរបស់ឈ្មោះ ។

**គ/**- ចំពោះការទាមទាររបស់កូនក្តីនាងខ្ញុំៈ សុំយកមាសផ្លាកទីនរួមមាន ខ្សែក ចិញ្ចៀន និងកងដៃទម្ងន់សរុប ៩ ជី ២ហ៊ុន ពីភាគីចុងចម្លើយវិញ នោះ គឺជាការត្រឹមត្រូវ ព្រោះថាៈ មានវិក័យប័ត្រដែលដើមចោទ និងប្រពន្ធឈ្មោះ ជាអ្នកទិញក្នុងអំឡុងពេលរស់នៅជាមួយគ្នា *( មានឯកសារក្នុងសំណុំរឿងស្រាប់ )* ។

**៣-អំពីការសំរេចសេចក្តីរបស់តុលាការៈ**

**ក/-ចំពោះការសំរេចសេចក្តីរបស់សាលាដំបូងខេត្តព្រៃវែងៈ** តាមអំណាចសាលក្រមលេខ ០២ ( ខ ) ចុះថ្ងៃទី ២៦-០៣-២០១៤ ដោយប្រគល់ៈ ដីមានទំហំ ១៦ម X ១១ម និងផ្ទះទំហំ ៨ម X ៨.៤ម ស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង - ម៉ូតូមួយគ្រឿងម៉ាក C125 សេរី 2008 ពាក់ស្លាកលេខ និង ខ្សែក ចិញ្ចៀន និងកងដៃទម្ងន់សរុប ៩ ជី ២ហ៊ុន អោយមកឈ្មោះ ជាដើមចោទវិញ គឺជាការសំរេចសេចក្តីប្រកបដោយភាពយុត្តិធម៌បំផុតហើយ ព្រោះថាៈ តាមការបង្ហាញក្នុងចំនុចទី២អំពីអង្គច្បាប់ខាងលើ បានបញ្ជាក់ថាៈ ឈ្មោះ ពិតជាជាកម្មសិទ្ធិលើទ្រព្យសម្បត្តិទាំងអស់នេះពិតប្រាកដមែន ហើយចុងចម្លើយគ្មានឯកសារជាក់លាក់ណាមួយដើម្បីបង្ហាញជូនតុលាការឡើយ ។ មួយវិញទៀតរាល់ឯកសារដីដែលចុងចម្លើយយកមកធ្វើជាភស្តុតាង គឺមានភាពមិនប្រក្រតីយ៉ាងច្រើន និងមិនអាចអោយជឿបានទេ ។

**ក/-ចំពោះការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍ៈ** តាមអំណាចសាលដីកាលេខ ០៤ ( ក្រ IV សស ) ចុះថ្ងៃទី ១៥-០៩-២០១៤ ដោយទទួលស្គាល់ពាក្យបណ្តឹងតបចុះថ្ងៃទី ២២-ធ្នូ-២០១៣ របស់ចុងចម្លើយ ដោយអោយឈ្មោះ ចុះចេញពីផ្ទះនិងដីទំនាស់នោះគឺជាការមិនត្រឹមត្រូវឡើយ ដោយហេតុថាៈសាលាឧទ្ធរណ៍មិនបានពិនិត្យនិងពិចារណាលើអង្គហេតុដែលភាគីចុងចម្លើយទទួលស្គាល់ថា ពិតជាមានការទិញលក់ដី និងផ្ទះ ព្រមទាំងមានការប្រគល់. ទទួលប្រាក់ថ្លៃទិញផ្ទះ ហើយក៏មិនបានពិនិត្យ និងពិចារណាទៅលើភាពមិនប្រក្រតីពាក់ពន្ធ័និងឯកសាររបស់ចុងចម្លើយយកមកបង្ហាញជូនតុលាការដូចជាៈ លិខិតផ្ទេរដីមួយកន្លែងចុះថ្ងៃទី ០៩-កញ្ញា-២០០៥ *( ឯកសារលេខ ៣/១ នៅក្នុងសំណុំរឿងស្រាប់)* - លិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ *( ឯកសារលេខ ៣/១ នៅក្នុងសំណុំរឿងស្រាប់)* របាយការណ៍បំភ្លឺរបស់លោក មេឃុំរកា ចុះថ្ងៃទី ១២-១២-២០១៣ និងរបាយការណ៍បំភ្លឺរបស់លោក មេភូមិមេលប់ចុះថ្ងៃទី ១២-១២-២០១៣ ដូចបានបង្ហាញជូន "**ត្រង់ចំនុចអង្គច្បាប់**" ខាងលើនេះឡើយ ។

ម៉្យាងទៀតចំពោះការសំរេចរបស់សាលាឧទ្ធរណ៍ ច្រានចោលនូវការទាមទាររបស់ដើមចោទ ដែលអោយចុងចម្លើយធ្វើការប្រគល់គ្រឿងអលង្ការរួមមានៈ ខ្សែក ចិញ្ចៀន និង កងដៃ ទម្ងន់សរុប ៩ ជី ២ហ៊ុន ដោយផ្អែកតាមការអះអាងរបស់ចុងចម្លើយថា ខ្លួនលក់ព្យាបាលកូន និងធ្វើបុណ្យសពអស់ហើយ ជាការពុំត្រឹមត្រូវទេ ព្រោះថាៈ ដើមចោទ

ជាអ្នកមើលថែ និងព្យាបាលជំងឺរបស់ប្រពន្ធ ហើយការចំណាយធ្វើបុណ្យសពនិងព្យាបាលជំងឺនោះដើមចោទជាអ្នកចាត់ចែងដែរ ព្រោះថាដើមចោទមានមុខរបរ ។ ម្យ៉ាងទៀតចុងចម្លើយគ្មានសិទ្ធិអ្វីមកធ្វើការចាត់ចែងលក់ដូរទ្រព្យសម្បត្តិរួមរបស់ដើមចោទឡើយ ប្រសិនបើមានការលក់គ្រឿងអលង្កាទាំងអស់នេះមែនក៏ទុកសិទ្ធិអោយដើមចោទជាអ្នកលក់ដែរមិនមែនចុងចម្លើយជាអ្នកលក់នោះទេ ។ ជាពិសេសទៅទៀតភាគីចុងចម្លើយគ្មានភាពស្មោះត្រង់បង្ហាញការពិតឡើយ គឺចង់បានទ្រព្យសម្បត្តិរបស់ដើមចោទ ព្រោះថា ដើមចោទបានអះអាងថា គ្រឿងអលង្កាខ្លួនជាអ្នកទិញអោយកូនស្រីឈ្មោះ , តាំងពីមិនទាន់រៀបការ ចំណែកឯម៉ូតូក៏ខ្លួនជាអ្នកទិញដែរ ប៉ុន្តែនៅពេលដែលដើមចោទបានបង្ហាញឯកសារពាក់ពន្ធ័និងគ្រឿងអលង្កា និងឯកសារម៉ូតូ ឃើញថា អះអាងរបស់ចុងចម្លើយគឺភូតកុហកតុលាការ ទាំងស្រុង ។ ដូច្នេះការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍គប្បីពិនិត្យទៅលើចំនុចទាំងអស់នេះ និងលើឯកសារដែលបានលើកក្នុងចំនុចអង្គច្បាប់ខាងលើ ទើបការសំរេចសេចក្តីអាចផ្តល់នូវភាពយុត្តិធមិសំរាប់កូនក្តីនាងខ្ញុំបាន ។

**៣-<u>សំណូមពរ</u>:**

សូមឯកឧត្តមប្រធានមេត្តាសំរេចសេចក្តី ច្រានចោលសាលដីកាលេខ ០៤ ( ក្រ IV សស ) ចុះថ្ងៃទី១៥-០៩-២០១៤ របស់សាលាឧទ្ធរណ៏ រួចធ្វើការសំរេចសេចក្តីមិនបង្វិល ដោយដំកល់ទុកនូវ សាលក្រមលេខ ០២ ( ខ ) ចុះថ្ងៃទី ២៦-០៣-២០១៤ របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការពេញទាំងមូលដដែល ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមប្រធាមមេត្តាទទួលនូវការស្នើសុំរបស់នាងខ្ញុំក្នុងនាមជាមេធាវីតំណាងដោយអាណត្តិដោយក្តីអនុគ្រោះ ។

សូមឯកឧត្តមប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ធ្វើនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៥

**ហត្ថលេខានិងត្រា**

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

## ដីកាបង្គាប់ឱ្យដាក់ឯកសារត្រៀម (សារណាតប)

សំណុំរឿងរដ្ឋប្បវេណី

លេខ ...33.......................

ចុះថ្ងៃទី...26...ខែ...01...ឆ្នាំ២០15

យើង ...[illegible]...ចៅក្រមទទួលបញ្ជារបស់ក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល បង្គាប់មកលោក-លោកស្រី...[illegible]...អាយុ...........ឆ្នាំ មានមុខរបរ...[illegible]... អាសយដ្ឋាន: ផ្ទះលេខ..........ក្រុម/ផ្លូវ.............ភូមិ...[illegible]...សង្កាត់/ឃុំ ...[illegible]... ខណ្ឌ/ស្រុក...[illegible]...រាជធានី/ខេត្ត...[illegible]... ជាចុងបណ្ដឹងសាទុក្ខ ឱ្យដាក់ឯកសារត្រៀមឆ្លើយតបទៅនឹងមូលហេតុនៃបណ្ដឹងសាទុក្ខដែលភ្ជាប់មកជាមួយនេះ របស់...[illegible]...ជូនតុលាការកំពូល ក្នុងអំឡុងពេល...30...ថ្ងៃបន្ទាប់ពីបានទទួលការបញ្ជូនដីកានេះ ។

ភ្នំពេញ ថ្ងៃទី...[illegible]...ខែ...[illegible]...ឆ្នាំ...2015...
ចៅក្រម

សែម.សក្តិកុម្ភា

ជូនភ្ជាប់ជាមួយនូវ ៖
-លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខ

មហាវិថីសម្ដេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, កម្ពុជា
Samdech Sothearos Blvd, Sangkat Chatomouk, Khan Daun Penh, Phnom Penh, Cambodia
ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣-)២១២៨២៦
Phone/fax: (855-23) 212 826

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខ: 1563

# បង្កាន់ដៃទទួលប្រាក់

បានទទួលពីឈ្មោះ.......................................................................

នៅឃុំ [illegible] ស្រុក [illegible] ខេត្ត [illegible]

ចំនួនទឹកប្រាក់ 5000,00-

ពីដំណើរ [illegible]

ថ្ងៃទី 15 ខែ 09 ឆ្នាំ 2015

ក្រឡាបញ្ជី

ឡេង ឌុង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

26/05/2015

## សារណាតប

នាងខ្ញុំឈ្មោះ ស្នាក់នៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ជាចុងបណ្តឹងសាទុក្ខក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ របស់តុលាការកំពូល ។

តុលាការកំពូល
លេខាធិការដ្ឋានរដ្ឋប្បវេណី
ចូល លេខ 1107 ថ្ងៃទី 26 ខែ 5 ឆ្នាំ 2015

**សូមគោរពជូន**

**ឯកឧត្តម ប្រធានតុលាការកំពូល**

**កម្មវត្ថុ:** ស្តីពីសារណាតបទៅនឹងមូលហេតុនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ របស់តុលាការកំពូល ។

**យោង:** ដីកាបង្គាប់ឲ្យដាក់ឯកសារលេខ........ ចុះថ្ងៃទី 28 ខែមេសា ឆ្នាំ 2015 របស់តុលាការកំពូល

តបតាមកម្មវត្ថុ និង យោងខាងលើ នាងខ្ញុំសូមគោរពជំរាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ចំពោះដីទំហំ១៨,៥០ ម៉ែត្រ គុណ ១៦,៥០ ម៉ែត្រ ចិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង គឺនាងខ្ញុំបានទិញពីលោក ឈ្មោះពេញ និង ប្រពន្ធឈ្មោះ ឈ្មោះពេញ តាំងពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ មកម្ល៉េះ ដូចមានលិខិតផ្ទេរដីមួយកន្លែង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៥ ចុះហត្ថលេខាដោយ មេឃុំរកាជាភស្តុតាង ។ ឯផ្ទះថ្មក្រោម ឈើលើ នាងខ្ញុំ និង ប្តីនាងខ្ញុំ ជន ដួត ពិតជាបានសាងសង់ តាំងពីឆ្នាំ២០០៨ ពិតប្រាកដមែន ដែលមានលិខិតបញ្ជាក់កម្មសិទ្ធិលេខ១៧៦៧/២០០៨ ចុះថ្ងៃទី២៤ ខែ១២ ឆ្នាំ២០០៨ ចុះហត្ថលេខា ដោយលោកមេឃុំរកាផងដែរ ឯស្នាមមេដៃដែលមានឈ្មោះ និង ឈ្មោះ គឺ យើងខ្ញុំមានគំរោងផ្ទេរឱ្យអ្នកទាំងពីរនាក់នេះ តែជាក់ស្តែង អ្នកទាំងពីរនាក់មិនយកទេ ហើយក៏មិនស្នាក់នៅដែរ ហើយយើងខ្ញុំក៏នៅតែជាម្ចាស់កម្មសិទ្ធិលើដី និង ផ្ទះនេះរហូតដល់បច្ចុប្បន្ន។ ចំណែកនៅក្នុង លិខិតបញ្ជាក់កម្មសិទ្ធិខាងលើ ត្រង់ចំនុច " កាន់កាប់ប្រើប្រាស់តាំងពីឆ្នាំ២០០៩ " ជាកំហុសអក្ខរាវិរុទ្ធ ដែលតែងតែកើតមាន នៅក្នុងឯកសាររបស់អាជ្ញាធរ អ្វីដែលសំខាន់គឺ ឯកសារទាំងនោះ មិនមែនក្លែងបន្លំ ឺ ជាឯកសារក្លែងក្លាយ និង ជាអង្គហេតុពិត ។ ម្យ៉ាងទៀត កូននាងខ្ញុំឈ្មោះ និង ឈ្មោះ បានរៀបការនៅឆ្នាំ២០១០ នេះទេ ហើយអ្នកទាំងពីរប្តីប្រពន្ធ ទើបតែមកស្នាក់នៅលើដី-ផ្ទះទំនាស់ នៅឆ្នាំ២០១២ ដោយនៅក្នុងផ្ទះមានបន្ទប់ថ្មដែលនាងខ្ញុំធ្វើរួចជាស្រេច ជាការចំណាយរបស់នាងខ្ញុំទាំងអស់ ។ ឯយ៉ាបមុខផ្ទះ ដែលកូននាងខ្ញុំ និង ឈ្មោះ ទើបតែតក្នុងឆ្នាំ២០១៣ គឺ អាចដោះបាន ហើយ លោក ដោះយកទៅវិញចុះ ។ លើសពីនេះទៅទៀត ការអះអាងរបស់ឈ្មោះ ដែលថាបានទិញដី-ផ្ទះ ពីឈ្មោះ គឺ មិនមានឯកសារផ្ទេរសិទ្ធិពីឈ្មោះ ទៅ ដែរ ហើយក៏មិនមានឯកសារទិញលក់ដី-ផ្ទះ មិនមានឯកសារប្រគល់ទទួលលុយជាពិសេស សាម៉ីខ្លួន ឈ្មោះ ក៏មិនបានបញ្ជាក់ថាៈលក់ ដី-ផ្ទះ នេះ ឱ្យទៅ ឈ្មោះ ដែរ ។ បើតាមរបាយការណ៍របស់លោក មេភូមិមេលប់ គោរពជូន អនុប្រធានតុលាការខេត្តព្រៃវែង គឺ ការអះអាងរបស់ឈ្មោះ ទេ ដែលមិនគួរឱ្យជឿទុកចិត្តបាន ដោយ នៅពេលសម្រុះសម្រួលនៅថ្នាក់ឃុំ ឈ្មោះ បានឆ្លើយ

...ក៏តុលាការថា: បានប្រគល់ប្រាក់8000$នៅសល់3000$ទៀត ហើយលុយ8000$ ឱ្យថ្លៃផ្ទះនេះ គឺ ខ្លួនបានមកពី រកស៊ីចងការប្រាក់ និង លក់មាស។ តែពេលមេភូមិចុះស្រាវជ្រាវដល់កូនបំណុល គេថា គេចងការពី នាងខ្ញុំទេ ។ ចំណែកមាស មិនដឹងលក់ឱ្យ ជាងណាទេ ។ ដូចនេះ ទាក់ទង ដី-ផ្ទះ ពិតជាកម្មសិទ្ធិរបស់យើងខ្ញុំពិតប្រាកដ មិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ ទៀយ ។

ចំណែកម៉ូតូហុងដា C125 ផលិតឆ្នាំ២០០៨ និង ខ្សែក ផ្លាកទីន ចិញ្ចៀន កងដៃ គឺ នាងខ្ញុំជា អ្នកចំណាយលុយទិញទាំងអស់ ។ ម៉ូតូនេះ ក្នុងឆ្នាំ២០០៨ នាងខ្ញុំទិញត ក្នុងតំលៃ1,300$ ពីឈ្មោះ ដែលទើបតែប្រើប្រាស់ និងទិញបានតែជាងមួយខែ ។ ក្រោយមក កូននាងខ្ញុំបានភ្ជាប់ពាក្យជាមួយឈ្មោះ នាងខ្ញុំក៏ឱ្យលុយទៅឈ្មោះ ១០ម៉ឺនរៀល និង អត្តសញ្ញាណរបស់នាងខ្ញុំ ឱ្យទៅធ្វើ កាតគ្រីម៉ូតូឱ្យនាងខ្ញុំ ហើយកូនស្រីនាងខ្ញុំ និង ឈ្មោះ ប្រើប្រាស់រហូតមក តែនាងខ្ញុំទើបតែដឹងនៅពេលមានទំនាស់កើតឡើង ថា ម៉ូតូត្រូវបានដាក់ឈ្មោះ ទៅវិញ ។ ឯខ្សែក ផ្លាកទីន ចិញ្ចៀន កងដៃ ទំងន់០៩ជី ០១ហ៊ុន នាងខ្ញុំលក់បាន***២លាន៨ម៉ឺនរៀល*** សំរាប់ព្យាបាលជំងឺរបស់កូនស្រីនាងខ្ញុំឈ្មោះ ដែលស្ថិតក្នុងស្ថានភាពធន់ធរ អស់***២លាន៥០ម៉ឺនរៀល*** ហើយខាតលើចំណាយបុណ្យសព និង បុណ្យ០៧ថ្ងៃ ***អស់១លាន៥០ម៉ឺន***រៀល និង ខាតលើបុណ្យ១០០ថ្ងៃ អស់០២លាន៥០ម៉ឺនរៀល ។ ចំណែកឯលោក វិញ ថ្លៃព្យាបាលជំងឺប្រពន្ធក៏មិនជួយចេញអ្វីទាំងអស់ ហើយ ចំណាយធ្វើបុណ្យក៏មិនចំណាយអ្វីដែរ ។

អាស្រ័យហេតុនេះ ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ តាមរយ:សាលដីកាលេខ០៤ (ក្រ IV សស) ចុះថ្ងៃទី១៥ ខែ០៩ ឆ្នាំ២០១៤ គឺ នាងខ្ញុំអាចទទួលយកបានហើយ ដោយនាងខ្ញុំ សំណូមពរ **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសំរេចតម្កល់សាលាដីកាសាលាឧទ្ធរណ៍នេះដដែល ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និង ថ្លែងអំណរគុណអំពីនាងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥

ស្នាមដៃស្តាំ



[redacted]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿងរដ្ឋប្បវេណី
លេខៈ ៣៣
ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥

# របាយការណ៍

តាមដីកាចាត់តាំងលេខ ៤៦ច.ត ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកឧត្តមប្រធាន តុលាការកំពូល ឱ្យពិនិត្យអំពីទម្រង់និងគតិច្បាប់នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ របស់តុលាការកំពូល និងសាលដីការដ្ឋប្បវេណីលេខ ០៩ក្រ.IV.សស ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍រវាង៖

**<u>ដើមចោទ:</u>** លោក (ជាដើមបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ មានទីលំនៅសព្វថ្ងៃ ភូមិមេលប់ ឃុំរការ ស្រុកពារាំង ខេត្តព្រៃវែង។

មានអ្នកតំណាងដោយអាណត្តិលោកស្រី មេធាវី

**<u>ចុងចម្លើយ:</u>** ឈ្មោះ (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី និងប្តីឈ្មោះ អាយុ៤៩ឆ្នាំ មុខរបរធ្វើស្រែ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ មេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ។

មានអ្នកតំណាងដោយអាណត្តិលោកមេធាវី

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារដីភូមិទំហំ ១៨ម គុណ ១១ម និងផ្ទះសង់អំពីឈើលើថ្មក្រោមទំហំ ៨ម គុណ ៨,៤ម ខ្សែកផ្លាកទីនចំនួន ៩ជី ២ហ៊ុន និងម៉ូតូ C125 ស៊េរី ២០០៨ មួយគ្រឿង។

**I.<u>អំពីអង្គហេតុ:</u>**

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៣ របស់ឈ្មោះ បញ្ជាក់ថា: នៅឆ្នាំ២០១០ ដើមចោទឈ្មោះ រៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ដួត សាវីច ហើយបានរួមរស់ជាមួយគ្នា មានកូន ០១នាក់ ឈ្មោះ ភេទប្រុស អាយុ០៣ឆ្នាំ បានរកស៊ីជាមួយគ្នា ទិញបានដីភូមិទំហំ១៨ម៉ែត្រ គុណ ១១ម៉ែត្រ និងផ្ទះប្រក់គ្បឿង (ឈើរខាងលើ ខាងក្រោមថ្ម) ទំហំ៨ម៉ែត្រ គុណ ៨,៤ម៉ែត្រ ស្ថិតក្នុងភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ដីភូមិ និងផ្ទះនេះទិញពីបងថ្លៃឈ្មោះ ដួត សារុធ មានតម្លៃ ១១,០០០ ដុល្លារអាមេរិក ទិញម៉ូតូសេ១២៥ ស៊េរីឆ្នាំ២០០៨ មួយគ្រឿង មានតម្លៃ៥០០ ដុល្លារអាមេរិក និងខ្សែកផ្លាកទីនទម្ងន់ ៩ជី ២ហ៊ុន ឯការរួមរស់នៅជាមួយគ្នា បានសេចក្តីសុខនិងគ្នាមិនដែលឈ្លោះប្រកែកអ្វីទេ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ប្រពន្ធដើមចោទមានជម្ងឺរលាកខួរក្បាល ក៏បានស្លាប់ទៅ បន្សល់ទុកកូនប្រុសមួយនាក់ កំព្រាម្តាយ ស្រាប់តែម្តាយក្មេកដើមចោទយកខ្សែក ម៉ូតូសេ១២៥ ស៊េរីឆ្នាំ២០០៨ មួយគ្រឿង ព្រមទាំងដេញដើមចោទ និងកូនឱ្យចុះចេញពីលើផ្ទះរបស់ដើមចោទថែមទៀត។

តាមពាក្យបណ្ដឹងតប ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣ របស់ឈ្មោះ និងប្រពន្ធឈ្មោះ

បានប្ដឹងពីឈ្មោះ ឲ្យចុះចេញពីផ្ទះរបស់ខ្លួន ដោយសំអាងហេតុថា៖

១-ដីភូមិ និងផ្ទះនេះ ជាកម្មសិទ្ធិរបស់ខ្លួន ពុំមានការពាក់ព័ន្ធជាមួយឈ្មោះ ទេ ព្រោះខ្លួនមានលិខិតបញ្ជាក់ពីកម្មសិទ្ធិរបស់ ខ្លួនផ្ទាល់។

២-សុំទាមទារប្រាក់ដែលពាក់ព័ន្ធនឹងឈ្មោះ មាន៖ ថ្លៃជួសជុលបន្ទប់សរុបមានចំនួន ៥០០ដុល្លារអាមេរិក,ថ្លៃព្យាបាលជម្ងឺមុនពេលកូនស្រីរបស់ខ្លួនស្លាប់សរុបចំនួន២.៥០០.០០០រៀល (ពីរលានប្រាំសែនរៀល), ថ្លៃធ្វើបុណ្យក្រោយពេលស្លាប់សរុបចំនួន ១.៥០០.០០០រៀល (មួយលានប្រាំសែនរៀល), ប្រាក់សុទ្ធចំនួន ៥.០០០.០០០រៀល (ប្រាំលានរៀល), ខ្សែកផ្កាកទីន ១ខ្សែ ស្មើនឹងទម្ងន់ ២ជី មានក្រោយពីពេលរៀបការរួចហើយ។

៣-ដីស្រែ ២កន្លែង គឺចំណុចត្រាំគ ទំហំ ៦០អា និងចំណុច ប្រគួចទំហំ ៦០អា។

៤-ទូ ១គ្រឿង។

## II-អំពីសេចក្ដីសម្រេចរបស់តុលាការៈ

តាមសាលក្រមរដ្ឋប្បវេណីលេខ ០២(ខ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១/ ទទួលស្គាល់បណ្ដឹងទាមទារ របស់ដើមចោទឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២/បង្គាប់ឱ្យចុងចម្លើយឈ្មោះ ណុច សារឿន ប្រគល់ម៉ូតូ ០១គ្រឿង ម៉ាកសេ១២៥ ស៊េរីឆ្នាំ២០០៨ និងខ្សែរកផ្កាកទីន, ចិញ្ចៀន, កងដៃ សរុបទម្ងន់ ៥ជី ២ហ៊ុន អោយទៅឈ្មោះ ជាដើមចោទវិញនៅពេលដែលសាលក្រមចូលជាស្ថាពរ។

៣/ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់ចុងចម្លើយ។

៤/សាលក្រមនេះ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ចំពោះមុខគូភាគី សម្រេចបើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

<u>សាលាដំបូង ខេត្តព្រៃវែង សម្រេចដោយសំអាងហេតុថាៈ</u>

តាមលទ្ធផលនៃសាកសួរ សាម៉ីភាគី ការពិនិត្យភស្ដុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា តាមអង្គហេតុនេះ គូភាគីទទួលស្គាល់ថាៈ ដើមឡើយដី និងផ្ទះទំនាស់នេះជារបស់ចុងចម្លើយ តែបានលក់អោយទៅដើមចោទជាកូនហើយ។

ក្នុងរឿងនេះ ចំណុចវិវាទនៅត្រង់ថាៈ បានទទួលប្រាក់តែ ១.០០០$ (មួយពាន់ដុល្លារអាមេរិក) ប៉ុណ្ណោះ ក្នុងចំនួនថ្លៃលក់សរុប ១២.០០០$ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក)។ ចំណុចនេះគប្បីតុលាការពិចារណា។

ការលក់ទិញ និងប្រគល់ប្រាក់របស់ភាគីនេះ ពុំមានឯកសារជាលាយលក្ខ័អក្សរទេ ដោយសំអាងថា

ជាម្តាយ និងកូន ។

យល់ឃើញថា: ការអះអាងផ្តល់ចម្លើយរបស់ចុងចម្លើយ នៅពេលទាញហេតុផលដោតផ្ទាល់មាត់ គ្មានមូលហេតុត្រឹមត្រូវដូចជា: ផ្ទះ និងដីដែលចុងចម្លើយទាមទារយកវិញនោះ គឺជាផ្ទះ និងដីដែលចុងចម្លើយបានលក់អោយទៅដើមចោទជាកូនឈ្មោះ និងកូនប្រសារឈ្មោះ ។ ហើយ ហើយដើមចោទក៏បានសាងសង់បន្ថែម គឺរៀបចំបន្ទប់ខាងក្រោមផ្ទះឈើរនោះ មានទាំងបន្ទប់គេង និងបន្ទប់ទឹក ព្រមទាំងបានតយាបចាប់ដែកផ្ទះ ដោយពុំមានភាគីណាមករារាំងឡើយ។

តាំងពីទិញ រហូតមកដល់សាងសង់បន្ថែម ភាគីដើមចោទបានរស់នៅដោយសុខសាន្តដោយពុំមានបញ្ហាអ្វីឡើយ តែនៅពេលប្រពន្ធរបស់ដើមចោទ ( ) ចាប់មានជម្ងឺហើយបានស្លាប់ក៏កើតមានទំនាស់ ដោយចុងចម្លើយត្រូវជាម្តាយក្មេកបានដេញកូនប្រសារ (ដើមចោទ) អោយចុះចេញពីផ្ទះនេះ ដោយអះអាងថា: ពុំទាន់បានទូទាត់ប្រាក់ថ្លៃទិញផ្ទះនេះគ្រប់នៅឡើយ។ ចំណុចនេះ គប្បីតុលាការពិចារណា។

ករណីនេះ បើដើមចោទមិនបានបង់ប្រាក់ថ្លៃទិញផ្ទះនោះ មិនមែនធ្វើជាលាយល័ក្ខអក្សទេ ដោយហេតុថា: ជាម្តាយ និងកូន ។ ជាក់ស្តែងដូចជា ម៉ូតូ ហុងដា ម៉ាកសេ១២៥ ស៊េរី ២០០៨ ពាក់ស្លាកលេខ ដែលចុងចម្លើយ ដែលបានដកហូតយកពីដើមចោទ (កូនប្រសារ) ដោយអះអាងថា: ជាម៉ូតូរបស់ខ្លួនទិញអោយកូនស្រី (ប្រពន្ធដើមចោទ) ប្រើជាបណ្តោះអាសន្នតាំបីមុនរៀបអាពាហ៍ពិពាហ៍ មកម៉្លេះហើយគ្មានកាតគ្រី និងស្លាកលេខទេ។

ចំណុចនេះ ដើមចោទបានអះអាងថា៖ ម៉ូតូនេះ ជារបស់ខ្លួនដែលបានទិញក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ចុងចម្លើយ (ម្តាយក្មេក) បានដកហូតយកម៉ូតូនេះទៅ ដោយមានកាតគ្រីខ្លួនដាក់នៅក្រោមកែបម៉ូតូ ហើយម៉ូតូនោះផ្លាកលេខ ១B ៦៥៤០ ដែលជាកម្មសិទ្ធិរបស់ខ្លួន តែចុងចម្លើយយកឯកសារនេះលាក់បំបាត់គាង។

តាមលិខិតលេខ ១៣០ សក.ពវ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ របស់មន្ទីសាធារណៈការ និងដឹកជញ្ជូនខេត្តព្រៃវែង បានបញ្ជាក់ថា ម៉ូតូដែលមានផ្លាកលេខ ១B ៦៥៤០ ជាកម្មសិទ្ធិរបស់ឈ្មោះ ។

មាសផ្លាកទីនមាន: ខ្សែក ចិញ្ចៀន និងកងដៃទម្ងន់សរុប ៩,២ ហ៊ុន (ប្រាំបួនជីពីរហ៊ុន) ដែលចុងចម្លើយ ( ) បានដកហូតពីប្រពន្ធដើមចោទ ដែលកំពង់សម្រាកព្យាបាលនៅមន្ទីពេទ្យសូវៀតនោះ ចុងចម្លើយអះអាងថា: ជារបស់ខ្លួនដែលបានទិញអោយកូនស្រី (ប្រពន្ធដើមចោទ) មុនពេលរៀបការដែរ តែនៅពេលតុលាការសួររកឯកសារទិញលក់គ្មានផ្ទុយពីដើមចោទ គឺមានវិក័យប័ត្រទិញលក់(មាសផ្លាកទីន) ត្រឹមត្រូវ ហើយការលក់ទិញនេះ គឺស្ថិតនៅក្នុងកំឡុងពេលមានចំណងអាពាហ៍ពិពហ៍។

ការអះអាងរបស់ចុងចម្លើយ ( ) គ្មានមូលហេតុត្រឹមត្រូវដែលអាចអោយតុលាការពិចារណាបានឡើយ ដោយហេតុថា: ប្រសិនបើប្រពន្ធរបស់ ( ) ត្រូវជាកូនបង្កើតរបស់ចុងចម្លើយពុំបានស្លាប់នោះទេ ក៏ពុំមានមូលហេតុក្នុងការទាមទារដី និងផ្ទះនេះវិញដែរ។ ការទាមទារនេះគឺ ចុងចម្លើយមានចេតនាទុច្ចរិតចង់បានដី និងផ្ទះ ដែលបានលក់ទៅអោយកូនរួចហើយមកគ្រប់គ្រងវិញ

ដោយសំអាងថា: ការលក់ទិញពុំមានធ្វើជាលាយល័ក្ខអក្សរ។

-តាមរបាយការណ៍របស់លោក សមាជិកក្រុមប្រឹក្សាឃុំរកា បានបញ្ជាក់ថា: នៅឆ្នាំ២០១១ ឈ្មោះ និងប្រពន្ធឈ្មោះ ពិតជាបានទិញផ្ទះ និងដីពីឈ្មោះ (ជាម្ដាយ)។ ទាំងពីរនាក់ប្ដីប្រពន្ធ បានរស់នៅលើផ្ទះនោះរហូតមក ដែលពុំមានបញ្ហាឡើយ ថែមទាំងបានធ្វើបន្ទប់គេង បន្ទប់ទឹកក្រោមផ្ទះ នឹងតយាបចាប់ដែក នៅខាងមុខនឹងសងខាងផ្ទះ ដោយពុំមានអ្នកណាមករារាំងឡើយ។ លុះដល់ឆ្នាំ២០១៣ ក្រោយពីឈ្មោះ ជាប្រពន្ធរបស់ដើមចោទស្លាប់ទៅបាន ០៧ថ្ងៃ ឪពុកម្ដាយរបស់ឈ្មោះ បានបណ្ដេញឈ្មោះ ជាកូនប្រសារ អោយចុះចេញពីផ្ទះ ដោយអោយយកទាំងកូនប្រុសអាយុ០៣ឆ្នាំ ទៅជាមួយផង មិនតែប៉ុណ្ណោះ ឈ្មោះ និង (ចុងចម្លើយ) បានចាក់សោរផ្ទះ និងយកគោទៅចងរំខាននៅកន្លែងរកស៊ីរបស់ទៀតផង។ ខ្លួនជាក្រុមប្រឹក្សាឃុំដែលបានរស់នៅទីនោះ ផ្ទាល់បានដឹងឮយ៉ាងច្បាស់ពីបញ្ហានេះ ហើយក៏មានប្រជាពលរដ្ឋនៅក្នុងភូមិមេលប់ជាច្រើននាក់ទៀត ក៏បានដឹងលឺពីបញ្ហានេះដែរ។

តាមចម្លើយរបស់សាក្សីឈ្មោះ យឹង ម៉ឺន ក៏ដូចជាចម្លើយរបស់សាក្សីឯទៀតដូចមានឈ្មោះ ខាងលើ បានឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នាថា: ខ្លួនបានដឹងថាឈ្មោះ និងប្រពន្ធឈ្មោះ បានទិញដី និងផ្ទះពីបងថ្លៃរបស់គេ ឈ្មោះ ប្រាកដមែន ព្រោះផ្ទះនោះ ចុងចម្លើយបានចែកមរតកក៏អោយទៅកូនបងឈ្មោះ ។ ក្រោយពីទិញហើយ ឃើញប្ដីប្រពន្ធគេរស់នៅលើផ្ទះនេះរហូតមក មិនដែលមានបញ្ហាអ្វីទេ។ ឯបងថ្លៃរបស់ឈ្មោះ ( ) ក្រោយពីលក់ផ្ទះនោះអោយទៅប្អូនហើយ ក៏ទៅទិញផ្ទះនៅឯផ្សារវិញ ។ ចម្លើយនេះ ស៊ីសង្វាក់ទៅនឹងចម្លើយរបស់ឈ្មោះ ដួត សារុធ ដែលបានទទួលស្គាល់ថា: នៅក្នុងឆ្នាំ២០១០ ក្រោយពីប្អូនស្រីខ្លួន ( ប្រពន្ធ ) រៀបការរួច ខ្លួនពិតជាបានទិញដីនៅផ្សារប្រាកដមែន។ អង្គហេតុនេះ គប្បីតុលាការពិចារណាតាមច្បាប់។

យល់ឃើញថា: ការលើកឡើងរបស់លោកមេធាវី ចំពោះឯកសារបញ្ជាក់កម្មសិទ្ធិដីធ្លី និងផ្ទះ ដែលបញ្ជាក់ដោយលោកមេភូមិ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ថាមានភាពមិនប្រក្រតី នៃលិខិតដោយហេតុថា: ការកាន់កាប់ប្រើប្រាស់នៅឆ្នាំ២០០៩ ឯលិខិតបញ្ជាក់កម្មសិទ្ធិធ្វើនៅឆ្នាំ២០០៨ ដែលនៅឆ្នាំ២០០៨នេះ មេភូមិមេលប់ គឺលោក មិនមែនជាលោក ឡើយ។ ចំណុចនេះ គប្បីតុលាការពិចារណាតាមច្បាប់។

យល់ឃើញថា: ខ្សែក ចិញ្ចៀន និងកងដៃទម្ងន់ ៩ជី ២ហ៊ុន ដើមចោទមានឯកសារទិញលក់ពីជាងត្រឹមត្រូវ នៅក្នុងកំឡុងដែលពួកគេរកស៊ីជាមួយគ្នា ដូចមានបញ្ជាក់ក្នុងលិខិតទិញលក់ ។

យល់ឃើញថា: តាមលិខិតបញ្ជាក់របស់មន្ទីសាធារណៈការ និងដឹកជញ្ជូនខេត្តព្រៃវែង បានបញ្ជាក់ថា: ឈ្មោះ ជាកម្មសិទ្ធិនៃម៉ូតូម៉ាកសេ១២៥ ស៊េរី២០០៨ ពាក់ផ្លាកលេខ 1B-៦៥៤០ ប្រាកដមែន។

យល់ឃើញថា: យោងតាមហេតុផលខាងនេះ តុលាការទទួលស្គាល់ថា: អង្គហេតុ និងមូលហេតុនៃការទាមទាររបស់ដើមចោទមានអត្ថិភាព។

យល់ឃើញថា: បណ្ដឹងទាមទាររបស់ឈ្មោះ និងឈ្មោះ ចុះថ្ងៃទី២២ ខែធ្នូ

ឆ្នាំ២០១៣ ពុំមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ គប្បីតុលាការច្រានចោលការទាមទារនេះ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០២(ខ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

តាមសាលដីការដ្ឋប្បវេណីលេខ ០៤ក្រ.IV.សស ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ មានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ របស់ចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ខ្លះ។

២-ទទួលស្គាល់បណ្តឹងតបចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣ របស់ចុងចម្លើយ និងប្តីឈ្មោះ ត្រង់ចំណុចទី១ ការទាមទារឲ្យ ចុះចេញពីផ្ទះ និងដីទំនាស់ទុកជាត្រឹមត្រូវតាមច្បាប់។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ: ០២(ខ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់សេចក្តីសម្រេចចំណុចទី២ បង្គាប់ឲ្យចុងចម្លើយ ប្រគល់ម៉ូតូ ០១ គ្រឿង ម៉ាកសេ១២៥ សេរីឆ្នាំ២០០៨ ឲ្យឈ្មោះ រឿន សុជាតិ ជាដើមចោទវិញ។ ចំណុចក្រៅពីនេះ ត្រូវលុបចោល។

៤-បង្គាប់អោយដើមចោទឈ្មោះ ចាកចេញពីផ្ទះ និងដីទំនាស់ទំហំ ១៨ម គុណ ១១ម ផ្ទះទំហំ ៨ម គុណ ៨,៤ម ឈើលើ ថ្មក្រោម ស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង និងឲ្យចុងចម្លើយឈ្មោះ ប្រគល់ប្រាក់ចំនួន ១,០០០$ ឲ្យទៅ ដើមចោទឈ្មោះ វិញ។

៥-សាលដីកានេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនាថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៤ បើកផ្លូវប្តឹងសាទុក្ខក្នុងរយៈពេល០១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនពីសាលដីកានេះ។

<u>សាលាឧទ្ធរណ៍សម្រេចដោយសំអាងហេតុថា:</u>

-តាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងឃើញថា ចុងចម្លើយ សុំបដិសេធសាលក្រមរបស់សាលាដំបូងខេត្តព្រៃវែង ដោយសុំទាមទារឲ្យសាលាឧទ្ធរណ៍លើកយកបណ្តឹងតបរបស់ខ្លួន និងប្តី ចុះថ្ងៃទី២២ ខែ១២ ឆ្នាំ២០១៣ ដែលបានប្តឹងឲ្យឈ្មោះ ចុះចេញពីផ្ទះរបស់ខ្លួន សុំទាមទារម៉ូតូម៉ាកសេ ១២៥ សេរីឆ្នាំ ២០០៨ និងគ្រឿងអលង្កាដោយអះអាងថា ផ្ទះនិងដី ទំនាស់ជាកម្មសិទ្ធិរបស់ខ្លួន និងប្តីពុំបានប្រគល់ឲ្យឈ្មោះ ទេ ហើយផ្ទះ និងដីនោះ ខ្លួនបានអោយកូនឈ្មោះ ស្នាក់នៅបណ្តោះអាសន្នបន្ទាប់ពីរៀបការជាមួយ ហើយខ្លួនបានប្រាប់កូនថាលក់ឲ្យតម្លៃ ១២,០០០$ ហើយកូនបានអោយប្រាក់ខ្លួន ១,០០០$ នៅខ្វះ ១១,០០០$ ពេលកូនស្រីខ្លួនស្លាប់ទៅឈ្មោះ មានគំនិតលោភលន់ចង់បានផ្ទះ និងដីរបស់ខ្លួន និងថាបានអោយប្រាក់ឈ្មោះ គ្រប់ចំនួនរួចហើយ តែតាមពិតពុំបានឲ្យទេ ។ បន្ទាប់ធ្វើបន្ថែមគឺខ្លួនជាអ្នកចេញប្រាក់អោយកូនធ្វើ។ ខ្លួនសុំទាមទារផ្ទះ និងដីនោះសុំប្រគល់លុយ ១.០០០$ វិញ ឈប់លក់ហើយ ព្រោះកូនស្រីរបស់ខ្លួនស្លាប់ហើយ ហើយ ក៏ពុំទាន់ឲ្យប្រាក់ខ្លួនគ្រប់ដែរ ។ ខ្សែក ចិញ្ចៀន កងដៃ ខ្លួន

ដោះយកពីកូនមែន ពេលឈឺដេកពេទ្យ លក់ព្យាបាល និងធ្វើបុណ្យសពអស់ហើយ ម៉ូតូខ្លួនគ្រប់គ្រង។

-តាមស្តាប់អំណានចម្លើយរបស់ដើមចោទ បានអះអាងថា ខ្លួនប្តឹងទាមទារផ្ទះម៉ូតូ១គ្រឿង និងខ្សែក ផ្កាកទីន ចិញ្ចៀន កងដៃ សរុប ៩ជី ២ ហ៊ុន ពីចុងចម្លើយ ណុច សារឿន ដោយសំអាងថា កាលពីឆ្នាំ២០១០ ខ្លួនបានរៀបការជាមួយឈ្មោះ ត្រូវជាកូនរបស់ចុងចម្លើយ ពេលរកស៊ីជាមួយប្រពន្ធមានលុយក៏បានទិញផ្ទះពីបងថ្លៃឈ្មោះ តម្លៃ ១១.០០០$ ផ្ទះទំហំ ៤ម គុណ ៨,៥ម សង់លើដីទំហំ១៦ម គុណ ១១ម បានប្រគល់ប្រាក់ឲ្យបងថ្លៃចំនួន និងចូលទៅរស់នៅបានសាងសង់បន្ទប់ថ្មខាងក្រោម តយ៉ាបខាងមុខ ទិញ ខ្សែកផ្កាកទីន កងដៃ ចិញ្ចៀន និងកងដៃ ឲ្យប្រពន្ធពាក់ និងទិញម៉ូតូ ០១ គ្រឿង នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ប្រពន្ធខ្លួនស្លាប់ទៅធ្វើបុណ្យ៧ថ្ងៃរួច ម្តាយក្មេកដេញខ្លួនឲ្យចុះចេញពីផ្ទះ និងដកយកម៉ូតូ ១គ្រឿង ចំពោះខ្សែក គ្រឿងអលង្កា ម្តាយក្មេកដកយកនៅពេលប្រពន្ធខ្លួនឈឺ ដឹកយកមកមន្ទីរពេទ្យរុស្ស៊ី។

-តាមស្តាប់អំណានចម្លើយសាក្សី បានអះអាងថា ខ្លួនពុំបានលក់ដី និងផ្ទះឲ្យទៅឈ្មោះ ទេ ហើយក៏ពុំដែលទទួលលុយពី ដែរ និងផ្ទះនោះជាកម្មសិទ្ធិរបស់ម្តាយខ្លួន ។ ខ្លួនពុំមានសិទ្ធិក្នុងការលក់ដូរទេ ។ នៅឆ្នាំ ២០១០ ក្រោយពីប្អូនស្រីខ្លួនការរួច ខ្លួនពិតជាបានទិញដីនៅផ្សារប្រាកដមែនដែលជាលុយផ្ទាល់ខ្លួន ចំណែកម៉ូតូម៉ាកសេ ១២៥ សេរីឆ្នាំ២០០៨ ម្តាយខ្លួនទិញអោយខ្លួន និងប្អូនស្រី ជិះទៅរៀនដែរ គ្រឿងអលង្ការម្តាយទិញឲ្យពាក់តាំងពីនៅក្មេង។

-តាមស្តាប់អំណាន ចម្លើយឲ្យការណ៍របស់សាក្សី និង ដែលជាអជ្ញាធរមូលដ្ឋានបានដាក់បញ្ជាក់ថា ពួកខ្លួនជាអ្នកដោះស្រាយវិវាទរវាងដើមចោទ និងចុងចម្លើយ ហើយបានសួររកប្រាក់ចំណូលដើម្បីទិញផ្ទះ របស់ដើមចោទ ដែលថា ដើមចោទពុំមានខ្ចីប្រាក់ពីអ្នកភូមិ និងពុំប្រាប់ពីកន្លែងលក់មាស ហើយសាក្សីឈ្មោះ ពេលសួរ ថាបានអោយលុយទិញផ្ទះទៅម្តាយក្មេក ៨,០០០$ ខ្វះ ៣,០០០$ រីឯចម្លើយសាក្សីឈ្មោះ ពេលខ្លួនសួរឈ្មោះ ថាអោយលុយទៅម្តាយក្មេក ៦,០០០$ គឺចម្លើយពុំស៊ីសង្វាក់ ពុំអាចអោយតុលាការជឿបានទេ ព្រោះពុំមានធ្វើកំណត់ហេតុ និងពុំមានការទទួលស្គាល់ពី ។

-ចម្លើយសាក្សីឈ្មោះ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ឈ្មោះ ពិតជាបានទិញដី និងផ្ទះទំនាស់នោះ ពីឈ្មោះ ដួត សារុធ និងបានរៀបបន្ទប់ថ្មរ និងតយ៉ាប ខាងមុខ ។ សាក្សីឈ្មោះ ថា នៅឆ្នាំ២០១១ ឈ្មោះ និងប្រពន្ធឈ្មោះ បានទិញដី និងផ្ទះពីឈ្មោះ (ជាម្តាយ) ចម្លើយសាក្សីទាំងអស់នោះពុំអាចយកជាការបានព្រោះ ការឆ្លើយនោះត្រូវបានឈ្មោះ បដិសេធហើយក៏ពុំមានឯកសារឬលិខិតទិញលក់ និងប្រគល់ទទួលប្រាក់ជាមួយឈ្មោះ នោះទេ។

-មេធាវី ធ្វើសេចក្តីថ្លែងការណ៍ថា សុំឲ្យសាលាឧទ្ធរណ៍សម្រេចតាមបណ្តឹងតបរបស់កូនក្តីខ្លួន ដោយលើកហេតុផលថា: ដី និងផ្ទះទំនាស់នោះគឺជាកម្មសិទ្ធិរបស់កូនក្តីខ្លួន មានឯកសារត្រឹមត្រូវ បញ្ជាក់ពីមេឃុំ ម៉ូតូ និងគ្រឿងអលង្ការ កូនក្តីខ្លួនទិញអោយកូនមុនរៀបការ។

-មេធាវី សុំអោយតុលាការតម្កល់សាលក្រមរបស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ ដោយបញ្ជាក់ថា: កូនក្តីខ្លួនបានទិញដី និងផ្ទះទំនាស់ពីចុងចម្លើយបានអោយប្រាក់គ្រប់ចំនួនហើយ ទើបចុងចម្លើយអោយកូនខ្លួនទៅរស់នៅ ហើយអោយធ្វើបន្ទប់ និងតយ៉ាបខាងមុខ ចំណែកម៉ូតូ និងគ្រឿងអលង្ការ ជារបស់កូនក្តីខ្លួន ដែលមានកាតគ្រីម៉ូតូ និងលិខិតទិញលក់មាស។

-ពាក្យបណ្តឹងចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៣ ចុងចម្លើយបានប្តឹងអោយដើមចោទ ចុះចេញពីផ្ទះរបស់ខ្លួន និងទាមទារប្រាក់ថ្លៃជួសជុលបន្ទប់ចំនួន ៥០០$ ថ្លៃព្យាបាលជម្ងឺ និងចំណាយបុណ្យសពរបស់កូន ៤លានរៀល ខ្សែករ១ខ្សែ ២ជី ទាមទារដីស្រែ ៦០អា ពីរកន្លែង ប៉ុន្តែសាលាដំបូងខេត្តព្រៃវែងពុំបានសម្រេចពីការទាមទាររបស់ចុងចម្លើយ បើពិនិត្យលើខ្លឹមសារបណ្តឹងនោះ គឺជាបណ្តឹងតបត្រង់ការទាមទារដើមចោទអោយចុះចេញពីផ្ទះ ខ្លួនសុំប្រគល់ប្រាក់ ១០០០$ អោយដើមចោទវិញ ។ គប្បីសាលាឧទ្ធរណ៍ យកមកពិចារណា ហើយនៅពេលទាញហេតុផលនោះ ចុងចម្លើយពុំបានទារប្រាក់ថ្លៃជម្ងឺ និងបុណ្យសពកូន និងទាមទារដី ៦០អា ពីរកន្លែង ពីឈ្មោះ ទេ។

-តាមការអះអាងរបស់ភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិ ឲ្យភាគី និងចម្លើយបំភ្លឺរបស់សាក្សី ឃើញថា ពុំមានកិច្ចសន្យាលក់ ទិញ រវាងដើមចោទ និង និងពុំមានលិខិតប្រគល់ទទួលប្រាក់ ។ តាមការអះអាងរបស់ដើមចោទ ថា ទិញពីបងថ្លៃឈ្មោះ បានអោយប្រាក់គ្រប់ចំនួនហើយ តែឈ្មោះ បដិសេធថាពុំបានលក់ ហើយក៏ពុំបានទទួលប្រាក់ដើមចោទដែរ ហើយក៏គ្មានសាក្សីណាបានដឹងអំពីតម្លៃ និងឃើញដើមចោទប្រគល់ប្រាក់អោយឈ្មោះ ដែរ។ ប៉ុន្តែតាមការអះអាងដើមចោទ ថាខ្លួនទទួលប្រាក់តែ ១.០០០$ ពីកូន ដួត សាវិច និងកូនសារ នៅខ្វះ ១១,០០០$ ទៀត កូនពុំទាន់បានអោយគ្រប់ទេ។ បើតាមឯកសារលិខិតបញ្ជាក់របស់មេឃុំ និងការអះអាងរបស់ភាគីផ្ទះ និងដីទំនាស់ជាកម្មសិទ្ធិរបស់ចុងចម្លើយ ដូចនេះ ចុងចម្លើយមានសិទ្ធិឈប់លក់វិញនៅពេលដើមចោទ ពុំបានចេញប្រាក់មកអោយខ្លួន ។ ម៉ូតូម៉ាកសេ ១២៥ សេរីឆ្នាំ២០០៨ មានលិខិតបញ្ជាក់ថា ជាកម្មសិទ្ធិរបស់ដើមចោទ ដូចនេះគប្បីច្រានចោលការទាមទាររបស់ចុងចម្លើយ។ គ្រឿងអលង្កាប្តាទីនទម្ងន់ ៩ជី ២ហ៊ុន ដើមចោទមានវិក័យប័ត្រទិញលក់មែន ប៉ុន្តែតាមការអះអាងរបស់ចុងចម្លើយថា ខ្លួនលក់ព្យាបាលកូន និងធ្វើបុណ្យសពអស់ហើយ ចំណុចនេះដើមចោទក៏ទទួលស្គាល់ថាពេលប្រពន្ធខ្លួនឈឺដឹកយកទៅមន្ទីរពេទ្យ ម្តាយក្មេកដោះយកពីប្រពន្ធខ្លួន ហេតុនេះ សាលាឧទ្ធរណ៍ យល់ឃើញថា ចុងចម្លើយជាអ្នកចំណាយប្រាក់ថ្លៃព្យាបាលជំងឺ និងបុណ្យសពរបស់កូន គប្បីលុបចោលការសម្រេចឲ្យចុងចម្លើយសងគ្រឿងអលង្ការទៅដើមចោទ។

-ពាក្យបណ្តឹងតបចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៣ របស់ចុងចម្លើយ សាលាដំបូងខេត្តព្រៃវែង ពុំបានសម្រេចអំពីការទាមទារឡើយ គប្បីសាលាឧទ្ធរណ៍លើកយកមកពិចារណា និងសម្រេចតាមច្បាប់។

-សាលក្រមរដ្ឋប្បវេណីលេខ ០២(ខ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង បានសម្រេចសេចក្តីដោយលើកយកសំអាងហេតុ ពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយគប្បីបំពេញបន្ថែមផ្នែកសំអាងហេតុតាមការយល់ឃើញខាងលើ។ ចំណែកការសម្រេចសេចក្តីក្នុងសាលក្រមនេះ ឃើញថា

- តាមលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ដើមបណ្ដឹងសាទុក្ខបានអះអាងថាដី និងផ្ទះ ដែលស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្ត ព្រៃវែង គឺខ្លួន និង ប្រពន្ធបានទិញពី ឈ្មោះ និងបានប្រគល់ប្រាក់ថ្លៃទិញចំនួន ១១០០០ដុល្លាអាមេរិច គ្រប់ចំនួនរួចហើយ ទើបខ្លួន និង ប្រពន្ធមានសិទ្ធិចូលទៅរស់នៅក្នុងផ្ទះនោះ និងសាងសង់បន្ទប់ តយ៉ាក ក៏ប៉ុន្តែពុំមានឯកសារណាមួយបញ្ជាក់អំពីការលក់ទិញ និង ការប្រគល់ប្រាក់គ្រប់ចំនួន ទេ ការដែលដើមចោទ និង ប្រពន្ធបានចូលទៅនៅក្នុងផ្ទះនោះ ដោយសារ ប្រពន្ធរបស់ដើមចោទជាកូនស្រីបង្កើតរបស់ចុងចម្លើយ ហើយចុងចម្លើយប្រគល់ផ្ទះនោះអោយដើមចោទ និង កូនស្នាក់នៅបណ្ដោះអាសន្ន ម្យ៉ាងទៀត ពុំមានឯកសារណាមួយដែលបញ្ជាក់ថា ដីនិងផ្ទះ ទំនាស់ជាកម្មសិទ្ធិរបស់ ឈ្មោះ ទេ។

ម្យ៉ាងវិញទៀត ចុងចម្លើយបានទទួលស្គាល់ថា ខ្លួនព្រមលក់ផ្ទះអោយកូនស្រីខ្លួនក្នុងតម្លៃ ១២០០០ដុល្លាអាមេរិក ហើយកូន បានអោយប្រាក់ចំនួន ១០០០ដុល្លាអាមេរិច នៅខ្វះចំនួន ១១០០០ដុល្លាអាមេរិចទៀត ពេលនេះកូនខ្លួនស្លាប់ហើយ ដូចនេះ ខ្លួនឈប់លក់វិញហើយ ក្នុងករណីនេះ ចុងចម្លើយដែលជាអ្នកលក់ក៏មានសិទ្ធិក្នុងការរំលាយកិច្ចសន្យាចោលវិញដែរ ដោយសង២ដងនៃប្រាក់កក់ទៅអោយអ្នកទិញវិញ យោងតាមមាត្រា ៥១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-សាលាឧទ្ធរណ៍បានសម្រេចសេចក្តីអោយ ឈ្មោះ ចាកចេញពីផ្ទះទំនាស់ ដោយពុំទាន់បានពិចារណាល្អិតល្អន់ ទៅលើលិខិតផ្ទេរដីចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥ ដែលមានឈ្មោះខុស និង លិខិតបញ្ជាក់កម្មសិទ្ធិ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលខ្លឹមសារនៃលិខិតបញ្ជាក់ថា ចុងចម្លើយបានកាន់កាប់ដីទំនាស់តាំងពីឆ្នាំ ២០០៩ មក នៅឡើយ គឺមានន័យថា ការធ្វើលិខិតបញ្ជាក់នេះមុនការកាន់កាប់របស់ ចុងចម្លើយទៀត។

-ការដែលសាលាឧទ្ធរណ៍សម្រេចលប់ចោលការប្រគល់ គ្រឿងអលង្កការទៅ អោយដើមចោទ នោះជាការត្រឹមត្រូវហើយ ពីព្រោះ ដើមចោទទទួលស្គាល់ថានៅពេលប្រពន្ធខ្លួនឈឺ ចុងចម្លើយជាអ្នកដឹកយកទៅមន្ទីរពេទ្យ ដូចនេះអាចជឿបានថា ចុងចម្លើយជាអ្នកមើលថែជំងឺ រហូតដល់បុណ្យសពកូនទៀត ផ្ទុយទៅវិញការដែលដើមចោទអះអាងថាខ្លួនជាអ្នកមើលថែ ប្រពន្ធ និង ចំណាយក្នុងការបុណ្យសពនោះ ពុំមានអ្វីមកបញ្ជាក់ទេ។

- ការសម្រេចសេចក្តី របស់សាលាឧទ្ធរណ៍ តាមសាលដីកា លេខ០៤ក្រIV"សស" ចុះថ្ងៃទី១៥ ខែ ០៩ ឆ្នាំ២០១៤ ត្រឹមត្រូវខ្លះ ខុសខ្លះ។

អាស្រយ័ហេតុនេះ សូម ឯកឧត្តមប្រធាន និង ក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ និងសម្រេចតាមច្បាប់។

**ចៅក្រមទទួលបញ្ជា**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

៤៧ S. KH.

(ខ្ទង់៤
47/4)

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ ...07...

ចុះថ្ងៃទី២៣...ខែ០៧...ឆ្នាំ២០១២

# ដីកាកោះ

ន.ស

យើង ......ឌិត មុន្ទី.................ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល

បង្គាប់មកលោក-លោកស្រី..........................អាយុ...50...ឆ្នាំ មានមុខរបរ.កសិករ..........

អាសយដ្ឋាន: ផ្ទះលេខ..........ក្រុម/ផ្លូវ..........ភូមិ.....................សង្កាត់/ឃុំ ...................

ខណ្ឌ/ស្រុក...................រាជធានី/ខេត្ត.........................................

ឱ្យចូលខ្លួនមកកាន់តុលាការកំពូលនៅថ្ងៃទី...២៤...ខែ.ឧសភា.ឆ្នាំ.២០១៣. វេលាម៉ោង.៨ព្រឹក............

ដើម្បីចូលរួមពីដំណើរការទាញហេតុផលដោយផ្ទាល់មាត់ទាក់ទងនឹងវិវាទអំពី .....................

.............................................................................................

"សាមីខ្លួនត្រូវអញ្ជើញមកអោយទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលមានទំនាក់ទំនងនឹងរឿងក្តីខាងលើមកជាមួយផង ប្រសិនបើមាន"។

ភ្នំពេញ ថ្ងៃទី ២៤... ខែមេសា....ឆ្នាំ ២០១៣.

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

(ហត្ថលេខា និងត្រា)

ឌិត មុន្ទី

30. 04. 2013

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿង [illegible]
លេខ 07
ចុះថ្ងៃទី 23 ខែ 01 ឆ្នាំ 2012

# លិខិតអញ្ជើញ

ប្រធាន [illegible]
ជំរាបមក [illegible]

ការបើកសវនាការរបស់តុលាការកំពូលដើម្បីជំនុំជំរះរឿង [illegible]
ពីបណ្ដឹងសាទុក្ខរបស់លេខ [illegible] នឹងប្រព្រឹត្តទៅ
នៅថ្ងៃទី 21 ខែ [illegible] ឆ្នាំ 2013 វេលាម៉ោង [illegible] ។

ហេតុនេះសូមអញ្ជើញលោកទៅចូលរួមសវនាការក្នុងឋានៈជា [illegible]

ក្នុងករណីមានធុរៈ សូមលោកអោយដំណឹងមកតុលាការកំពូលជាបន្ទាន់ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ 2013
តុលាការកំពូល

ឌិត មុន្ទី

[illegible]
[illegible] 30-04-2013
[illegible] 3, 42 [illegible]

[illegible]
09.05-2013

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

**សភាវរដ្ឋប្បវេណី**
សំណុំរឿងរដ្ឋប្បវេណី
លេខ: ៣៣
ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥
សាលដីកា
លេខ: ៥២៧ “ក”
ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានទាញហេតុផលដោយផ្ទាល់មាត់នាសវនាការជាសាធារណៈនៅថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១-ឯកឧត្តម ជីវ កេង ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
២-លោក យស់ សូខឿន ជាចៅក្រម
៣-លោក អ៊ីវ គីមស្រ៊ី ជាចៅក្រម
៤-លោក សឹង បញ្ញាវុឌ្ឍ ជាចៅក្រម
៥-លោកស្រី សែម សក្កិកូឡា ជាចៅក្រម

**ចៅក្រមទទួលបញ្ជា**

លោកស្រី សែម សក្កិកូឡា

**ក្រឡាបញ្ជី**

លោក ស៊ិន ភារៈ

**តំណាងមហាអយ្យការ**

លោក ឌុច គីមសន ជាព្រះរាជអាជ្ញា

**ដើមចោទ:**លោក វឿន សុជាតិ( ដើមបណ្ដឹងសាទុក្ខ) អាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិមេលប់ ឃុំរការ ស្រុកពារាំង ខេត្តព្រៃវែង។

**អ្នកតំណាងដោយអាណត្តិ៖** លោកស្រីមេធាវី ពឹង ធីតា

**ចុងចម្លើយ:**អ្នកស្រី ណុច សាវឿន (ចុងបណ្ដឹងសាទុក្ខ) ប្ដីឈ្មោះ ដន ដួត អាយុ ៤៩ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង។

**អ្នកតំណាងដោយអាណត្តិ៖** លោកមេធាវី តាន់ ម៉េងស្រ៊ុយ, លោក ភុន វិទ្យា និងកញ្ញា ទិត ដាឡែន

**កម្មវត្ថុបណ្តឹង:**-ប្តឹងទាមទារដីភូមិទំហំ ១៨ម គុណ ១១ម និងផ្ទះសង់អំពីឈើលើថ្មក្រោម ទំហំ ៨ម៉ែត្រ គុណ ៨,៤ម៉ែត្រ ខ្សែកផ្កាទីនទម្ងន់ ៩ជី ២ហ៊ុន និងម៉ូតូ C125 ស៊េរី ២០០៨ មួយគ្រឿង។

## អំពីអង្គហេតុ និង ចំណុចវិវាទ:

ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:

តាមពាក្យបណ្តឹង ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៣ របស់ឈ្មោះ រឿន សុជាតិ បញ្ជាក់ថា: នៅឆ្នាំ ២០១០ ដើមចោទឈ្មោះ រឿន សុជាតិ រៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ដួត សាវិច ហើយបានរួមរស់ជាមួយគ្នាមានកូន ០១នាក់ ឈ្មោះ ជាតិ គីមហុង ភេទប្រុស អាយុ ០៣ឆ្នាំ បានរកស៊ីជាមួយគ្នា ទិញបានដីភូមិទំហំ ១៨ម៉ែត្រ គុណ ១១ម៉ែត្រ និងផ្ទះប្រក់ក្បឿង(ឈើខាងលើ ខាងក្រោមថ្ម) ទំហំ ៨ម៉ែត្រ គុណ ៨,៤ម៉ែត្រ ស្ថិតក្នុងភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ដីភូមិ និងផ្ទះនេះទិញពីបងថ្លៃឈ្មោះ ដួត សាវុធ មានតម្លៃ ១១.០០០ដុល្លារអាមេរិក ទិញម៉ូតូសេ ១២៥ ស៊េរីឆ្នាំ ២០០៨ មួយគ្រឿង មានតម្លៃ ៥០០ដុល្លារអាមេរិក និងខ្សែកផ្កាទីនទម្ងន់ ៩ជី ២ហ៊ុន ឯការរួមរស់នៅជាមួយគ្នា បានសេចក្តីសុខនឹងគ្នាមិនដែលឈ្លោះប្រកែកអ្វីទេ នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ប្រពន្ធដើមចោទមានជម្ងឺរលាកខួរក្បាល ក៏បានស្លាប់ទៅ បន្សល់ទុកកូនប្រុសមួយនាក់កំព្រាម្តាយ ស្រាប់តែម្តាយក្មេកដើមចោទយកខ្សែក ម៉ូតូសេ ១២៥ ស៊េរីឆ្នាំ ២០០៨ មួយគ្រឿង ព្រមទាំងដេញដើមចោទ និងកូនឱ្យចុះចេញពីលើផ្ទះរបស់ដើមចោទថែមទៀត។

តាមពាក្យបណ្តឹងតប ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៣ របស់ឈ្មោះ ដន ដួត និងប្រពន្ធឈ្មោះ ណុច សារឿន បានប្តឹងពីឈ្មោះ រឿន សុជាតិ ឱ្យចុះចេញពីផ្ទះរបស់ខ្លួន ដោយសំអាងហេតុថា៖

១-ដីភូមិ និងផ្ទះនេះ ជាកម្មសិទ្ធិរបស់ខ្លួន ពុំមានពាក់ព័ន្ធជាមួយឈ្មោះ រឿន សុជាតិ ទេ ព្រោះខ្លួនមានលិខិតបញ្ជាក់ពីកម្មសិទ្ធិរបស់ខ្លួនផ្ទាល់។

២-សុំទាមទារប្រាក់ដែលពាក់ព័ន្ធនឹងឈ្មោះ រឿន សុជាតិ មាន៖ ថ្លៃជួសជុលបន្ទប់សរុបមានចំនួន ៥០០ ដុល្លារអាមេរិក, ថ្លៃព្យាបាលជម្ងឺមុនពេលកូនស្រីរបស់ខ្លួនស្លាប់សរុបចំនួន ២.៥០០.០០០(ពីរលានប្រាំសែន)រៀល, ថ្លៃធ្វើបុណ្យក្រោយពេលស្លាប់សរុបចំនួន ១.៥០០.០០០(មួយលានប្រាំសែន)រៀល, ប្រាក់សុទ្ធចំនួន ៥.០០០.០០០ (ប្រាំលាន)រៀល, ខ្សែកផ្កាទីន ១ខ្សែ ស្មើនឹងទម្ងន់ ២ជី មានក្រោយពីពេលរៀបការរួចហើយ។

៣-ដីស្រែ ២កន្លែង គឺចំណុចត្រាំគ ទំហំ ៦០អា និងចំណុចប្រឡាយតូចទំហំ ៦០អា។

៤-ទូ ១គ្រឿង។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០២ "ខ" ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង សម្រេច:**

១-ទទួលស្គាល់បណ្តឹងទាមទាររបស់ដើមចោទឈ្មោះ រឿន សុជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ណុច សារឿន ប្រគល់ម៉ូតូ ០១គ្រឿង ម៉ាកសេ ១២៥ ស៊េរីឆ្នាំ ២០០៨ និងខ្សែកផ្កាទីន, ចិញ្ចៀន, កងដៃ សរុបទម្ងន់ ៩ជី ២ហ៊ុន ឱ្យទៅឈ្មោះ រឿន សុជាតិ ជាដើមចោទវិញ នៅពេលដែលសាលា-

ក្រមចូលជាស្ថាពរ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

៤-សាលក្រមនេះ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ចំពោះមុខគូភាគី សម្រេចបើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

*សាលក្រមនេះ ត្រូវបានឈ្មោះ ណុច សាវឿន ប្ដឹងឧទ្ធរណ៍ តាមបណ្ដឹងលេខ ១២ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ត្រង់ចំណុច នៃសេចក្ដីសម្រេចទាំងមូល។*

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៤ ក្រ.IV.សស ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ របស់សាលាឧទ្ធរណ៍ សម្រេចៈ**

១-ទទួលបណ្ដឹងឧទ្ធរណ៍ របស់ចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ខ្លះ។

២-ទទួលស្គាល់បណ្ដឹងតប ចុះថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០១៣ របស់ចុងចម្លើយ ណុច សាវឿន និងប្ដីឈ្មោះ ដន ដួត ត្រង់ចំណុចទី ១ ការទាមទារឱ្យ វឿន សុជាតិ ចុះចេញពីផ្ទះ និងដីទំនាស់ទុកជាត្រឹមត្រូវតាមច្បាប់។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០២(ខ) ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់សេចក្ដីសម្រេចចំណុចទី ២ បង្គាប់ឱ្យចុងចម្លើយ ណុច សាវឿន ប្រគល់ម៉ូតូ ០១គ្រឿង ម៉ាកសេ ១២៥ ស៊េរីឆ្នាំ ២០០៨ ឱ្យឈ្មោះ វឿន សុជាតិ ជាដើមចោទវិញ។ ចំណុចក្រៅពីនេះ ត្រូវលុបចោល។

៤-បង្គាប់ឱ្យដើមចោទឈ្មោះ វឿន សុជាតិ ចាកចេញពីផ្ទះ និងដីទំនាស់ទំហំ ១៨ម៉ែត្រ គុណ ១១ម៉ែត្រ ផ្ទះទំហំ ៨ម៉ែត្រ គុណ ៨,៥ម៉ែត្រ ឈើលើ ថ្មក្រោម ស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង និងឱ្យចុងចម្លើយឈ្មោះ ណុច សាវឿន ប្រគល់ប្រាក់ចំនួន ១.០០០ដុល្លារអាមេរិក ឱ្យទៅដើមចោទឈ្មោះ វឿន សុជាតិ វិញ។

៥-សាលដីកានេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ នាថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ បើកផ្លូវប្ដឹងសាទុក្ខក្នុងរយៈពេល ០១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

*សាលដីកានេះត្រូវបានឈ្មោះ វឿន សុជាតិ ប្ដឹងសាទុក្ខតាមបណ្ដឹងលេខ ១៦៣ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤ ត្រង់ចំណុច នៃសេចក្ដីសម្រេចទាំងមូល។*

**ខ-*<u>អំពីសេចក្ដីថ្លែងការណ៍របស់គូភាគី:</u>***

**ឈ្មោះ វឿន សុជាតិ** ធ្វើសេចក្ដីថ្លែងការណ៍ថា: ផ្ទះ និងដីនេះ ខ្លួនទិញពីបងថ្លៃឈ្មោះ ដួត សាវុធ តែគ្មានលិខិតស្នាមទេ ព្រោះម៉ែក្មេកថា បងប្អូនឯងមិនបាច់ធ្វើទេ។ ខាងចុងចម្លើយក៏គ្មានលិខិតស្នាមដែរ។ ខ្លួនសុំទាមទារគ្រប់គ្រងផ្ទះ និងដីនេះ ព្រោះក្នុងការទិញលក់នេះ មានអ្នកស្រុក អ្នកភូមិដឹងឮថា ខ្លួនពិតជាទិញផ្ទះនេះមែន។ ខ្លួនបានឱ្យលុយទៅបងថ្លៃគ្រប់ចំនួនហើយ។

ចំពោះម៉ូតូ សេ ១២៥ និងមាសទម្ងន់ ៩,២ជី ខ្លួនទិញពីរនាក់ប្ដីប្រពន្ធ ក្រោយពេលរៀបការ។ ថ្លៃព្យាបាលជម្ងឺ និងសោហ៊ុយធ្វើបុណ្យសពខ្លួនជាអ្នកចេញ។ ពេលប្រពន្ធខ្លួនស្លាប់ ម៉ែក្មេកខ្លួនខ្ចី ហើយយកទុករហូតតែម្ដង។

**ឈ្មោះ ណុច សាវឿន** ធ្វើសេចក្ដីថ្លែងការណ៍ថា: ផ្ទះនេះខ្លួនឱ្យកូនរស់នៅបណ្ដោះអាសន្នពេលកូនខ្លួននៅ

រស់ ពេលនេះ កូនខ្លួនស្លាប់ហើយ ខ្លួនសុំទាមទារយកផ្ទះខ្លួនវិញ។ ចំពោះយ៉ាបផ្ទះ ខ្លួនឲ្យដើមចោទរុះយកវិញចុះ។ ផ្ទះនេះតម្លៃ ១២.០០០ដុល្លារ ឲ្យខ្លួនបានតែ ១.០០០ដុល្លារ នៅសល់ ១១.០០០ដុល្លារ មិនទាន់ឲ្យទេ។ តាំងពីដើម មក ទល់ពេលនេះ ម្តាយខ្លួនរស់នៅខាងលើរហូត។ ចំពោះម៉ូតូខ្លួនជាអ្នកទិញឲ្យកូនជិះទៅរៀនដេរមុនរៀបការ ក្រោយរៀបការហើយ ខ្លួនឲ្យប្រាក់ដើមចោទ ១០ម៉ឺន និងអត្តសញ្ញាណប័ណ្ណ យកទៅធ្វើស្លាកលេខ តែដើមចោទធ្វើដាក់ឈ្មោះខ្លួនឯងទៅវិញ។ ថ្លៃពេទ្យ និងថ្លៃធ្វើបុណ្យសព ខ្លួនចេញទាំងអស់។

លោកស្រី ពឹង ធីតា មេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ រឿន សុជាតិ ធ្វើសេចក្តីថ្លែងការណ៍ថាៈ កូនក្តីខ្លួនរៀបការជាមួយកូនចុងចម្លើយក្នុងឆ្នាំ ២០១០ មានកូនប្រុសអាយុ ៣ឆ្នាំ ដោយមានមុខរបរទាំងពីរនាក់ ទើបសន្សំលុយទិញផ្ទះ និងដីពីបងថ្លៃឈ្មោះ ដួត សាវុធ តម្លៃ ១១.០០០ដុល្លារ ដោយបានប្រគល់ប្រាក់ឲ្យគ្រប់ចំនួន។ ឈ្មោះ ដួត សាវុធ បានប្រាក់នេះ យកទៅទិញដីកន្លែងផ្សេងទៀតរួចហើយ។ ម៉ូតូ កូនក្តីខ្លួនទិញតម្លៃ ១.៤៧០ដុល្លារ និងគ្រឿងអលង្ការ គឺជាទ្រព្យទិញរួមគ្នាជាមួយប្រពន្ធក្នុងចំណងអាពាហ៍ពិពាហ៍។

អង្គហេតុ ពិតជាមានការទិញលក់ពិតប្រាកដមែន ចុងចម្លើយក៏បានឆ្លើយថា បានទទួលប្រាក់ ១.០០០ដុល្លារ ពីដើមចោទដែរ។ ឯ ដួត សាវុធ បើពុំបានលុយពីការលក់ផ្ទះ និងដីនេះទេ ក៏ពុំមានលុយទិញដីនៅកន្លែងផ្សេងដែរ។ មានសាក្សីជាអនុភូមិ សមាជិកក្រុមប្រឹក្សាឃុំ បញ្ជាក់ថា កូនក្តីខ្លួនពិតជាបានទិញផ្ទះពីឈ្មោះ ដួត សាវុធ ពិតប្រាកដមែន។ ឯកសារកាន់កាប់របស់ចុងចម្លើយមានភាពមិនប្រក្រតី ហើយលិខិតកាន់កាប់នេះ មានអ្នកកាន់កាប់ដល់ទៅ ៤នាក់ ក្នុងនោះមានឈ្មោះ ដួត សាវុធ ដែរ ដែលស្របទៅនឹងចម្លើយដើមចោទថា បានទិញផ្ទះនេះពីឈ្មោះ ដួត សាវុធ។ ចំពោះគ្រឿងអលង្ការ គឺបានទិញក្នុងចំណងអាពាហ៍ពិពាហ៍ ឯម៉ូតូ គឺមានលិខិតទិញពីក្រុមហ៊ុនរបស់កូនក្តីខ្លួន។ កូនក្តីខ្លួនពុំបានប្រឌិតអង្គហេតុទេ។

សំណូមពរៈ សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ទាំងមូល។

លោក តាន់ ម៉េងស្រ៊ុយ មេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ណុច សារឿន ធ្វើសេចក្តីថ្លែងការណ៍ថាៈ ពេលផ្សះផ្សានៅឃុំ ដើមចោទឆ្លើយថា បានប្រគល់ប្រាក់ ៨ពាន់ដុល្លារ តែនាសវនាការនេះឆ្លើយថា បានប្រគល់ឲ្យគ្រប់ចំនួន។ តាំងពីតុលាការថ្នាក់ក្រោមមក ទើបតែនៅសវនាការតុលាការកំពូលនេះទេ ដែលដើមចោទឆ្លើយថា បានចេញថ្លៃព្យាបាល និងធ្វើបុណ្យសព។ ឈ្មោះ ដួត សាវុធ បានឆ្លើយបដិសេធថា ពុំបានលក់ផ្ទះឲ្យដើមចោទទេ ព្រោះជាដីម្តាយ។ បើដើមចោទទទួលស្គាល់ថា គ្រឿងអលង្ការជាទ្រព្យរួម គឺមិនអាចទាមទារបានទេ ព្រោះម្តាយលក់យកប្រាក់ព្យាបាលជម្ងឺ និងធ្វើបុណ្យសពប្រពន្ធខ្លួនអស់ហើយ។

សំណូមពរៈ សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមទទួលបញ្ជា

-ក្រោយពីបានស្តាប់យោបល់របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និងមេធាវីតំណាងដោយអាណត្តិរបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៦៣ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤ របស់ឈ្មោះ **រឿន សុជាតិ** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ២៨៣ មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-យល់ឃើញថា ដើមបណ្តឹងសាទុក្ខបានអះអាងថា ដី និងផ្ទះ ដែលស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង គឺខ្លួន និងប្រពន្ធបានទិញពីឈ្មោះ ដួត សារុធ និងបានប្រគល់ប្រាក់ថ្លៃទិញចំនួន ១១.០០០ដុល្លារអាមេរិក គ្រប់ចំនួនរួចហើយ ទើបខ្លួន និងប្រពន្ធមានសិទ្ធិចូលទៅរស់នៅក្នុងផ្ទះនោះ និងសាងសង់បន្ទប់ តយ៉ាក ក៏ប៉ុន្តែពុំមានឯកសារណាមួយបញ្ជាក់អំពីការលក់ទិញ និងការប្រគល់ប្រាក់គ្រប់ចំនួនទេ។ ម្យ៉ាងទៀត ការដែលដើមចោទ និងប្រពន្ធបានចូលទៅនៅក្នុងផ្ទះនោះ ដោយសារ ប្រពន្ធរបស់ដើមចោទជាកូនស្រីបង្កើតរបស់ចុងចម្លើយ ហើយចុងចម្លើយប្រគល់ផ្ទះនោះឱ្យកូនស្នាក់នៅបណ្តោះអាសន្ន ។ លើសពីនេះទៀត ពុំមានឯកសារណាមួយដែលបញ្ជាក់ថា ដី និងផ្ទះទំនាស់ជាកម្មសិទ្ធិរបស់ឈ្មោះ ដួត សារុធ ទេ ពីព្រោះ តាមលិខិតផ្ទេរសិទ្ធិដី ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥ បង្ហាញថា ឈ្មោះ រឹម នាង បានលក់ដីទំនាស់ទៅឱ្យឈ្មោះ ដួត សារឿន ពុំមែនលក់ទៅឱ្យ ដួត សារុធ ទេ។ ហើយការអះអាងរបស់តំណាងដោយអាណត្តិដើមចោតថា លិខិតបញ្ជាក់កម្មសិទ្ធិ មានឈ្មោះ ដួត សារុធ ជាម្ចាស់កម្មសិទ្ធិដែរនោះ ជាការមិនត្រឹមត្រូវទេ ពីព្រោះ តាមខ្លឹមសារនៃលិខិតនោះ បង្ហាញជាក់ច្បាស់ថា ដីទំនាស់ជាកម្មសិទ្ធិរបស់ចុងចម្លើយតែប៉ុណ្ណោះ។

៣-យល់ឃើញថា ចុងចម្លើយបានទទួលស្គាល់ថា ខ្លួនព្រមលក់ផ្ទះឱ្យកូនស្រីខ្លួនក្នុងតម្លៃ ១២.០០០ដុល្លារអាមេរិក ហើយកូនបានឱ្យប្រាក់ចំនួន ១.០០០ដុល្លារអាមេរិក នៅខ្វះចំនួន ១១.០០០ដុល្លារអាមេរិកទៀត ពេលនេះកូនខ្លួនស្លាប់ហើយ ដូចនេះ ខ្លួនឈប់លក់វិញហើយ ក្នុងករណីនេះ ចុងចម្លើយដែលជាអ្នកលក់ក៏មានសិទ្ធិក្នុងការរំលាយកិច្ចសន្យាចោលវិញដែរ ដោយសង ២ដងនៃប្រាក់កក់ទៅឱ្យអ្នកទិញវិញ យោងតាមមាត្រា ៥១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែ ដោយសារអង្គហេតុនេះ ចូលជាស្ថាពរហើយ តុលាការកំពូលអាចសម្រេចបានដោយមិនបង្វិល តាមមាត្រា ៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤-យល់ឃើញថា នាពេលសវនាការតុលាការកំពូល ដើមចោទបានអះអាងថា ខ្លួនជាអ្នកចេញលុយព្យាបាលជម្ងឺ ចំណាយក្នុងការធ្វើបុណ្យសពប្រពន្ធខ្លួន ចំណុចនេះ ជាអង្គហេតុថ្មីមួយដែលដើមចោទទើបលើកឡើងនៅពេលនេះ ដូចនេះ តុលាការកំពូលពុំលើកយកមកពិចារណាទេ។ ផ្ទុយទៅវិញ ការដែលសាលាឧទ្ធរណ៍សម្រេចលប់ចោលការប្រគល់គ្រឿងអលង្ការទៅឱ្យដើមចោទនោះ ជាការត្រឹមត្រូវហើយ ពីព្រោះ ដើមចោទទទួលស្គាល់ថា នៅពេលប្រពន្ធខ្លួនឈឺ ចុងចម្លើយជាអ្នកដឹកយកទៅមន្ទីរពេទ្យ ដូចនេះ អាចជឿបានថា ចុងចម្លើយជាអ្នកមើលថែជម្ងឺ រហូតដល់បុណ្យសពកូនទៀត ផ្ទុយទៅវិញ ការដែលដើមចោទអះអាងថា ខ្លួនជាអ្នកមើលថែប្រពន្ធ និងចំណាយក្នុងការធ្វើបុណ្យសពនោះ ពុំមានអ្វីមកបញ្ជាក់ទេ។

៥-យល់ឃើញថា ចំពោះម៉ូតូមួយគ្រឿងម៉ាកសេ ១២៥ ស៊េរីឆ្នាំ ២០០៨ ដែលដើមចោទបានទាមទារ និងសំយ៉ាបដែលដើមចោទបានអះអាងថា ខ្លួនជាអ្នកធ្វើនោះ ចុងចម្លើយយល់ព្រមប្រគល់ឱ្យទៅដើមចោទវិញ ដូចនេះ គប្បីសម្រេចតាមគោលការណ៍នៃសិទ្ធិបាត់ចែងរបស់គូភាគី។

៦-យល់ឃើញថា ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ តាមសាលដីកាលេខ ០៤ក្រIV "សស" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ ត្រឹមត្រូវខ្លះ ខុសខ្លះ។

៧-យល់ឃើញថា តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

## សេចក្ដីសម្រេចបញ្ចប់

១-ច្រានចោលផ្នែកខ្លះ នៃបណ្ដឹងសាទុក្ខលេខ ១៦៣ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤ របស់ឈ្មោះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ០៤ក្រIV "សស" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុច បង្គាប់ឱ្យចុងចម្លើយប្រគល់ប្រាក់ចំនួន ១.០០០(មួយពាន់)ដុល្លារអាមេរិក ទៅឱ្យដើមចោទ ត្រូវកែប្រែមកជា ឱ្យឈ្មោះ ប្រគល់ប្រាក់ចំនួន ២.០០០(ពីរពាន់)ដុល្លារអាមេរិក ទៅឱ្យដើមចោទឈ្មោះ វិញ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយឈ្មោះ ។

៤-សាលដីកានេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងប្រកាសនាពេលសវនាការជាសាធារណៈនៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ។

| | | | |
|---|---|---|---|
| ឯកឧត្ដម | ជីវ | កេង | ប្រធាន |
| លោក | យស់ | សូខឿន | ចៅក្រម |
| លោក | អ៊ុំ | គីមស្រ៊ី | ចៅក្រម |
| លោក | សឹង | បញ្ញាវុឌ្ឍ | ចៅក្រម |
| លោកស្រី | សែម | សក្តិកូឡា | ចៅក្រម |
| លោក | ស៊ិន | ភារៈ | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥
ក្រឡាបញ្ជី

ស៊ិន ភារៈ

បានឃើញ
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ជីវ កេង

(មានរូបមន្តអនុវត្តនៅខាងក្រោយ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

| សារាចរដ្ឋខេត្តព្រៃវែង | | |
|---|---|---|
| ពាក្យ | លេខ | |
| ចុះថ្ងៃទី | ខែ | ឆ្នាំ២០.. |
| ម៉ោង :... | | |

**លេខ: ៩៤៧/១៥ តកក-សរណ**

## រូបមន្តអនុវត្តសាលដីកា

**យើង** : ជាក្រឡាបញ្ជីសភារដ្ឋប្បវេណី នៃតុលាការកំពូល។

-បានឃើញមាត្រា ៣៥៤, ៣៥៥, ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានឃើញលិខិតបញ្ជាក់សាលដីកាស្ថាពរលេខ ៩៤៦/១៥ តកក-សរណ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ របស់តុលាការកំពូល។

-បានឃើញពាក្យសុំ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ របស់មេធាវី តាន់ ម៉េងស្រ៊ុយ

-បានឃើញសេចក្តីអនុញ្ញាត ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ របស់ប្រធានតុលាការកំពូល។

**<u>សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្ត មានខាងក្រោមនេះ</u> ÷**

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ៖ , ប្តីឈ្មោះ

អសយដ្ឋាន: ភូមិមេលប់ ឃុំរការ ស្រុកពារាំង ខេត្តព្រៃវែង

តំណាងដោយ:លោកមេធាវី

អាចអនុវត្តដោយបង្ខំទារយក: តាមសាលដីការដ្ឋប្បវេណីលេខ ៥២៧ “ក” ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ របស់តុលាការកំពូល។

កូនបំណុលនៃការអនុវត្តឈ្មោះ៖

អាសយដ្ឋាន: ភូមិមេលប់ ឃុំរការ ស្រុកពារាំង ខេត្តព្រៃវែង

តំណាងដោយ:............................................................................................................

*សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឲ្យសម្រេចតាមសាលដីកាស្ថាពរនេះ និងឲ្យអាជ្ញាធរសាធារណៈ ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។*

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥

ក្រឡាបញ្ជី

* សម្រាប់ប្រើប្រាស់នៅតុលាការកំពូល

* អ្នកស្នើសុំត្រូវបង់ពន្ធលើពាក្យសុំនេះចំនួន ៥.០០០៛

## របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| | | | |
|---|---|---|---|
| កាលបរិច្ឆេទធ្វើចេញ: ថ្ងៃទី ២៥ | ខែ មីនា | ឆ្នាំ ២០១៤ | |

លេខសំណុំរឿង: ៤៣៣/២០.១១.២០១៣

ឈ្មោះឯកសារដែលត្រូវបានបញ្ជូន: សាលដីកាលេខ ១០ [illegible] / ១៩.៣.២០១៤

ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន:

អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន:

ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: ២៥-៣-2014

ហត្ថលេខា ឬ ស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង:

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (គត្តាប្រែសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

ទីកន្លែងដែលបានធ្វើការបញ្ជូន :

កាលបរិច្ឆេទនៃការបញ្ជូន : ថ្ងៃទី.............. ខែ.............. ឆ្នាំ.............. ម៉ោង.............. ព្រឹក/រសៀល

### វិធីជាក់ស្តែងក្នុងការបញ្ជូន

| | |
|---|---|
| ☐ ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | ☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអក្សរ |
| ☐ ២ | ខ្ញុំបានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ |
| | ☐ អ្នកបម្រើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | ឈ្មោះ : |
| ☐ ៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថា បុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ |
| | ☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ : |

☐ **ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ**

☐ **ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូនខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។**

កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃទី.............. ខែ.............. ឆ្នាំ..............

ឈ្មោះ និង ហត្ថលេខាអ្នកធ្វើរបាយការណ៍ :

# ឯកសារយោង

## ❖ ឯកសារជាភាសាខ្មែរ


១-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២-ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា, លេខ ០៦ ក្រ, ០៨ កុម្ភៈ ១៩៩៣

៣-ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

៤-ក្រមរដ្ឋប្បវេណីកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

៥-ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤

៦-សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ភាគ១ ស្តីពីនីតិវិធីបណ្តឹង ឆ្នាំ២០០៨

៧-សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

៨- កម្រងឯកសារបណ្តុះបណ្តាលមន្ត្រីសាធារណៈ ស្តីអំពីច្បាប់ និងសាលាជម្រះក្តីកម្ពុជា

៩- លោក កុយ នាម និង ឡុង បញ្ញាវុធ, អយ្យការះប្រវត្តិ និងការសិក្សាប្រៀបធៀប (បោះពុម្ពលើកទី១ ឆ្នាំ២០០៦)

១០- សាស្ត្រាចារ្យ ខាំ សុមករា, នីតិរដ្ឋប្បវេណី (បោះពុម្ពលើកទី២ ឆ្នា២០១២)

១១-រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សៀវភៅ ស្តីពី ការពន្យល់អំពីនីតិវិធីជម្រះក្តីលើកទី១ (បោះពុម្ពលើកទី២ ឆ្នាំ២០០៩)

១២- មេធាវី អ៊ីវ ប៉ូលី, មេរៀនសង្ខេបនីតិវិធីរដ្ឋប្បវេណី (បោះពុម្ពលើកទី១ ឆ្នាំ២០១០)

១៣- សម្តេចព្រះសង្ឃរាជ ជួន ណាត , វចនានុក្រមខ្មែរ ព.ស.២៥១១ គ.ស.១៩៦៧

១៤- ទីស្តីការគណៈរដ្ឋមន្ត្រី , សន្ទានុក្រមពាក្យច្បាប់ ឆ្នាំ២០០៧

❖ **គេហទំព័រ**

១- http://www.supremecourt.gov.kh/index.php/km/about-us

២- https://leangheng01.wordpress.com/នីតិវិធីរដ្ឋប្បវេណី/

៣- http://cambodialawstudent.blogspot.com/2014/07/blog-post_1799.html

៥- www.law-society.asia